ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សន្និបាត

## បូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ ឆ្នាំសិក្សា ២០១៦-២០១៧ និងទិសដៅ ឆ្នាំសិក្សា ២០១៧-២០១៨

ថ្ងៃទី២៤-២៥ ខែមករា ឆ្នាំ២០១៨

| មាតិកា | ទំព័រ |
|---|---|
| **ផ្នែកទី ១ ៖ លទ្ធផល និង ទិសដៅ** | |
| **១.សេចក្តីផ្តើម** | ១ |
| **២.វឌ្ឍនភាព** | ២ |
| **២.១.លទ្ធផលរួមរបស់មន្ទីរអប់រំ យុវជន និងកីឡា** | ២ |
| ២.១.១ ការវិភាគអំពីវឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល (ឧបសម្ព័ន្ធទី ១) ផលសម្រេចបានសូចនាករស្នូលទាំង ៨ របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំខេត្ត | ២ |
| ២.១.២ ការវិភាគអំពីវឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៧ (ឧបសម្ព័ន្ធទី ២) | ៣ |
| ២.១.៣ ការវិភាគអំពីវឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ២០១៧ (ឧបសម្ព័ន្ធទី៣ ) | ៤ |
| ២.១.៤ ការវិភាគអំពីវឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ ១៥ចំណុច | ៥ |
| **២ ២.លទ្ធផលតាមអនុវិស័យ** | ១០ |
| ២.២.១.អនុវិស័យ ការអប់រំកុមារតូច | ១០ |
| ២.២.២.អនុវិស័យ ការអប់រំបឋមសិក្សា | ១៥ |
| ២.២.៣.អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | ២២ |
| ២.២.៤.អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ៣៣ |
| ២.២.៥.អនុវិស័យ ការអភិវឌ្ឍយុវជន | ៣៨ |
| ២.២.៦.អនុវិស័យ ការអភិវឌ្ឍអប់រំកាយនិងកីឡា | ៤២ |
| **២ ៣.សកម្មភាព និងលទ្ធផលរបស់សមាគមបុគ្គលិកសិក្សាខ្មែរ** | ៤៦ |
| **៣.ទិសដៅឆ្នាំសិក្សា ២០១៧-២០១៨** | ៤៧ |
| **៣.១.ទិសដៅតាមអនុវិស័យ** | ៤៧ |
| ៣.១.១.អនុវិស័យ ការអប់រំកុមារតូច | ៤៧ |
| ៣.១.២.អនុវិស័យ ការអប់រំបឋមសិក្សា | ៤៧ |
| ៣.១.៣.អនុវិស័យ ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | ៤៨ |
| ៣.១.៤.អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ | ៤៩ |
| ៣.១.៥.អនុវិស័យ ការអភិវឌ្ឍយុវជន | ៤៩ |
| ៣.១.៦.អនុវិស័យ ការអភិវឌ្ឍអប់រំកាយនិងកីឡា | ៤៩ |
| **៣.២.បញ្ហាប្រឈម និងទិសដៅឆ្លងអនុវិស័យ** | ៥១ |
| ៣.២.១.ការពង្រីកប្រព័ន្ធផែនការ | ៥១ |
| ៣.២.២.ការគ្រប់គ្រងបុគ្គលិក និងនីតិកម្ម | ៥១ |
| ៣.២.៣.ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ៥២ |
| ៣.២.៤.ការងាររដ្ឋបាល | ៥៣ |
| ៣.២.៥.ការងារគុណភាពអប់រំ | ៥៤ |
| **៤.សេចក្តីសន្និដ្ឋាន** | ៥៤ |
| **ផ្នែកទី ២ ៖ ឧបសម្ព័ន្ធ** | ៥៦ |

| | |
|---|---|
| ឧបសម្ព័ន្ធទី ១ ៖ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល និងចំណុចដៅសម្រាប់ឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ | ៥៦ |
| ឧបសម្ព័ន្ធទី ២ ៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៦-២០១៧ | ៥៧ |
| ឧបសម្ព័ន្ធទី ៣ ៖ ការពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ | ៦២ |
| ឧបសម្ព័ន្ធទី ៤ ៖ តារាងសូចនាករនិងចំណុចដៅរបស់អនុវិស័យ ឆ្នាំ ២០១៧ | ៧៣ |
| **ផ្នែកទី៣ ៖ ប្រធានបទពិភាក្សា** | |
| ប្រធានបទពិភាក្សា | ៧៦ |

# ផ្នែកទី១

# លទ្ធផល និងទិសដៅ

## ១-សេចក្តីផ្តើម៖

មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ បាននឹងកំពុងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៥-២០១៧ ដែលឆ្លើយតបនឹងកំណែទម្រង់ និងដំណើរការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ។ គោលនយោបាយយុទ្ធសាស្ត្ររួម ទាំងវិធានការកំណែទម្រង់អាទិភាព ១៥ចំណុច របស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានសម្រេចដើម្បីឆ្លើយតប ទៅនឹងគោលនយោបាយទីមួយគឺ ***ធានាគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*** និងគោលនយោបាយទីពីរគឺ ***ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*** ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធក្នុងការប្រើប្រាស់សក្តានុពលធនធានសរុបឱ្យអស់លទ្ធភាព ។

ការពិនិត្យតាមដាន និងពិនិត្យឡើងវិញ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំតាមដំណាក់កាល និងជាប្រចាំ គឺជាការងារដ៏មានសារៈសំខាន់ដើម្បីតម្រង់ទិសការងារឱ្យសម្រេចបានតាមគោលដៅអប់រំដែលបានគ្រោងទុក ។ សន្និបាតអប់រំដែលបានរៀបចំឡើងជារៀងរាល់ឆ្នាំបានផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធទាំងអស់បានពិភាក្សា ពិនិត្យវឌ្ឍនភាពការងារ បញ្ហាប្រឈម និងកំណត់ទិសដៅសម្រាប់អនុវត្តបន្តដើម្បីអភិវឌ្ឍន៍វិស័យអប់រំក្នុងខេត្ត ឱ្យស្របតាមកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ។គណៈកម្មការបច្ចេកទេសសន្និបាតអប់រំបានបង្កើតឡើង ដើម្បីដំណើរការរៀបចំសន្និបាតដែលមានក្របខណ្ឌការងារ និងមានវត្ថុបំណងច្បាស់លាស់ ។ គុណភាពនៃការរៀបចំសន្និបាតអប់រំក៏ត្រូវបានលើកកម្ពស់ តាមរយៈរបាយការណ៍បូកសរុបការងារឱ្យកាន់តែមានលក្ខណៈសាមញ្ញ វិភាគ និងផ្តោតសំខាន់លើលទ្ធផល ។

វឌ្ឍនភាពនៃការអនុវត្តការងារតាមអនុវិស័យ និងការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការ ប្រតិបត្តិឆ្នាំ២០១៧ បានឆ្លុះបញ្ចាំងនូវខ្លឹមសារនៃរបាយការណ៍សន្និបាតអប់រំដើម្បីជាមូលដ្ឋាន សម្រាប់ធ្វើការពិនិត្យឡើងវិញពីសកម្មភាព និងចំណុចដៅរបស់សូចនាករក្នុងការបំពេញការងារគន្លឹះៗ ។ របាយការណ៍សន្និបាតអប់រំបានឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព បញ្ហាប្រឈម និងអនុសាសន៍ជារួមរបស់មន្ទីរ និងតាមអនុវិស័យទាំង ០៦ រួមមាន ការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន និងការអប់រំកាយ និងកីឡា ។

ជាក់ស្តែងក្នុងឆ្នាំសិក្សា២០១៦-២០១៧ កន្លងមកនេះ មន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ សម្រេចបានលទ្ធផលធំៗ ដូចតទៅ ៖

# ២-វឌ្ឍនភាព

## ២.១-លទ្ធផលរួមវិស័យអប់រំ យុវជន និងកីឡា

### ២.១.១-ការវិភាគអំពីវឌ្ឍនភាពនៃការសម្រេចសូចនាករស្នូល

**តារាងទី១ ៖ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូលទាំង ៨ របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំខេត្ត**

| សូចនាករស្នូល | ជាក់ស្តែង ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ស្ថានភាព |
|---|---|---|---|---|
| ***គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*** | | | | |
| ១. ភាគរយកុមារអាយុ ៥ឆ្នាំក្នុងការអប់រំកុមារតូចគ្រប់រូបភាព | ៥៨.៨១% | ៦៥% | ៥៩% | → |
| ២. ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០ ភាគរយ | ៧ | ៧ | ៧ | ↑ |
| ៣. ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ ភាគរយ | ១ | ១ | ១ | ↑ |
| ៤. អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥ឡើង) | ៩០.៤៧% | ៩០.៧២% | ៩០.៧០% | → |
| ៥. ការវាយតម្លៃថ្នាក់ជាតិលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី ៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | | | | |
| ការអាន | N/A | ៥២.១% | ៥២.១% | ↑ |
| គណិតវិទ្យា | N/A | ៤៨.៣% | ៤៨.៣% | ↑ |
| ***គោលនយោបាយទី២ ៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*** | | | | |
| ៦. ចំនួនគ្រូបង្រៀនបានចូលរួមថ្នាក់ពន្លឿន | ២៨ នាក់ | ៤៥ នាក់ | ២៨ នាក់ | → |
| ៧. ចំនួននាយកសាលាបានបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល | ៤០នាក់ | ៥០ នាក់ | ៤៣ នាក់ | → |
| ៨. ភាគរយនៃការទូទាត់ថវិកា | ៨៦.១៧% | ៩៥% | ៩៨.១៧% | ↑ |

***សម្គាល់:*** ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

កុមារអាយុ៥ឆ្នាំបានទទួលសេវាអប់រំកុមារតូចគ្រប់រូបភាព ៥៩ភាគរយ នៃចំនួនប្រជាជនអាយុ៥ឆ្នាំ ទាបជាង ៦ ភាគរយ ធៀបនឹងចំណុចដៅឆ្នាំ២០១៦-២០១៧។ លទ្ធផលនេះដោយសារការពង្រីកសេវាអប់រំកុមារតូចពុំទាន់មានវិសាលភាពទូលំទូលាយដោយខ្វះសាលា ខ្វះបន្ទប់រៀន ខ្វះគ្រូមត្តេយ្យសិក្សា និងការផ្តល់ធាតុចូលផ្សេងៗពុំបានតាមតម្រូវការ ។

ចំនួនក្រុង/ស្រុកដែលមានអត្រាបញ្ចប់ការសិក្សាលើសពី៨០ភាគរយចំនួន ៧ក្រុង/ស្រុក លទ្ធផលនេះដោយសារការគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ជាពិសេសនាយក/នាយិកាសាលា គ្រូមានវិធីសាស្ត្របង្រៀនសម្បូរបែប មានសម្ភារៈសម្រាប់បង្រៀននិងរៀន មានការសហការពីមាតាបិតាសិស្សក្នុងការជួយកូនៗឱ្យបានមករៀនបានទៀងទាត់ សិស្សក្រីក្របានទទួលអាហារូបករណ៍ និងមានអង្គការដៃគូជាតិ អន្តរជាតិ ជួយទាំងផ្នែកបច្ចេកទេសនិងសម្ភារៈ និងមានការគាំទ្រពីថ្នាក់ដឹកនាំតាំងពីក្រសួង រហូតដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ។

អត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ភាគរយ សម្រេចបានមួយក្រុងតាមចំណុចដៅ ដោយសារក្រុងសួងមិនសូវមានសិស្សបោះបង់ការសិក្សាច្រើនដូចស្រុកដទៃទៀតទេ ។

អត្រាអក្ខរកម្មមនុស្សពេញវ័យ អាយុ១៥ឆ្នាំឡើងសម្រេចបាន ៩០.៧០ភាគរយ បើធៀបនឹងចំណុចដៅឆ្នាំសិក្សា ២០១៦-២០១៧ មិនទាន់សម្រេចបានតាមចំណុចដៅនៅឡើយ តែលទ្ធផលនេះអាចទទួលយកបានបើធៀបនឹងឆ្នាំសិក្សា

២០១៥-២០១៦ ។ លទ្ធផលដែលសម្រេចបាននេះដោយសារមានការគាំទ្រពីអ្នកពាក់ព័ន្ធ មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ការផ្គត់ផ្គង់សម្ភារ និងការចុះជួយពង្រឹងដល់ថ្នាក់អក្ខរកម្មបានទាន់ពេលវេលា ។

### ២.១.២- វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៧

ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ បានបង្ហាញពីសកម្មភាពអនុវត្ត ៣០៥ គិតត្រឹម ខែ ធ្នូ ឆ្នាំ២០១៧ ក្នុងនោះ សកម្មភាព ២៦៨ បានបញ្ចប់ សកម្មភាព ០៤ នៅបន្តអនុវត្ត និង ៣៣ មិនទាន់ចាប់ផ្តើមអនុវត្ត ។

សេចក្តីលម្អិតនៃវឌ្ឍនភាព ស្តីពីការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៧ ( ឧបសម្ព័ន្ធទី ២ ) ។

រូបភាពទី១ ៖ វឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៧




រូបភាពទី២៖ វឌ្ឍនភាពនៃការអនុវត្តសកម្មភាពផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៧



## ២.១.៣-ការវិភាគអំពីវឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ ២០១៧

សន្និបាតអប់រំ ឆ្នាំ ២០១៧ បានលើកទិសដៅ ១១៩ ក្នុងនោះទិសដៅរបស់អនុវិស័យ ៨៥ និងទិសដៅរបស់ឆ្លងអនុ វិស័យ ៣៤។ ទិសដៅ ៦៨ ស្មើនឹង ៥៧.១៤ ភាគរយ បានអនុវត្តចប់ ទិសដៅ ១៣ ស្មើនឹង ១០.៩២ ភាគរយ បានកំពុងអនុវត្ត និង ទិសដៅ ៣៨ ស្មើនឹង ៣១.៩៣ ភាគរយ មិនទាន់អនុវត្ត ។

- ទិសដៅ អនុវិស័យដែលបានអនុវត្តចប់ ៤២ ស្មើនឹង ៤៩.៤១ ភាគរយ ទិសដៅកំពុងអនុវត្ត ១១ ស្មើនឹង ១២.៩៤ ភាគរយ និង ទិសដៅមិនទាន់អនុវត្ត ៣២ ស្មើនឹង ៣៧.៦៥ ភាគរយ ។
- ទិសដៅ ឆ្លងអនុវិស័យ ដែលបានអនុវត្តចប់ ២៦ ស្មើនឹង ៧៦.៤៧ ភាគរយ ទិសដៅកំពុងអនុវត្ត ២ ស្មើនឹង ៥.៨៨ ភាគរយ ទិសដៅមិនទាន់អនុវត្ត ០៦ ស្មើនឹង ១៧.៦៥ ភាគរយ ។

សេចក្តីលម្អិតវឌ្ឍនភាពនៃការអនុវត្តទិសដៅកំណែទម្រង់សំខាន់ៗឆ្នាំ២០១៧ ( ឧបសម្ព័ន្ធទី៣ ) ។

រូបភាពទី៣៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតអប់រំឆ្នាំ២០១៦
( អនុវិស័យ និងឆ្លងអនុវិស័យ )




- **វឌ្ឍនភាពនៃការអនុវត្តទិសដៅ តាមអនុវិស័យ**

ទិសដៅអនុវិស័យសរុប ៨៥ ក្នុងនោះ អនុវិស័យការអប់រំកុមារតូច ១២ អនុវិស័យការអប់រំបឋមសិក្សា ១២ អនុវិស័យការអប់រំមធ្យមសិក្សា ១៧ អនុវិស័យការអប់រំក្រៅប្រព័ន្ធ ០៦ អនុវិស័យការអភិវឌ្ឍយុវជន ១៩ និងអនុវិស័យការអប់រំកាយ និងកីឡា ១៩ ក្នុងនោះទិសដៅដែលបានអនុវត្តចប់ ៤២ ស្មើនឹង ៤៩.៤១ ភាគរយ ទិសដៅកំពុងអនុវត្ត ១១ ស្មើនឹង ១២.៩៤ ភាគរយ និងទិសដៅមិនទាន់អនុវត្ត ៣២ ស្មើនឹង ៣៧.៦៥ ភាគរយ ។

- ទិសដៅដែលបានអនុវត្តចប់ ៤២ ស្មើនឹង ៤៩.៤១ ភាគរយ ដោយក្នុងនោះ អនុវិស័យការអប់រំកុមារតូច ០៣ ស្មើនឹង ២៥ ភាគរយ អនុវិស័យការអប់រំបឋមសិក្សា ២ ស្មើនឹង ១៦.៦៧ ភាគរយ អនុវិស័យការអប់រំមធ្យមសិក្សា ១២ ស្មើនឹង ៧០.៥៩ ភាគរយ អនុវិស័យការអប់រំក្រៅប្រព័ន្ធ ០១ ស្មើនឹង ១៦.៦៧ ភាគរយ អនុវិស័យការអភិវឌ្ឍយុវជន ១៣ ស្មើនឹង ៦៨.៤២ ភាគរយ និងអនុវិស័យការអប់រំកាយ និងកីឡា ១១ ស្មើនឹង ៥៧.៨៩ ភាគរយ ។

- ទិសដៅដែលកំពុងអនុវត្ត ១១ ស្មើនឹង ១២.៩៤ ភាគរយ ដោយក្នុងនោះ៖ អនុវិស័យការអប់រំកុមារតូច ០២ ស្មើនឹង ១៦.៦៧ ភាគរយ អនុវិស័យការអប់រំបឋមសិក្សា ០៦ ស្មើនឹង ៥០ ភាគរយ អនុវិស័យការអប់រំមធ្យមសិក្សា ០១ ស្មើនឹង ៥.៨៨ ភាគរយ អនុវិស័យការអប់រំក្រៅប្រព័ន្ធ ០១ ស្មើនឹង ១៦.៦៧ ភាគរយ អនុវិស័យការអភិវឌ្ឍយុវជន ០១ ស្មើនឹង ៥.២៦ ភាគរយ និងអនុវិស័យការអប់រំកាយ និងកីឡា ០០ ស្មើនឹង ០ ភាគរយ។

- ទិសដៅដែលមិនទាន់អនុវត្ត ៣២ ស្មើនឹង ៣៧.៦៥ ភាគរយ ដោយក្នុងនោះ៖ អនុវិស័យការអប់រំកុមារតូច ០៧ ស្មើនឹង ៥៨.៣៣ ភាគរយ អនុវិស័យការអប់រំបឋមសិក្សា ០៤ ស្មើនឹង ៣៣.៣៣ ភាគរយ អនុវិស័យការអប់រំមធ្យមសិក្សា ០៤ ស្មើនឹង ២៣.៥៣ ភាគរយ អនុវិស័យការអប់រំក្រៅប្រព័ន្ធ ០៤ ស្មើនឹង ៦៦.៦៧ ភាគរយ អនុវិស័យការអភិវឌ្ឍយុវជន ០៥ ស្មើនឹង ២៦.៣២ភាគរយ និងអនុវិស័យការអប់រំកាយ និងកីឡា ០៨ ស្មើនឹង ៤២.១១ ភាគរយ ។

សេចក្តីលម្អិតវឌ្ឍនភាពនៃការអនុវត្តទិសដៅកំណែទម្រង់សំខាន់ៗឆ្នាំ២០១៧ ( ឧបសម្ព័ន្ធទី៣ ) ។

### រូបភាពទី ៤៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅ អនុវិស័យ ឆ្នាំ២០១៧




- **វឌ្ឍនភាពនៃការអនុវត្តទិសដៅ ឆ្លងតាមអនុវិស័យ**

ទិសដៅឆ្លងអនុវិស័យសរុប ៣៤ ក្នុងនោះ ការពង្រឹកប្រព័ន្ធផែនការ ០៩ ការគ្រប់គ្រងបុគ្គលិក ០៧ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ០៩ ការងាររដ្ឋបាល ០៦ និងការងារធានាគុណភាពអប់រំ ៣ ក្នុងនោះទិសដៅដែលបានអនុវត្តចប់ ២៦ ស្មើនឹង ៧៦.៤៧ ភាគរយ ទិសដៅកំពុងអនុវត្ត ២ ស្មើនឹង ៥.៨៨ ភាគរយ និងទិសដៅមិនទាន់អនុវត្ត ០៦ ស្មើនឹង ១៧.៦៥ ភាគរយ ។

សេចក្តីលម្អិតវឌ្ឍនភាពនៃការអនុវត្តទិសដៅកំណែទម្រង់សំខាន់ៗឆ្នាំ២០១៦ ( ឧបសម្ព័ន្ធទី៣ ) ។

### រូបភាពទី ៥៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅ ឆ្លងអនុវិស័យ ឆ្នាំ២០១៧




### ២.១.៤-ការវិភាគអំពីវឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិស័យអប់រំ ១៥ ចំណុច

**កំណែទម្រង់ទី ១ ៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- ប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់បើកប្រាក់បៀវត្សបុគ្គលិក ប្រាក់បេសកកម្ម ប្រាក់ម៉ោងបន្ថែម ប្រាក់បង្រៀនថ្ងៃព្រហស្បតិ៍ ប្រាក់ដំណើរការសាលារៀន ប្រាក់អាហារូបករណ៍
- បានអនុវត្តថវិកាកម្មវិធីពេញលេញ
- ថវិកាដំណើរការសាលារៀន អាគារធនធានបានទម្លាក់ជូនសាលារៀននៅដើមត្រីមាសតាមផែនការរបស់សលរៀន
- ប្រាក់អាហារូបករណ៍បានទម្លាក់ជូនដល់សាលារៀនដើម្បីបើកឱ្យសិស្សដោយសិស្សម្នាក់ៗទទួលបាន ២៤០,០០០រៀល សម្រាប់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និង៣៦០,០០០រៀល សម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ ។ សិស្ស ដែលបានទទួលអាហារូបករណ៍សរុបចំនួន ១០,២៩២ នាក់ ស្រី ៥,៦៦០ នាក់ ក្នុង

នោះសិស្សបឋមសិក្សាមានចំនួន ៨,២៩០ នាក់ ស្រី ៤,៦៤៨ នាក់ និងសិស្សមធ្យមសិក្សាមានចំនួន ២,០០២ នាក់ ស្រី ១,០១២ នាក់

- បានប្រើប្រាស់ប្រព័ន្ធរបាយការណ៍(Excel)ដោយបញ្ចូលទិន្នន័យបានរួចរាល់ទាន់ពេល
- បានប្រមូលចំណូលពីការបង់សិទ្ធិប្រឡងសិស្សមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ចំនួន៩,៤៧៦,០០០រៀល

**កំណែទម្រង់ទី ២ ៖ ការពង្រាយគ្រូបង្រៀន**

- បំប៉នគ្រូបង្រៀនកម្រិតមូលដ្ឋានឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្តមដើម្បីទៅបម្រើការងារនៅតាមគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ដែលខ្វះគ្រូ ចំនួន ៣៧នាក់ ស្រី ៧នាក់
- រៀបចំជម្រើសគោលនយោបាយស្តីពីការពង្រាយគ្រូបង្រៀនទៅតំបន់ដែលខ្វះគ្រូ
- ចេញសេចក្តីណែនាំស្តីពីល័ក្ខខណ្ឌ នីតិវិធីផ្ទេរ និងផ្លាស់ប្តូរកន្លែងបម្រើការងារដែលត្រូវកែសម្រួលនូវខ្លឹមសារមួយចំនួន ដែលដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ ២០១៧ នេះតទៅ

**កំណែទម្រង់ទី ៤ ៖ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន**

- បានបើកវគ្គសិក្ខាសាលា ស្តីពីការបំពេញទិន្នន័យរបាយការណ៍ប្រពន្ធ័ពិនិត្យតាមដានផ្តែកលើលទ្ធផលអនុវិស័យបឋមសិក្សាមានអ្នកចូលរួមចំនួន៩០នាក់ក្នុងគោលបំណងឱ្យការបំពេញរបាយការណ៍មានភាពជាក់លាក់ និងត្រឹមត្រូវ
- បើកវគ្គបំប៉នស្តីពីការពង្រឹងតួនាទីភារកិច្ច DTMT មានអ្នកចូលរួមចំនួន ៦០ នាក់ ស្រី ៣ នាក់ ដើម្បីឱ្យ DTMT មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការងារប្រកបដោយជោគជ័យ ។
- បានបើកវគ្គបំប៉នស្តីពីការគ្រប់គ្រងបណ្ណាល័យដល់នាយកនិងបណ្ណារក្សចំនួន ២៣៨ ស្រី ៦៤នាក់ ក្នុងគោលបំណងឱ្យបណ្ណារក្សដែលមិនទាន់ទទួលការបំប៉នមានសមត្ថភាពគ្រប់គ្រងបណ្ណាល័យបានល្អ ។
- អនុវត្តការងារបំប៉នគ្រូថ្នាក់ទី ១២ លើមុខវិជ្ជាគណិតវិទ្យា និងមុខវិជ្ជាវិទ្យាសាស្ត្រមួយចំនួននៅទូទាំងខេត្ត
- បំប៉នសមត្ថភាពគ្រូអក្ខរកម្មវិជ្ជាជីវៈជាប់កិច្ចសន្យា (គ្រូដែលថ្មី) នៅថ្នាក់ខេត្តចំនួន១៨នាក់ ស្រី៩នាក់ លើការយល់ដឹងស្តីពីការងារអប់រំក្រៅប្រព័ន្ធចិត្តសាស្ត្រ ទស្សនវិជ្ជា និងវិធីសាស្ត្របង្រៀនមនុស្សពេញវ័យ រដ្ឋបាលថ្នាក់ និងការបំពេញកម្រងសំណួរ ការអភិវឌ្ឍជនបទ កិច្ចតែងការបង្រៀន ការងារក្រុម វិធីវាយតម្លៃការសិក្សាសិស្ស ការកិច្ចតែងការបង្រៀន និងបង្រៀនសាកល្បង និងណែនាំពីសៀវភៅសិក្សានីមួយៗ និងកម្មវិធីសិក្សា ។
- ការិយាល័យអប់រំក្រៅប្រព័ន្ធបានបើកសិក្ខាសាលាពង្រឹងសមត្ថភាពគ្រូជំនាញមុខរបរ លើវិធីសាស្ត្របង្រៀនជំនាញ និងការអនុវត្តជាក់ស្តែង ការប្រើប្រាស់ និងថែទាំសម្ភាររបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ការលើកទឹកចិត្តសិស្ស ការបំពេញកម្រងសំណួរព័ត៌មានសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលមានសិក្ខាកាមចូលរួមចំនួន៣០នាក់ ស្រី១១ នាក់ ដែលមានគ្រូជំនាញចំនួន ១២នាក់ ស្រី៨នាក់ ប្រធាន និងអនុប្រធាន ១២ នាក់ ស្រី ៣នាក់ អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុក និងមន្ត្រីជំនាញទទួលបន្ទុកសរុប ៦នាក់ ស្រី ០នាក់ ។
- សិក្ខាសាលាគ្រូអក្ខរកម្ម ៣០ នាក់ ស្រី ១៤ នាក់ មន្ត្រីការិយាល័យ ១២ នាក់ ស្រី ២ នាក់ ស្តីពីបច្ចេកទេសបង្រៀន និងរៀន និងការធ្វើរបាយការណ៍ និងសិក្ខាសាលាវិធីសាស្ត្រការកសាងទិន្នន័យព័ត៌មាន ដែលមាន សិក្ខាកាមសរុប៧៤នាក់ ស្រី ៥ នាក់ មន្ត្រីការិយាល័យស្រុក១២នាក់ ស្រី ២ នាក់ មន្ត្រីអប់រំឃុំ ៦២ នាក់ ស្រី ៣ នាក់ ។

សិក្ខាសាលាគ្រូសមមូលចំនួន ២១ នាក់ ស្រី ៤ នាក់ មានមន្ត្រីការិយាល័យស្រុក ៤ នាក់ ស្តីពី បច្ចេកទេសបង្រៀន និងរៀន និងការធ្វើរបាយការណ៍ ។

- បណ្តុះបណ្តាលគ្រូ និងបុគ្គលិកអប់រំឱ្យមានសញ្ញាបត្រកាន់តែខ្ពស់ ដើម្បីបង្កើនគុណភាពលើការបង្រៀន និងរៀនរបស់គ្រូបានតម្លើងប្រាក់បំណាច់មុខងារជូននាយក នាយិកា នៅគ្រប់កម្រិតភូមិសិក្សាកាន់តែខ្ពស់ថែមទៀត
- ជ្រើសរើសគ្រូបឋម និងមត្តេយ្យសិក្សា ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ ឱ្យទៅបំប៉នជាគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ៥៨ នាក់ ស្រី ២៣នាក់
- បានបំប៉នដល់មន្ត្រីគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ស្តីពីការបង្កើនសមត្ថភាពនៃការគ្រប់គ្រង និងការដឹកនាំចំនួន ២០នាក់ ស្រី ៥នាក់
- បន្តអនុវត្តការងារបណ្តុះបណ្តាលបំប៉នសមត្ថភាព និងវិក្រឹតការគ្រូបង្រៀន ដោយគោរពតាមការណែនាំរបស់ក្រសួង

**កំណែទម្រង់ទី ៥ ៖ ការងារអធិការកិច្ច**

- ចុះពិនិត្យតាមដានចំនួន៤ដង លើកម្មវិធីអក្ខរកម្ម សមមូល និងមជ្ឈមណ្ឌលសិក្សាសហគមន៍
- បានចុះធ្វើអធិការកិច្ចតាមសាលារៀនគោលដៅចំនួន ២៩សាលា ដោយធ្វើការពង្រឹងគុណភាពដល់នាយក គ្រូ (ការងារគ្រប់គ្រង ការបង្រៀន និងរៀន លទ្ធផលសិក្សា ការចូលរួមរបស់សហគមន៍)
- បូកសរុបរបាយការណ៍អធិការកិច្ចផ្ទៃក្នុងរបស់ក្រុង/ស្រុកទាំង ៧ ចំនួន ០២ លើក
- ប្រជុំផ្សព្វផ្សាយលទ្ធផលការងារអធិការកិច្ចដល់គណៈគ្រប់គ្រងលោកគ្រូ អ្នកគ្រូចំនួន ៥៧នាក់
- ផ្តល់របាយការណ៍ស្តីពីលទ្ធផលការងារអធិការកិច្ចសាលារៀន ដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងសាលារៀនគោលដៅ ចំនួន ២៩សាលា
- បានបូកសរុបរបាយការណ៍ស្តីពីលទ្ធផល នៃការធ្វើអធិការកិច្ចតាមការកំណត់ជូនក្រសួងអប់រំ យុវជន និងកីឡា ចំនួន ២លើក

**កំណែទម្រង់ទី ៦ ៖ វង្វាយតម្លៃលទ្ធផលសិក្សា**

- បានចូលរួមសហការអនុវត្តតេស្តសាកល្បងថ្នាក់ជាតិនៅតាមអនុវិទ្យាល័យគោលដៅ សម្រាប់ថ្នាក់ទី៨ លើមុខវិទ្យាគណិតវិទ្យា រូបវិទ្យា និងភាសាខ្មែរ ចំនួន ៥សាលា
- ទទួលបានប័ណ្ណព័ត៌មានលទ្ធផលសិក្សាក្រោយអនុវត្តតេស្តវង្វាយតម្លៃសិស្សស្តង់ដារថ្នាក់ជាតិ កម្រិតបឋមថ្នាក់ទី៦សម្រាប់ផ្សព្វផ្សាយជូនគ្រប់សាលាបឋមសិក្សា
- បានចូលរួមសហការអនុវត្តតេស្តថ្នាក់ជាតិនៅតាមអនុវិទ្យាល័យគោលដៅ សម្រាប់ថ្នាក់ទី៨ លើមុខវិទ្យាគណិតវិទ្យា រូបវិទ្យា និងភាសាខ្មែរ ចំនួន ១១សាលា
- ប្រជុំផ្សព្វផ្សាយ និងពិគ្រោះយោបល់លទ្ធផលតេស្តវង្វាយតម្លៃសិស្ស ថ្នាក់ជាតិ ថ្នាក់ទី ៦ ចំនួន ៤៥នាក់
- ចូលរួមសហការ ជាមួយក្រសួងអប់រំ យុវជន និងកីឡាចុះធ្វើតេស្តវង្វាយតម្លៃសិស្ស កម្រិតអន្តរជាតិ សម្រាប់ការអភិវឌ្ឍនៅតាមសាលារៀនគោលដៅចំនួន ៤

**កំណែទម្រង់ទី ៧ ៖ កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ**

- ប្រជុំផ្សព្វផ្សាយនូវសេចក្តីណែនាំ ការងារបច្ចេកទេស និងលិខិតបទដ្ឋាននានា ទាក់ទងនិងការងារប្រឡងសញ្ញាបត្រទាំងពីរកម្រិត ជូនដល់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន
- បានរៀបចំការប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ខេត្ត
- បានចុះពិនិត្យតាមដានការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
- លទ្ធផលការប្រឡងមធ្យមសិក្សាទុតិយភូមិសម័យប្រឡង៖ ២១ សីហា ២០១៧
    - សិស្សប្រឡងជាប់សរុប ២,០៣៣នាក់ ស្រី១,១០០ នាក់ ស្មើនឹង ៦៥.១៤ភាគរយ
    - និទ្ទេសA : ០៧ នាក់ ស្រី ០៤ នាក់ , និទ្ទេស B : ៧១នាក់ ស្រី ៤៣នាក់, និទ្ទេស C : ១៥៥ នាក់ ស្រី ៩០ នាក់, និទ្ទេស D : ២៤៥ នាក់ ស្រី ១២០នាក់ និងនិទ្ទេស E : ១,៥៥៥ នាក់ ស្រី ៨៤៣ នាក់
- លទ្ធផលការប្រឡងមធ្យមសិក្សាបឋមភូមិសម័យប្រឡង៖ ០៧ សីហា ២០១៧
    - សិស្សប្រឡងជាប់សរុប ៥,៦២០នាក់ ស្រី៣,២៦០នាក់ ស្មើនឹង ៩២ភាគរយ
    - និទ្ទេសល្អ : ៧៨២នាក់ ស្រី ៥៥៣នាក់ និទ្ទេសល្អបង្គួរ : ២,១១៦នាក់ ស្រី ១,៣១២នាក់ និទ្ទេស មធ្យម : ២,៧១៨នាក់ ស្រី ១,៣៩៣នាក់
- សិស្សពូកែប្រឡងជាប់ទូទាំងប្រទេសថ្នាក់ទី៩ បានចំនួន ០១ នាក់ ស្រី ០០ នាក់ ក្នុងនោះចំណាត់ថ្នាក់ជ័យលាភីលេខ១០ ផ្នែករូបវិទ្យាថ្នាក់ទី៩ ចំនួន ០១នាក់ ស្រី ០០នាក់ ។

**កំណែទម្រង់ទី ១១ ៖ ការលើកកម្ពស់វិស័យកីឡា**

- ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា ពីរាជរដ្ឋាភិបាល ដល់ក្រុង/ស្រុកទាំង៧
- ការផ្តល់ប្រាក់រង្វាន់ដល់ជ័យលាភីពីការប្រកួតជើងឯកថ្នាក់ខេត្តដល់ក្រុង/ស្រុកដែលទទួលបានជ័យលាភី
- ស្នើសុំដីសម្រាប់សាងសង់កីឡដ្ឋានខេត្តទៅសាលាខេត្ត រួមមាន៖ ទីលានអត្តពលកម្ម ទីលានបាល់ទាត់ បាល់ទះ បាល់បោះ ប៉េតង់ប៊ូល ភ្លើងបំភ្លឺទីលានបាល់ទាត់ ប្រព័ន្ធបង្ហូរទឹក បំពាក់កៅអី របងការពារសុវត្ថិភាព និងសាលដំបូលទូក។
- បានអនុវត្តការកែសម្រួលគោលការណ៍ចំណាយស្តី ពីការប្រកួតកីឡាប្រចាំឆ្នាំគ្រប់ប្រភេទ
- រៀបចំហ្វឹកហាត់ក្រុមកីឡា ៦ ប្រភេទកីឡា ត្រៀមចូលរួមប្រកួតថ្នាក់ជាតិ និងកីឡាជាតិ
- ត្រៀមចូលរួមប្រកួតល្បែងកីឡាជាតិ ដោយប្រព្រឹត្តទៅរៀងរាល់ពីរឆ្នាំម្តង ឱ្យបានបួនដង គិតចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ ២០២៣ តាមការអនុញ្ញាតជាគោលការណ៍របស់រាជរដ្ឋាភិបាល លេខ១៣០ សជណ.អវ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦។

**កំណែទម្រង់ទី ១២ ៖ ការអនុវត្តផែនការ សកម្មភាពគោលនយោបាយយុវជន**

- ធ្វើសំណើររៀបចំគណៈកម្មការក្រុមប្រឹក្សាដើម្បីអភិវឌ្ឍន៍យុវជនកម្ពុជាខេត្តត្បូងឃ្មុំ
- រៀបផែនការ និងអនុវត្តសកម្មភាពប្រចាំឆ្នាំដែលបម្រើដល់ការអភិវឌ្ឍជំនាញទន់ អប់រំស្មារតី ចូលរួមកិច្ចការសង្គម ការចេះចែករំលែកបទពិសោធន៍ ការចេះរួបរួម និងរៀនរស់នៅជាមួយគ្នា ការចេះស្រលាញ់ ថែរក្សា និងការពារនូវសម្បត្តិវប្បធម៌ ទំនៀមទំលាប់ ប្រពៃណីរបស់ជាតិ និងការត្រៀមខ្លួនក្នុងការជ្រើសរើសជំនាញវិជ្ជាជីវៈសមស្របតាមសមត្ថភាពចំណេះដឹង និងទេពកោសល្យរបស់ពួកគេ
- បង្កើតកម្មវិធីទស្សនកិច្ចសិក្សារៀនសូត្រ ថ្នាក់ខេត្តដើម្បីពង្រឹងសមត្ថភាពជំនាញទន់បន្ថែមដល់យុវជន

- លើកកម្ពស់ការងារស្ម័គ្រចិត្តទាំងក្នុងសាលា និងសហគមន៍ តាមរយៈការពង្រឹងសកម្មភាពក្រុមប្រឹក្សាកុមារ និងយុវជន និងការពង្រឹង ពង្រីករចនាសម្ព័ន្ធយុវជនស្ម័គ្រចិត្តកាយរឹទ្ធិ និងកាកបាតក្រហម
- រៀបចំ និងបានអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់យុវជនក្រៅសាលា។

# លទ្ធផល
# តាមអនុវិស័យ

# ២.២-លទ្ធផលតាមអនុវិស័យ

## ២.២.១- អនុវិស័យការអប់រំកុមារតូច

### ក.លទ្ធផលសម្រេចបាន

#### ក.១. ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា ២០១៧-២០១៨ នេះសាលាមត្តេយ្យសិក្សារដ្ឋមានចំនួន ២១៩កន្លែង ក្នុងនោះសាលាមត្តេយ្យសិក្សាដាច់ដោយឡែកមានចំនួន ៤កន្លែង មត្តេយ្យសិក្សាឯកជនមានចំនួន ០៧កន្លែង មត្តេយ្យសិក្សាសហគមន៍មាន ១៤៣កន្លែង និងមានកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះមាន ១ស្រុក ២ឃុំ ៣៨ភូមិ បើធៀបជាមួយឆ្នាំសិក្សា ២០១៦-២០១៧ មត្តេយ្យសិក្សារដ្ឋកើន ១៧កន្លែង មត្តេយ្យសិក្សាឯកជនកើន ១កន្លែង មត្តេយ្យសិក្សាសហគមន៍ថយ ២៤កន្លែង និងកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះថយចំនួន ២ស្រុក ២២ឃុំ ១៥៧ភូមិ (អង្គការsave the children កាត់បន្ថយចំនួនភូមិគោលដៅ)។

ថ្នាក់មត្តេយ្យសិក្សាគ្រប់សេវាមានចំនួន ៥៩៥ថ្នាក់ ក្នុងនោះថ្នាក់មត្តេយ្យសិក្សារដ្ឋមានចំនួន ៤៣០ថ្នាក់ មត្តេយ្យសិក្សាឯកជនមានចំនួន ១៧ថ្នាក់ មត្តេយ្យសិក្សាសហគមន៍មានចំនួន ១៤៨ថ្នាក់ ធៀបឆ្នាំ២០១៦-២០១៧ ថ្នាក់មត្តេយ្យសិក្សារដ្ឋកើន ២៣ថ្នាក់ មត្តេយ្យសិក្សាឯកជនកើន ១ថ្នាក់ មត្តេយ្យសិក្សាសហគមន៍ថយ ២៥ថ្នាក់ ។

កុមារអាយុពី ៣ ដល់ ក្រោម ៦ ឆ្នាំ បានទទួលសេវាអប់រំ គ្រប់រូបភាពមាន ១៧,១៣៥នាក់ ស្មើនឹង ៤០.៩៤ ភាគរយ ស្រី ៨,៥៩៦នាក់ ស្មើនឹង ៤០ ភាគរយ នៃចំនួនប្រជាជន ៣ ដល់ក្រោម ៦ឆ្នាំ ។

ជាលទ្ធផល ការពង្រីកសេវាអប់រំកុមារតូច នៅពុំទាន់ឆ្លើយតបទៅនឹងចំណុចដៅក្នុងឆ្នាំសិក្សា ២០១៧-២០១៨ នៅឡើយ មូលហេតុការពង្រីកសេវាអប់រំកុមារតូចគ្រប់សេវានៅក្នុងខេត្តនៅមានកម្រិត ខ្វះបុគ្គលិក ខ្វះថ្នាក់ ខ្វះសម្ភារ និងថវិកាគាំទ្រសេវាទាំង៤។

##### ក.១.១. មត្តេយ្យសិក្សារដ្ឋ

សាលាមត្តេយ្យសិក្សារដ្ឋ ២១៩កន្លែងក្នុងនោះមានសាលាមត្តេយ្យសិក្សាដាច់ដោយឡែក៤កន្លែងមាន២០ថ្នាក់ មត្តេយ្យសិក្សាក្នុងបឋមមាន ២១៥កន្លែង មាន ៤១០ថ្នាក់។ បុគ្គលិកអប់រំមត្តេយ្យសិក្សារដ្ឋ ៣៨៨ នាក់ ស្រី ៣៥៨ នាក់ធៀបជាមួយឆ្នាំសិក្សា២០១៦-២០១៧ បុគ្គលិកកើនចំនួន ៣៧ នាក់ ស្រី ៣៦ នាក់ ។

កុមារអាយុ ៣ ឆ្នាំ បានទទួលសេវាអប់រំមត្តេយ្យសិក្សារដ្ឋមាន ៥៩៩នាក់ ស្រី ២៨៣ នាក់ កុមារអាយុ ៤ ឆ្នាំ បានទទួលសេវាអប់រំមត្តេយ្យសិក្សារដ្ឋមាន ៤,១៥៨ នាក់ ស្រី ២,០៥៤នាក់ កុមារអាយុ ៥ ឆ្នាំ បានទទួលសេវាអប់រំមត្តេយ្យសិក្សារដ្ឋមាន ៨,១៤៧ នាក់ ស្រី ៤,០៧៣ នាក់ ធៀបជាមួយឆ្នាំសិក្សា ២០១៦-២០១៧ កុមារអាយុ៣ឆ្នាំកើនចំនួន ១០២នាក់ ស្រី៣៨នាក់ កុមារអាយុ៤ឆ្នាំកើនចំនួន ៦៤៦ នាក់ ស្រី១៨២នាក់ កុមារអាយុ៥ឆ្នាំកើនចំនួន ១,១១២នាក់ ស្រី៤៩១នាក់។

##### ក.១.២. មត្តេយ្យសិក្សាឯកជន

សាលាមត្តេយ្យសិក្សាឯកជនមាន ៧កន្លែង មាន១៧ថ្នាក់ បុគ្គលិកបង្រៀនមត្តេយ្យសិក្សាឯកជនមាន ១៥នាក់ ស្រី ១៤នាក់ ។

កុមារអាយុ ៣ ឆ្នាំ បានទទួលសេវាអប់រំមត្តេយ្យសិក្សាឯកជនមាន ៨៥នាក់ ស្រី ៣៦ នាក់ កុមារអាយុ ៤ ឆ្នាំ បានទទួលសេវាអប់រំមត្តេយ្យសិក្សាឯកជនមាន ១៥៣នាក់ ស្រី៧១នាក់ កុមារអាយុ ៥ ឆ្នាំ បានទទួលសេវាអប់រំមត្តេយ្យសិក្សាឯកជនមាន ១៧០ នាក់ ស្រី ៨៨នាក់ ធៀបជាមួយឆ្នាំសិក្សា ២០១៦-២០១៧ កុមារអាយុ៣ឆ្នាំកើនចំនួន ១៨នាក់ ស្រី១៣នាក់ កុមារអាយុ៤ឆ្នាំថយចំនួន ៨នាក់ ស្រី៥នាក់ កុមារអាយុ៥ឆ្នាំថយចំនួន ៨៨នាក់ ស្រី៥៦នាក់ ។

### ក.១.៣. មត្តេយ្យសិក្សាសហគមន៍

មត្តេយ្យសិក្សាសហគមន៍មាន ១៤៣ កន្លែងស្មើនឹង ១៤៨ថ្នាក់ គ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍មានចំនួន ១៤៧នាក់ ស្រី ១៤៥ នាក់ ធៀបឆ្នាំសិក្សា ២០១៦-២០១៧ គ្រូបង្រៀនថយចំនួន ២៤នាក់ ស្រី២១នាក់។

កុមារអាយុ ៣ឆ្នាំ បានទទួលសេវាអប់រំមត្តេយ្យសិក្សាសហគមន៍មាន ១,០០០នាក់ ស្រី ៥១២នាក់ កុមារអាយុ ៤ ឆ្នាំ បានទទួលសេវាអប់រំមត្តេយ្យសិក្សាសហគមន៍មាន ១,២៧៨នាក់ ស្រី ៦៦២នាក់ កុមារអាយុ ៥ ឆ្នាំ បានទទួលសេវាអប់រំមត្តេយ្យសិក្សាសហគមន៍មាន ១,០៤៨នាក់ ស្រី ៥១៥នាក់ ធៀបជាមួយឆ្នាំសិក្សា ២០១៦-២០១៧ កុមារអាយុ៣ឆ្នាំថយចំនួន ២០០នាក់ ស្រី១២៣នាក់ កុមារអាយុ៤ឆ្នាំថយចំនួន ៥៥នាក់ ស្រី៤នាក់ កុមារអាយុ៥ឆ្នាំថយចំនួន ១៣៩នាក់ ស្រី៩៤នាក់។

### ក.១.៤. ការអប់រំកុមារតូចតាមខ្នងផ្ទះ

ការអប់រំកុមារតូចតាមខ្នងផ្ទះមានម្តាយបង្គោលសរុប ៣៤នាក់ ប្រធានក្រុមម្តាយ ៤៣នាក់ សមាជិកម្តាយ ៦៨០នាក់ ភូមិដែលបានអនុវត្តកម្មវិធីអប់រំកុមារតូចតាមខ្នងផ្ទះមាន ៣៤ភូមិ ស្ថិតក្នុងឃុំចំនួន ២ ស្ថិតក្នុងស្រុកមេមត់។ បើធៀបនឹងឆ្នាំសិក្សា ២០១៦-២០១៧ម្តាយបង្គោលថយចំនួន១៥៨នាក់ ប្រធានក្រុមម្តាយថយចំនួន៨៦០នាក់ សមាជិកម្តាយថយចំនួន៣,២០០នាក់។

កុមារអាយុពី ០ ដល់ ក្រោម៣ ឆ្នាំ បានទទួលសេវាអប់រំកុមារតូចតាមខ្នងផ្ទះចំនួន ៤៨៧ នាក់ ស្រី ២៥៩ នាក់ កុមារអាយុ ៣ ឆ្នាំបានទទួលបានសេវាអប់រំកុមារតូចតាមខ្នងផ្ទះមាន ១៧៨ នាក់ ស្រី ១០៦នាក់ កុមារអាយុ ៤ ឆ្នាំបានទទួលបានសេវាអប់រំកុមារតូចតាមខ្នងផ្ទះមាន ១៦៨ នាក់ ស្រី៩៨នាក់ កុមារអាយុ ៥ ឆ្នាំបានទទួលបានសេវាអប់រំកុមារតូចតាមខ្នងផ្ទះមាន ១៥១នាក់ ស្រី ៩៨នាក់ ធៀបនឹងឆ្នាំសិក្សា ២០១៦-២០១៧ កុមាអាយុ០ដល់ក្រោម៣ឆ្នាំថយចំនួន ២,៨៨១នាក់ ស្រី១,៥១១នាក់ កុមារអាយុ៣ឆ្នាំថយចំនួន ១,១១៤នាក់ ស្រី៥៦៧នាក់ កុមារអាយុ៤ឆ្នាំថយចំនួន ១,១៣០នាក់ ស្រី៥៦៨នាក់ កុមារអាយុ៥ឆ្នាំថយចំនួន ១,៣០៩នាក់ ស្រី៦៩០នាក់។

#### ការផ្តល់ថវិកាដំណើរការ និងថវិកាកែលម្អសាលារៀន

គ្រប់សាលាមត្តេយ្យសិក្សាសាធារណៈបានទទួលថវិកាដំណើរការសាលារៀន និងគាំទ្រសម្រាប់កុមារចំនួន ៨ជុំតាមរយៈការរៀបចំផែនការប្រចាំឆ្នាំ ដោយមានការចូលរួមពីគណៈកម្មការទ្រទ្រង់សាលារៀន និង អង្គការដៃគូពាក់ព័ន្ធ។ សាលារៀននីមួយៗកាន់តែមានគណនេយ្យភាពចំពោះចំណូលចំណាយដោយមានបិទផ្សាយតារាងតម្លាភាព ប្រការនេះជួយឱ្យសាលារៀនកាន់តែមានលទ្ធភាពប្រមូលកុមារចូលរៀន និងមានការចូលរួមពីសហគមន៍ កាន់តែប្រសើរឡើង ។

- **ការគាំទ្ររបស់អង្គការវឌ្ឍនភាព(WP)**

- គាំទ្រថវិកាលើកាធ្វើបបរខាប់គ្រប់គ្រឿងដល់កុមារចំនួន ៣,៣២៦ ស្រី១,៦៨៩នាក់ ក្នុងស្រុកតំបែរ និងពញាក្រែក
- សហការជាមួយមណ្ឌលសុខភាពចំនួន ០៩ ក្នុងការចុះវាស់ថ្លឹងតាមដានការលូតលាស់របស់កុមារអាយុ០ឆ្នាំដល់ក្រោម៦ឆ្នាំ ក្នុងស្រុកតំបែរ និងពញាក្រែក
- សហការជាមួយមណ្ឌលសុខភាពស្រុកប្រតិបត្តិចំនួន ០៩ ដើម្បីកែលម្អស្ថានភាពសុខភាពកុមារដែលខ្វះអាហារូបត្ថម្ភក្នុងស្រុកតំបែរ និងពញាក្រែក
- សហការជាមួយមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ ក្នុងការបណ្តុះបណ្តាលដល់បុគ្គលិកមណ្ឌលសុខភាពក្នុងតំបន់គោលដៅចំនួន៩មណ្ឌលសុខភាព
- គាំទ្រ និងសម្របសម្រួលឲ្យកុមារមានទម្លាប់អនាម័យនិងចេះអនុវត្តនូវអនាម័យបន្ទោបង់ក្នុងបង្គន់

- ផ្តល់ធុងចម្រោះទឹក សម្រាប់កុមារញុំាគ្រប់ថ្នាក់មត្តេយ្យសិក្សាសហគមន៍ទាំងអស់ ក្នុងស្រុកតំបែរ និងពញាក្រែក
- ជួសជុលកែលម្អថ្នាក់មត្តេយ្យចំនួន ៣៧កន្លែង
- គាំទ្រ និងសហការជាមួយក្រុមមាតាបិតាក្នុងការបង្កើត និងសាងសង់ខ្ទមសម្រាប់កុមារលេងកំសាន្ត(តុបតែង និងបំពាក់សម្ភារសម្រាប់កុមារលេង)
- គាំទ្រប្រាក់ឧបត្ថម្ភប្រចាំខែដល់គ្រូមត្តេយ្យសិក្សាសហគមន៍ចំនួន ១២៧នាក់
- គាំទ្រវាល់សម្ភារអនាម័យ សម្ភារបង្រៀន និងរៀនដល់ថ្នាក់មត្តេយ្យសហគមន៍ចំនួន ១២៧កន្លែង
- គាំទ្រ និងសហការជាមួយក្រុមប្រឹក្សាឃុំ កិច្ចការនារីឃុំ គណៈកម្មការទ្រទ្រង់សាលាមត្តេយ្យ និងក្រុមមាតាបិតាក្នុងការរៀបចំល្បែងក្រៅថ្នាក់ តុបតែងក្នុងថ្នាក់មត្តេយ្យទាំង ១២៧ថ្នាក់
- គាំទ្រអាហារពេលព្រឹករបស់កុមារថ្នាក់មត្តេយ្យសិក្សា ចំនួន ៤១ថ្នាក់ ដែលមានកុមារចំនួន ១,០៥៩នាក់ ស្រី៥២៩ នាក់ ។

- **សាសនាកាតូលិក**

បានផ្តល់ថវិកាប្រចាំខែដល់គ្រូមត្តេយ្យសិក្សាសហគមន៍ចំនួន ១១នាក់ ក្នុងស្រុកក្រូចឆ្មារចំនួន ២នាក់ និងនៅក្នុងស្រុកអូររាំងឪចំនួន ៩នាក់ ។

- **អង្គការសមាគមប្រទេសជប៉ុន**

សាងសង់អណ្តូងចំនួន ០១ នៅក្នុងបរិវេណសាលាបឋមសិក្សាក្រែក សម្រាប់ឱ្យសាលាមត្តេយ្យធនធានប្រើប្រាស់។

- **អង្គការ Save the children**

បានរៀបចំមណ្ឌលអានចំនួន ២កន្លែង នៅក្នុងឃុំត្រមូងភូមិសំបូរ ១កន្លែង និងនៅក្នុងឃុំដារភូមិដារលិច ១កន្លែង។

- **អង្គការខេមរា**

បានជួសជុលបន្ទប់មត្តេយ្យសិក្សានៅសាលាបឋមសិក្សាទួលពិសិដ្ឋនៅឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំអស់ថវិកាចំនួន ១,៦៤៩ ដុល្លារ

**លទ្ធផលនៃការសិក្សា ៖**

កុមារអាយុ ៥ ឆ្នាំ បានបញ្ចប់ការសិក្សាថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់ចំនួន ៨,៧១៩នាក់ ស្រី៤,៤៣៩នាក់ ។ កុមារអាយុ ៥ ឆ្នាំ ឆ្លងកាត់សេវាអប់រំកុមារតូចគ្រប់រូបភាព ដែលបានចូលរៀនថ្នាក់ទី១ នៃសាលាបឋមសិក្សាបាន ៥៧ ភាគរយ ។

**ការកែលម្អបរិស្ថានសាលា និងសម្ភារសិក្សា**

សាលាមត្តេយ្យសិក្សាដាច់ដោយឡែក និងមត្តេយ្យសិក្សាសហគមន៍ នៅតាមក្រុង/ស្រុកមួយចំនួនបានជួសជុល កែលម្អបរិស្ថានសិក្សា មានសម្ភារសិក្សា សម្ភារដាក់តាំងតាមជ្រុង និងដាក់តាំងក្នុងលំហស្របតាមគរុកោសល្យថ្នាក់មត្តេយ្យសិក្សា ។

**ការអនុវត្តម៉ោង និងកម្មវិធីសិក្សា**

ការអនុវត្តកម្មវិធីសិក្សានៅសាលារៀន និងថ្នាក់រៀនមត្តេយ្យសិក្សាដាច់ដោយឡែកបានអនុវត្តចប់ ១០០ភាគរយ ដោយឡែកថ្នាក់មត្តេយ្យសិក្សាក្នុងបឋមពុំបានអនុវត្តចប់ ១០០ភាគរយទេ (ប្រើប្រាស់គ្រូបឋម) ការអនុវត្តកម្មវិធីសិក្សានៅមណ្ឌល ឬថ្នាក់មត្តេយ្យសិក្សាសហគមន៍មានភាពប្រសើរឡើងគឺអនុវត្តបាន ៧២ ភាគរយ ធៀបទៅនឹងកម្មវិធីសិក្សាប្រចាំឆ្នាំ ។

- **ផ្នែកផែនការនិងគ្រប់គ្រងជំនួយ មន្ទីរអប់រំ យុវជន និងកីឡា**
  - **ផ្នែកសំណង់** ៖ គិតក្នុងឆ្នាំសិក្សា២០១៦-២០១៧ មន្ទីរអប់រំយុវជន និងកីឡាខេត្តបានទទួលនូវសមិទ្ធផលសំណង់អាគារដែលជាអំណោយឧបត្ថម្ភដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ស្រុកត្បូងឃ្មុំ ដោយបានផ្តល់ជូននូវសាលាមត្តេយ្យសិក្សាចំនួន ១ ខ្នង ស្មើនឹង ៣ បន្ទប់ ដល់សាលាមត្តេយ្យសិក្សាពាមជីលាំង ។
- **ការងារពិនិត្យតាមដាន**
  - ចុះជួយរៀបចំតុបតែងថ្នាក់មត្តេយ្យស្តង់ដារអប្បរមាបានចំនួន ៣៩សាលា លើផ្នែកលំហ រៀបចំជ្រុងទាំង៥ ផលិតសម្ភារឧបទេស និងការងារបច្ចេកទេស
  - តាមដានការអនុវត្តធ្វើតេស្តកុមារអាយុ៥ឆ្នាំបាន ៧៥សាលា
  - តាមដានលើការអនុវត្តការងារបច្ចេកទេសរៀន និងបង្រៀនថ្នាក់មត្តេយ្យសិក្សារដ្ឋចំនួន ១៣៧សាលា និងថ្នាក់មត្តេយ្យសិក្សាសហគមន៍ ៣១ថ្នាក់ (គាំទ្រដោយអង្គការវឌ្ឍនភាព ១៦ថ្នាក់ និងUnicef ១៥ថ្នាក់)។

## ក.២ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

- **ការអភិវឌ្ឍសមត្ថភាពក្នុងខេត្ត**

**មន្ទីរអប់រំ យុវជន និងកីឡាបាន៖**

- បំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សាសហគមន៍ចំនួន ២៤នាក់លើការងារបច្ចេកទេសបង្រៀន ថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងការរៀបចំថ្នាក់ចំនួន ២ថ្ងៃ
- ដឹកនាំប្រជុំបូកសរុបការងារ M&E ជាមួយមន្ត្រីអប់រំកុមារតូចទាំង៧ក្រុង/ស្រុកចំនួន ៣ដងក្នុង១ឆ្នាំ
- បំប៉នសមត្ថភាពគ្រូមត្តេយ្យសិក្សារដ្ឋ លើការរៀបចំថ្នាក់មត្តេយ្យ និងការធ្វើតេស្តកុមារអាយុ៥ឆ្នាំមានស្រុកអូររាំងឪ និងស្រុកពញាក្រែក អ្នកចូលរួមចំនួន ៤៧នាក់ ស្រី ៤៣នាក់ ចំនួន២ថ្ងៃ
- មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ សហការជាមួយអង្គការវឌ្ឍនភាពក្នុងការបំប៉នសមត្ថភាពបច្ចេកទេសគ្រូ មត្តេយ្យសិក្សាសហគមន៍ សម្របសម្រួលការប្រជុំប្រចាំត្រីមាស និងចុះពិនិត្យកែលម្អបច្ចេកទេសថ្នាក់មត្តេយ្យសហគមន៍ គម្រោងBMZ គ្រូមត្តេយ្យសិក្សាសហគមន៍ ៤១នាក់ និងម្តាយបង្គោលចំនួន ៤១នាក់ គម្រោងJNO គ្រូមត្តេយ្យសិក្សាសហគមន៍ចំនួន ៨៧នាក់។

**អង្គការវឌ្ឍនភាព(WP)បាន៖**

- គាំទ្រ និងសម្របសម្រួលក្រុមមាតាបិតាក្នុងតំបន់គោលដៅចំនួន ៦០០ក្រុមតូច ដែលមានសមាជិក សរុប ៣,១៧៥ ស្រី៣,០០៤នាក់ ប្រជុំប្រចាំខែទាក់ទងនឹងសារគន្លឹះទាំង១២ នៃការថែទាំ សុខភាពគ្រួសារ
- គាំទ្រ និងសម្របសម្រួលប្រជុំប្រចាំត្រីមាសរវាងកិច្ចការនារីឃុំ និងប្រធានក្រុមមាតាបិតា
- សហការជាមួយមន្ទីរអភិវឌ្ឍនជនបទក្នុងការថែរក្សា និងជំរុញដល់ក្រុមគោលដៅក្នុងការអនុវត្ត អនាម័យ និងទឹកស្អាត ជាពិសេសសុវត្ថិភាពទឹកញ៉ាំ តាមរយៈការប្រជុំប្រចាំខែរបស់ក្រុមមាតាបិតា
- គាំទ្រ និងសម្របសម្រួលដល់គណៈកម្មការទ្រទ្រង់សាលាមត្តេយ្យសិក្សា សហគមន៍ឲ្យមានការប្រជុំប្រចាំត្រីមាស
- គាំទ្រ និងសហការជាមួយការិយាល័យអប់រំស្រុក និងក្រុមប្រឹក្សាឃុំរៀបចំក្បួនដង្ហែយុទ្ធនាការប្រមូលកុមារចុះឈ្មោះចូលរៀនក្នុងឃុំទាំង១២ នៃស្រុកតំបែរ និងពញាក្រែក។

**អង្គការ Save the Children បាន៖**

- ប្រជុំពិគ្រោះយោបល់ថ្នាក់ឃុំចំនួន ២ដង ដែលមានអ្នកចូលរួម ៤៥នាក់ ស្រី១៥នាក់
- បណ្តុះបណ្តាលដល់អ្នកសម្របសម្រួលកិច្ចប្រជុំភូមិ ២ដង អ្នកចូលរួម ៣៨នាក់ ស្រី២៥នាក់
- ប្រជុំក្រុមឪពុកម្តាយចំនួន ៣៤ភូមិ បានចំនួន ៨ដង អ្នកចូលរួមពីក្រុមឪពុកម្តាយចំនួន ៤,២៦៤នាក់ ស្រី ៤,១០១នាក់
- ប្រជុំឆ្លុះបញ្ចាំងជាមួយក្រុមឪពុកម្តាយបង្គោល និងប្រធានក្រុមឪពុកម្តាយចំនួន ១ដង អ្នកចូលរួមចំនួន ៥០នាក់ ស្រី ៥០នាក់
- ចុះសួរសុខទុក្ខទៅដល់គ្រួសារចំនួន ៥០នៅក្នុងឃុំគោលដៅចំនួន ២ដង
- ចុះត្រួតពិនិត្យមណ្ឌលអាន និងចុះជួយដល់អ្នកសម្របសម្រួលកិច្ចប្រជុំភូមិទាំង ៣៤ភូមិ
- បំប៉ នសមត្ថភាពគ្រូបង្គោលស្តីពីរបៀបនៃការដឹកនាំប្រជុំភូមិចំនួន ៨នាក់ ស្រី ៦នាក់ ។

## ខ.វឌ្ឍនភាពនៃសូចនាករផលសម្រេច

### ការវិភាគវឌ្ឍនភាពសូចនាករផលសម្រេច

| ការអប់រំកុមារតូច | ជាក់ស្តែងឆ្នាំ 2015-2016 | ចំណុចដៅឆ្នាំ 2016-2017 | ជាក់ស្តែងឆ្នាំ 2016-2017 | ស្ថានភាព |
|---|---|---|---|---|
| - ភាគរយកុមារអាយុ 5 ឆ្នាំទទួលបានការអប់រំគ្រប់រូបភាព | 58.21% | 65% | 59% | ➡ |
| - ភាគរយកុមារអាយុ 4 ឆ្នាំទទួលបានការអប់រំគ្រប់រូបភាព | 37.86% | 42% | 40.96% | ➡ |
| - ភាគរយកុមារអាយុ 3 ឆ្នាំទទួលបានការអប់រំគ្រប់រូបភាព | 16.14% | 30% | 17.12% | ➡ |
| - ភាគរយកុមារតូចដែលគោរពតាមស្តង់ដារគុណភាព | 30% | 32% | 31% | ➡ |
| - ភាគរយកុមារតូចដែលអនុវត្តបានតេស្តទៀងទាត់ដើម្បីវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ ជាទៀងទាត់ | NA | 70% | 46.45% | ⬇ |
| - ភាគរយកុមារតូចក្នុងសេវាគាំពារនិងអភិវឌ្ឍកុមារតូច ដែលមានស្ថានភាពអាហារូបត្ថម្ភ | NA | 50% | 10.45% | ⬇ |
| -ភាគរយកុមារតូចនៅតាមសាលាមត្តេយ្យសិក្សាសាធារណៈ: ទទួលបានថ្នាំទម្លាក់ព្រូន | 95% | 96% | 49.96% | ⬇ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

## គ.បញ្ហាប្រឈម ៖

ទន្ទឹមនឹងការអនុវត្តសម្រេចបានលទ្ធផលខាងលើ នៅមានបញ្ហាប្រឈមមួយចំនួនចាំបាច់ ត្រូវមានការរួមគ្នាខិតខំប្រឹងប្រែងដើម្បីរកដំណោះស្រាយដែលបញ្ហាប្រឈមទាំងនោះរួមមាន៖

- ថ្នាក់មត្តេយ្យសិក្សាភាគច្រើនខ្ចីថ្នាក់បឋមសិក្សាធ្វើឱ្យគ្រូមានការលំបាកក្នុងការរៀបចំថ្នាក់ឱ្យបានតាមស្តង់ដារ
- ខ្វះល្បែងក្រៅថ្នាក់ស្ទើរគ្រប់សាលា
- គ្រូបឋម និងគ្រូកិច្ចសន្យាដែលបង្រៀនថ្នាក់មត្តេយ្យសិក្សាពុំបានបំប៉នបច្ចេកទេសមត្តេយ្យសិក្សា

- ថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន ៦៦កន្លែង កំពុងដំណើរការក្រោមផ្ទះប្រជាជន
- ខ្វះគ្រូក្របខណ្ឌមត្តេយ្យសិក្សា
- ថ្នាក់មត្តេយ្យសិក្សាសហគមន៍នៅភូមិជ្រៃតាសូរ ភូមិពុទ្ធា ភូមិស្ពាន ភូមិជាំទ្រៀក ភូមិដងក្ដោង ភូមិត្រពាំងព្រៃ ភូមិជាំធ្លក ភូមិពងទឹក ភូមិធ្លក ភូមិបុស្សរកា និងភូមិអំពាក់ទី២ បានផ្អាកដំណើរការដោយសារគ្មាន ថវិកាគាំទ្រ។

## ២.២.២ ការអប់រំបឋមសិក្សា

### ក.លទ្ធផលសម្រេចបាន

#### ក.១.ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា ២០១៧-២០១៨ សាលាបឋមសិក្សាសាធារណៈមាន ៤០១កើន៣សាលា ធៀបនឹងឆ្នាំសិក្សា ២០១៦-២០១៧ ។ សាលារៀនមិនគ្រប់កម្រិតថ្នាក់ថយចុះ ១សាលា ។ សាលាកុមារមេត្រី ( កម្រិតមធ្យម និង កម្រិតអភិវឌ្ឍ ) ៣១៥ សាលា កើន៦សាលា ។ ថ្នាក់រៀនមាន ៣,២៥៧ កើន៥ថ្នាក់ ស្មើនឹង ០.១៥ភាគរយ បន្ទប់រៀនមាន ៣,២៧១ បន្ទប់ កើន៧៥ បន្ទប់ ស្មើនឹង ២.២៩ភាគរយ ។

សាលាបឋមសិក្សាឯកជន មាន៦សាលា ថយ២សាលា មានទីតាំងនៅស្រុក ពញាក្រែក ក្រុងសួង និងក្រូចឆ្មារ ។ សិស្សបឋមសិក្សា ១១៥,៨៥៦ នាក់ ស្រី ៥៦,៩៩៥ នាក់ ថយពីឆ្នាំចាស់ ១,៩០៥នាក់ សិស្សស្រីថយចុះ ៤១២ នាក់ ។ អត្រាពិតចូលរៀនថ្មីបឋមសិក្សាសរុប ១៦,៩២៥នាក់ ស្រី ៨,៦៨៩ នាក់ ស្មើ នឹង ៩៧.៥០ភាគរយ កើនពីឆ្នាំចាស់០.២០ភាគរយ ។

ប្រការនេះបញ្ជាក់ឱ្យឃើញថា កុមារក្នុងខេត្តកាន់តែទទួលបានការអប់រំប្រកបដោយសមធម៌ និង បរិយាប័ន្ន ។ បុគ្គលិកអប់រំ ៣៣,៨២នាក់ ស្រី ១,៦៩២នាក់ ថយ២០នាក់ ស្រី១២នាក់ គ្រូបង្រៀនពីរវេន ៩១៣ នាក់ ស្រី ៤១៣ នាក់ គ្រូបង្រៀនថ្នាក់គួបពីរកម្រិតថ្នាក់ ៩៥ នាក់ ស្រី ៤៣នាក់ និងគ្រូបង្រៀនថ្នាក់គួបបីកម្រិត ថ្នាក់ ៣ នាក់ ស្រី ១ នាក់ និង គ្រូកិច្ចសន្យា ៣៧៨នាក់ ។

- **ការអនុវត្តកម្មវិធី និង សកម្មភាពនានា**

#### ការផ្ដល់ថវិកាដំណើរការ និងថវិកាកែលម្អសាលារៀន

គ្រប់សាលារៀនបឋមសិក្សាសាធារណៈ បានទទួលថវិកាដំណើរការ និងកម្មវិធីកែលម្អ សាលារៀន ពេញលេញ ។ សាលារៀននីមួយៗមានការរៀបចំផែនការអភិវឌ្ឍប្រចាំឆ្នាំ ដោយមានការចូលរួមពីគណៈកម្មការ ទ្រទ្រង់សាលា ។ សាលារៀននីមួយៗកាន់តែមានគណនេយ្យភាពចំពោះចំណូល ចំណាយដោយមានបិទផ្សាយតារាងតម្លាភាព ។

ប្រការនេះជួយឱ្យសាលារៀនមានលទ្ធភាពប្រមូលកុមារចូលរៀន និងមានការចូលរួមពីសហគមន៍កាន់តែប្រសើរឡើង។

#### កម្មវិធីអាហារូបករណ៍នៅតាមសាលារៀន

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ស្ដីពីការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណោះទូទៅ ហើយក្រសួងក៏បានចេញប្រកាសស្ដីពីការកំណត់លក្ខខណ្ឌ និងនីតិវិធីនៃការផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ នៅ

បឋមសិក្សា និងមធ្យមសិក្សាចំណោះទូទៅផងដែរ ដូច្នេះតាមរយៈការអនុវត្តកម្មវិធីអាហារូបករណ៍បឋមសិក្សា មានសិស្សចំនួន ៨,២៩០ នាក់ ស្រី ៤,៦៤៨ នាក់ នៃសាលាបឋមសិក្សា ចំនួន ២៩៩ សាលា បានទទួលអាហារូបករណ៍ ប្រការនេះបានជួយបង្កើនលទ្ធភាពដល់កុមារដែលមកពីគ្រួសារក្រីក្រឱ្យបានចូលរៀន និងរៀនទៀងទាត់ ក្នុងន័យដើម្បីបង្កើនការចូលរៀននិងកាត់បន្ថយការបោះបង់ការសិក្សា។

- អង្គការជំនួយខ្មែរនៃសតវត្សទី២១ បានផ្ដល់អាហារូបករណ៍ជាសាច់ប្រាក់ដល់សិស្សក្រីក្រចំនួន ២៩ នាក់ក្នុងម្នាក់ទទួលបាន ៣០,០០០រៀល ក្នុង១ខែ រយៈពេល ១២ ខែ និងសម្ភារៈមួយចំនួនទៀត ដូចជាកង់ សម្លៀកបំពាក់ និងផ្ដល់អាហារូបករណ៍ដល់កុមារកំព្រាចំនួន ៣នាក់ បានរៀនរហូតចប់មហាវិទ្យាល័យនៅមណ្ឌលកុមារកំព្រា (ផ្ទះនៃក្ដីសង្ឃឹម) ខេត្តកំពង់ស្ពឺ
- អង្គការខេមរាបានផ្ដល់កង់ចំនួន ១២៥គ្រឿង សម្ភារៈសិក្សា និងសម្លៀកបំពាក់ ៦២៤នាក់ ស្រី៣០២នាក់ ដល់សិស្សក្នុងស្រុកត្បូងឃ្មុំ ។

## ការអប់រំសុខភាព

- បើកវគ្គសិក្ខាសាលាផ្សព្វផ្សាយស្ដីពីគោលការណ៍ណែនាំលក្ខខណ្ឌអប្បបរមាពីទឹកស្អាត និងអនាម័យនៅសាលារៀន ដល់គ្រូទទួលបន្ទុកសុខភាពចំនួន ៦៥ នាក់ ប្រើប្រាស់ ថវិការបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- លោកគ្រូ អ្នកគ្រូបានផ្សព្វផ្សាយ និងបញ្ជ្រាបស្ដីពីសុខភាព អនាម័យ និងអាហារូបត្ថម្ភដល់សិស្សានុសិស្ស បានចំនួន ១,៤៧២ នាក់ ស្រី ៦៨៦ នាក់
- ក្រុមការងារថ្នាក់ខេត្ត-ក្រុង/ស្រុក បានចុះពិនិត្យតាមដានការអនុវត្តសុខភាពសិក្សាតាមសាលារៀនចំនួន ៩៨ សាលា ក្នុង ០៧ ក្រុង/ស្រុក
- អង្គការឆាដាបានបណ្ដុះបណ្ដាលស្ដីពីការបង្កើតអនាម័យរវាងសាលារៀន និងសហគមន៍ និងបានបណ្ដុះបណ្ដាលគ្រូទទួលបន្ទុកសុខភាព មានអ្នកចូលរួម ចំនួន ៤៣ នាក់ ស្រី ១៣ នាក់ នៅស្រុក ០២ គឺតំបែរ និងពញាក្រែក
- ណែនាំពីសុវត្ថិភាពចំណីអាហារតាមរយៈការប្រជុំក្រុមប្រឹក្សាកុមារប្រចាំខែគ្រប់សាលារៀនទាំងអស់
- គ្រប់សាលារៀនសហការជាមួយមណ្ឌលសុខភាព ក្នុងការផ្ដល់ថ្នាំទម្លាក់ព្រូនដល់សិស្ស និងមន្ត្រីអប់រំ ២ដងក្នុង ១ឆ្នាំ
- ពិនិត្យតាមដានប្រចាំត្រីមាស ស្ដីពីការអនុវត្តសកម្មភាពលើកកម្ពស់ សុខភាពតាមសាលារៀន រួមបញ្ចូលទាំងការអប់រំបង្ការជំងឺឆ្លង ការបង្ការគ្រោះថ្នាក់ផ្សេងៗ ការសង្គ្រោះបឋម វិធានការអនាម័យ និងបរិស្ថានសាលារៀនទូទាំងខេត្ត ធ្វើឱ្យសិស្សមានបំណិនទាក់ទងនឹងសុខភាព
- អង្គការស្អាតកម្ពុជាបានជួយឧបត្ថម្ភគាំទ្រ ការសាងសង់បង្គន់អនាម័យ អាងស្តុកទឹក និងកន្លែងសម្រាប់លាងដៃដល់សិស្សានុសិស្សនៅក្នុងស្រុកពញាក្រែក ២០ សាលារៀន ស្រុកតំបែរ ១៥សាលា ស្រុកអូររាំងឪ ៤សាលា និងស្រុកត្បូងឃ្មុំមួយចំនួនទៀត
- អង្គការជិះកង់កម្ពុជាបានជួយព្យាបាលធ្មេញ តាមរយៈការផ្ដល់ថ្នាំដុសធ្មេញ ច្រាស់ និងផ្ដល់ប្រាក់ឧបត្ថម្ភដល់គ្រូចំនួន ៣០ដុល្លា ក្នុងម្នាក់ដើម្បីជួយពិនិត្យលើការអនុវត្តសុខភាព និងផ្ដល់គ្រូបង្រៀនភាសាអង់គ្លេសមួយថ្ងៃពីរម៉ោងក្នុង១សប្ដាហ៍៥ថ្ងៃ ។

### ❖ តារាងសមធម៌នៃការចូលរៀន៖

| សូចនាករ | ធៀបទៅនឹងចំណុចដៅឆ្នាំសិក្សា 2016-2017 | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ជាក់ស្តែង | | | | ចំណុចដៅ | | | | គម្លាត | | | |
| | សរុប | ភ.រ | ស្រី | ភ.រ | សរុប | ភ.រ | ស្រី | ភ.រ | សរុប | ភ.រ | ស្រី | ភ.រ |
| អត្រាពិតចូលរៀនថ្មី | 17,413 | 97.30% | 8,441 | 96.86% | 17,896 | 99% | 8,715 | 99% | 483 | 2.83% | 89 | 2.76% |
| អត្រារួមចូលរៀនថ្មី | 23,286 | 126.80% | 10,767 | 123.57% | 24,256 | 110% | 9,663 | 110% | 2026 | -16.8% | 967 | -13.57% |
| អត្រាពិតនៃការសិក្សា | 102,777 | 95.16% | 51,043 | 96.61% | 107,999 | 100% | 52,834 | 100% | 5,222 | 4.83% | 1,791 | 3.38% |
| អត្រារួមនៃការសិក្សា | 117,761 | 110.82% | 56,183 | 110.59% | 122,707 | 104% | 59,441 | 104% | 4,546 | 4.03% | 3,258 | 5.48% |
| អត្រាឆ្លងភូមិសិក្សា | 13,886 | 91.44% | 7,187 | 92.72% | 14,616 | 95% | 7,565 | 95% | 730 | 3.56% | 378 | 2.28% |

### ❖ តារាងស្ថានភាពនៃវ័យកុមារ និងការចូលរៀន ៖

| វ័យសិក្សា (ឆ្នាំ) | សរុប | ស្រី | បានចូលរៀនបឋមសិក្សា | | ភាគរយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| 6 ឆ្នាំ | 17,896 | 8,715 | 17,413 | 8,441 | 97.30% |
| 6-11 ឆ្នាំ | 107,999 | 52,834 | 102,777 | 51,043 | 95.16% |

ក្នុងឆ្នាំសិក្សា ២០១៦-២០១៧ អត្រាឡើងថ្នាក់នៅបឋមសិក្សា បានកើនដល់ ៩២.២៣ភាគរយ ស្រី ៩១.៣២ភាគរយ និងប្រុស ៩៣.៩៥ភាគរយ ។ អត្រាត្រួតថ្នាក់ថយមកត្រឹម ៧.៥៨ភាគរយ ស្រី ៦.៥៩ ភាគរយ ប្រុស ៨.៩៩ភាគរយ ។ អត្រាបោះបង់ការសិក្សាថយចុះមកត្រឹម ២.៣៨ភាគរយ ស្រី ២.០៩ភាគរយ ប្រុស ២.៨១ភាគរយ ។

### ✚ ការផ្គត់ផ្គង់សៀវភៅសិក្សាគោល និងការអនុវត្តកម្មវិធីសិក្សា

- បានផ្តល់សៀវភៅសិក្សាគោល ស្តង់ដារអំណានភាសាខ្មែរ ថ្នាក់ទី១ ទី២ និងទី៣ សម្រាប់គ្រូចំនួន ១,៣២៦ ក្បាល ចែកជូនដល់ ៧ក្រុង/ស្រុក
- សៀវភៅសិក្សាគោលសម្រាប់សិស្ស 1/1 សម្រាប់ទីប្រជុំជន និង 1/1 សម្រាប់តំបន់ជនបទ
- ការអនុវត្តកម្មវិធីសិក្សាយកតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអនុវត្តបាន ៖
    - ភាសាខ្មែរ ៩៨ ភាគរយ
    - គណិតវិទ្យា ៩៩ ភាគរយ
    - វិទ្យាសាស្ត្រ និង សិក្សាសង្គម ថ្នាក់ទី ១ ដល់ ថ្នាក់ទី៣ បាន ៩៧ភាគរយ
    - វិទ្យាសាស្ត្រ និងសិក្សាសង្គម ថ្នាក់ទី៤ ដល់ ថ្នាក់ទី៦ បាន ៩៨ភាគរយ

## ការងារបណ្ណាល័យ:

- អនុវត្តស្តង់ដារបណ្ណាល័យបឋមសិក្សានៅតាមសាលារៀនទូទាំងខេត្ត ២២៥ បណ្ណាល័យ
- ចុះតាមដានការអនុវត្តស្តង់ដារបណ្ណាល័យបឋមសិក្សា ៧ក្រុង/ស្រុក ចំនួន ២៨ សាលា
- ប្រជុំបូកសរុបប្រចាំឆ្នាំស្តីពីការងារគ្រប់គ្រងបណ្ណាល័យដល់បណ្ណារក្ស និងនាយកសាលាចំនួន ៤៤ នាក់
- អង្គការRoom to Read បានសាងសង់អគារបណ្ណាល័យចំនួន ១៦បន្ទប់ បានផ្តល់សៀវភៅអំណានភាសាខ្មែរសម្រាប់បណ្ណាល័យចំនួន ១៣,០៦៩ក្បាល សៀវភៅអំណានភាសាអង់គ្លេសសរុប ៤៣៥ក្បាល សៀវភៅភាសាខ្មែរជំនួយសិស្សថ្នាក់ទី១ ទី២ (ភាគ១ភាគ២ភាគ៣) ចំនួន ៤,៥២០ក្បាល សៀវភៅភាសាខ្មែរជំនួយគ្រូថ្នាក់ទី១ ទី២ (ភាគ១ភាគ២ភាគ៣) សរុប៩៦ក្បាល។

## ផ្នែកផែនការនិងគ្រប់គ្រងជំនួយ មន្ទីរអប់រំ យុវជន និងកីឡា

- **ផ្នែកសំណង់** ៖ គិតក្នុងឆ្នាំសិក្សា ២០១៦-២០១៧ មន្ទីរអប់រំយុវជន និងកីឡាខេត្ត បានទទួលនូវសមិទ្ធផលសំណង់តាមគ្រឹះស្ថានសិក្សាក្រោមអំណោយឧបត្ថមដែលមាន ៖
  - សំណង់អគារ ជាអំណោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជាដែលបានសាងសង់មាន ៖
    - ស្រុក មេមត់ ដែលមានសមិទ្ធិផល អគារសិក្សា ចំនួន ៥ ខ្នង ស្មើនឹង ៦០ បន្ទប់ ទីចាត់ការ ១ ខ្នង ស្មើនឹង ៣ បន្ទប់ ដែលក្នុងនោះប្រគល់ដល់សាលាបឋមសិក្សាប៊ុន រ៉ានី ហ៊ុនសែនក្តុលផ្សារ នូវអគារសិក្សា ១ខ្នង ស្មើនឹង ៣០បន្ទប់ និងទីចាត់ការ ១ខ្នង ស្មើនឹង ៣បន្ទប់ ។ សាលាបឋមសិក្សាកោះថ្មទទួលបានអគារសិក្សា ១ខ្នង ស្មើនឹង ១២បន្ទប់ ។ សាលាបឋមសិក្សាបេងកោងទទួលបានអគារសិក្សា ១ខ្នង ស្មើនឹង ៦បន្ទប់ ។ សាលាបឋមសិក្សាស្លាភ្នំទទួលបានអគារសិក្សា ១ខ្នង ស្មើនឹង ៦បន្ទប់ និងសាលាបឋមសិក្សាចង្កំ ទទួលបានអគារសិក្សា ១ខ្នង ស្មើនឹង ៦បន្ទប់ ។
    - ស្រុក ក្រូចឆ្មារ បានសាងសង់អគារសិក្សា ចំនួន ១ ខ្នង ស្មើនឹង ២១ បន្ទប់ ប្រគល់ដល់សាលាបឋមសិក្សាប៊ុនរ៉ានី ហ៊ុនសែន កំពង់ទ្រាស ។
    - ស្រុក ត្បូងឃ្មុំ ដែលមានសមិទ្ធិផលអគារសិក្សា ចំនួន ៣ ខ្នង ស្មើនឹង ៥០ បន្ទប់ ទីចាត់ការ ២ ខ្នង ស្មើនឹង ៦ បន្ទប់ ដែលក្នុងនោះប្រគល់ដល់សាលាបឋមសិក្សាប៊ុន រ៉ានី ហ៊ុនសែនពាមជីលាំង នូវអគារសិក្សា ២ខ្នង ស្មើនឹង ៣២បន្ទប់ និងទីចាត់ការ ១ខ្នង ស្មើនឹង ៣បន្ទប់ ។ សាលាបឋមសិក្សាចំណុះរដ្ឋបាលខេត្តត្បូងឃ្មុំ ទទួលបានអគារសិក្សា ១ខ្នង ស្មើនឹង ១៨ បន្ទប់ និងទីចាត់ការ ១ខ្នង ស្មើនឹង ៣បន្ទប់ ។

## ការពិនិត្យតាមដាន និងវាយតម្លៃ:

- ចុះអធិការកិច្ចនៅតាមសាលាបឋមសិក្សានានាក្នុងខេត្តបានចំនួន ១៥០ សាលា ។
- បានចុះវាយតម្លៃសាលាទាំងបីកម្រិតចំនួន ៣៨ សាលា ។

**សូចនាករបានបង្ហាញវឌ្ឍនភាព ក្នុងការកាត់បន្ថយអត្រាត្រួតថ្នាក់ ការកាត់បន្ថយចំនួនសាលារៀនមិនគ្រប់កម្រិត ការប្រមូលកុមារចូលរៀនឡើងវិញ អត្រាបោះបង់ការសិក្សា និងការបញ្ចប់ការសិក្សា**

| ល.រ | សូចនាករ | ជាក់ស្តែង | | ចំណុចដៅ | | ស្ថានភាព |
|---|---|---|---|---|---|---|
| | | 2016-2017 | | 2016-2017 | | |
| | | សរុប | ស្រី | សរុប | ស្រី | |
| 1 | ផលធៀបសិស្ស-ថ្នាក់នៅបឋមសិក្សា | 36 | | 35 | | → |
| 2 | អត្រាត្រួតថ្នាក់ | 7.58% | 6.59% | 3% | 3% | ↓ |
| 3 | អត្រាបោះបង់ការសិក្សា | 2.38% | 2.09% | 1.50% | 1.50% | ↓ |
| 4 | អត្រាបញ្ចប់ការសិក្សា | 92,11% | 93,19% | 95% | 95% | ↓ |
| 5 | ចំនួនសិស្សចូលរៀនឡើងវិញពីថ្នាក់ទី 3 ដល់ទី 6 | 870 | 374 | 925 | 476 | ↓ |
| 6 | ចំនួនសាលារៀនមិនគ្រប់កម្រិត | 80 | | 74 | | ↓ |
| 7 | ផលធៀបសៀវភៅសិក្សាគោលពីថ្នាក់ទី 1 ដល់ទី 3 | 3/1 | | 3/1 | | → |
| 8 | ភាគរយសិស្សសម្រេចបានតាមស្តង់ដារការសិក្សាលើមុខវិជ្ជាភាសាខ្មែរ ដោយផ្អែកលើតេស្តនៅ ៖ | | | | | |
| | - ថ្នាក់ទី 3 | N/A | N/A | N/A | N/A | N/A |
| | - ថ្នាក់ទី 6 | 52.1% | 55.4% | N/A | N/A | N/A |
| 9 | ភាគរយសិស្សសម្រេចបានតាមស្តង់ដារការសិក្សាលើមុខវិជ្ជាគណិតវិទ្យា ដោយផ្អែកលើតេស្តនៅ ៖ | | | | | |
| | - ថ្នាក់ទី 3 | N/A | N/A | N/A | N/A | N/A |
| | - ថ្នាក់ទី 6 | 48.4% | 48.7% | N/A | N/A | N/A |
| | - ថ្នាក់ទី 8 | N/A | N/A | N/A | N/A | N/A |

<u>សម្គាល់:</u> ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

## ក.២.<u>ធានាភាពសក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់</u>

**មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាន ៖**

- បំប៉នគណៈគ្រប់គ្រងសាលារៀន ចំនួន ១២៣ នាក់ ស្តីពីការរៀបចំតេស្តចុងឆ្នាំនិងដើមឆ្នាំ
- បំប៉នអ្នកទទួលបន្ទុកបំពេញរបាយការណ៍ចំនួន ១៧ នាក់ នៅការិយាល័យអប់រំ យុវជន និងកីឡាស្រុកអូររាំងឪ ស្តីពីការបំពេញរបាយការណ៍ ការគ្រប់គ្រងពត៌មានផ្អែកលើលទ្ធផលសិក្សារបស់អនុវិស័យបឋមសិក្សា
- សិក្ខាសាលាស្តីការពង្រឹងតួនាទី DTMT ដែលមានអ្នកចូលរួមចំនួន ៦០នាក់ ស្រី៤នាក់
- បានចូលរួមសិក្ខាសាលាស្តីពីស្តង់ដារសាលាបឋមសិក្សា នៅខេត្តកំពង់ធំ ចំនួន ៥នាក់
- បានចូលរួមសិក្ខាសាលាស្តីពីផែនការយុទ្ធសាស្ត្រអនុវិស័យបឋមសិក្សា នៅខេត្តកំពង់ចាម
- បានបើកវគ្គបំប៉នស្តីការពង្រឹងកម្មវិធីអាហារូបករណ៍ ដែលមានអ្នកចូលរួមចំនួន ៦០នាក់
- ប្រជុំផ្សព្វផ្សាយ ពិគ្រោះយោបល់លទ្ធផលតេស្តវាយតម្លៃសិស្សថ្នាក់ជាតិថ្នាក់ទី៦ ចំនួន ៤៥ នាក់
- ប្រជុំណែនាំផ្សព្វផ្សាយលទ្ធផលការងារអធិការកិច្ចដល់នាយក នាយិកា លោកគ្រូ អ្នកគ្រូ ចំនួន ៥៧ នាក់
- អង្គការសុវណ្ណភូមិបានបំប៉នគ្រូថ្នាក់រៀនយឺត ក្នុងស្រុកតំបែរ ស្រុកមេមត់ និងស្រុកពញាក្រែក ចំនួន ៧១សាលា ដែលមានគ្រូចូលរួមចំនួន ២១០នាក់ ស្រី ៧៨នាក់ និងបំប៉នដល់នាយកសាលាស្តីពីភាពជាអ្នកដឹកនាំចំនួន ៣៨ នាក់
- អង្គការPlan បានបំប៉នគ្រូថ្នាក់ទី១ ចំនួន ៤៩ នាក់ ស្តីពីកម្មវិធីបង្រៀនកុមារអាយុ ៦ឆ្នាំ ដែលមិនបានឆ្លងកាត់មត្តេយ្យ ចំនួន ៦ ថ្ងៃ និងលើកទី២ ចំនួន ១៥ នាក់ ចំនួន ៤ថ្ងៃ នៅស្រុក ២ គឺ តំបែរ ចំនួន ៣៤ សាលា និង

ពញាក្រែកចំនួន ១៥ សាលា ហើយគ្រូនឹងបង្រៀនសិស្សដែលត្រៀមចូលថ្នាក់ទី១ ចំនួន ២ខែ គឺខែ កញ្ញា និង តុលា

- អង្គការPlan បានកែសម្រួលឯកសារកម្មវិធីបង្រៀនកុមារអាយុ ៦ឆ្នាំ ដែលមិនបានឆ្លងកាត់មត្តេយ្យចំនួន ៣ថ្ងៃដោយមានការចូលរួមពីនាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងមានការចូលរួមពីអង្គការ Kape
- អង្គការសុវណ្ណភូមិ បានបើកវគ្គបំប៉នពីតួនាទីភារកិច្ចគណៈកម្មការទ្រទ្រង់សាលា នៅស្រុកពញាក្រែក និងតំបែរ
- អង្គការ Kape បានបើកវគ្គបំប៉នស្តីពីវិធីសាស្ត្របង្រៀននិងស្វ័យវាយតម្លៃសាលារៀន ដល់គ្រូថ្នាក់ទី១ ដល់ ទី៦ ចំនួន ១៨នាក់ នៅស្រុកមេមត់ និងស្រុកត្បូងឃ្មុំ ចំនួន ១៥សាលា
- អង្គការ Kape បានជួយដល់សាលា ៣ ក្នុងស្រុកត្បូងឃ្មុំ និងពញាក្រែក លើកម្មវិធីពង្រឹងអំណានសរុប (TRACIII) ផ្តោតលើថ្នាក់ទី១ និងទី២ ផ្នែកភាសាខ្មែរ
- អង្គការ Save The Children បានបណ្តុះបណ្តាល ស្តីពីការរៀបចំផែនទីសិក្សាដល់សាលា ចំនួន ០៤ ក្នុងស្រុកមេមត់ និងគណៈកម្មការទាំង១០
- អង្គការ Room to Read បានបណ្តុះបណ្តាលមន្ត្រីអប់រំថ្នាក់ខេត្ត ថ្នាក់សាលារៀន ស្តីពីកម្មវិធីអំណាន ថ្នាក់ទី ១ និងទី ២ ចំនួន ៥លើក
- អង្គការ Save the Children បានបើកវគ្គបំប៉នស្តីពីការរៀបចំផែនទីសិក្សានៅដើមឆ្នាំសិក្សា ចំនួន ៤សាលា ក្នុងស្រុកមេមត់ដល់នាយក គណៈកម្មការទ្រទ្រង់សាលា និងក្រុមប្រឹក្សាកុមារ និងការកសាងផែនការអភិវឌ្ឍសាលារៀន
- អង្គការ Save the Children បានបើកវគ្គបំប៉នស្តីពីការរៀបចំផែនការអភិវឌ្ឍសាលារៀន រយៈពេលវែង និងខ្លី ដល់លោកគ្រូ អ្នកគ្រូ ចំនួន២៦ នាក់ ក្នុងសាលាគោលដៅ ០៤ គឺសាលាបឋមសិក្សា បុស្សតាអឹម សំបួរ សាឡង់២ និងក្រវៀនធំ ក្នុងស្រុកមេមត់
- អង្គការ Save the Children បានរៀបចំមណ្ឌលអាននៅក្នុងសហគមន៍១កន្លែងនៅភូមិក្នុងសាលាបឋមសិក្សាសំបួរ ស្រុកមេមត់
- អង្គការ Save the Children បានបំប៉នស្តីពីការរៀបចំតេស្តប្រចាំសប្តាហ៍ ខែ ឆ្នាំ ដល់នាយកសាលា៤ ក្នុងស្រុកមេមត់
- អង្គការRoom to Read បំប៉នបច្ចេកទេសដឹកនាំសកម្មភាពអំណានទាំង ៤បែប រយៈពេល ៤ថ្ងៃ ដល់ប្រធានក្រុមបច្ចេកទេសថ្នាក់ទី១ ដល់ ទី៦ ចំនួន ១៦១ នាក់ ស្រី ១០០នាក់ សៀវភៅជំនួយសិស្សថ្នាក់ទី១ ទី២ និងជួយផ្តល់សម្ភារៈបណ្ណាល័យដូចជា ធុងដែក ៤៤ធុង សម្ភារៈបណ្ណារក្ស ២២គេះ
- អង្គការRoom to Read បានបណ្តុះបណ្តាលមន្ត្រីអប់រំថ្នាក់ខេត្ត ថ្នាក់សាលារៀនចំនួន ៥លើក ចំនួន ៦៥នាក់ ក្នុង ២ ស្រុក គឺស្រុកត្បូងឃ្មុំ និងពញាក្រែក
- អង្គការRoom to Read បានបំប៉នបច្ចេកទេសការគ្រប់គ្រងបណ្ណាល័យ រយៈពេល ៧ថ្ងៃ ដល់បណ្ណារក្សចំនួន ៤៤ នាក់ ស្រី៣០នាក់
- អង្គការ Kape បានបើកវគ្គបំប៉នស្តីពីវិធីសាស្ត្របង្រៀន និងស្វ័យវាយតម្លៃដល់គ្រូថ្នាក់ទី១ដល់ ថ្នាក់ទី៦ ចំនួន១៨នាក់
- មន្ទីរអប់រំ យុវជន និងកីឡាបានបើកវគ្គសិក្ខាសាលាស្តីពីការពង្រឹងការងារបណ្ណាល័យដល់នាយកសាលា និងបណ្ណារក្សចំនួន ១១០នាក់ ស្រី ៣៣នាក់ ។

- អង្គការSave the Children បានបើកបំប៉នស្តីពីការបង្រៀនបំណិនជីវិតដល់នាយក និងគ្រូបង្រៀនថ្នាក់ទី៤ ដល់ ទី៦ នៅស្រុកមេមត់ មានអ្នកចូលរួមចំនួន ១៧ នាក់ ស្រី៦នាក់។
- **អង្គការ វី អេស អូ ( VSO )**
  - បានបើកវគ្គបណ្តុះបណ្តាលស្តីពីការវិភាគ លើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស ភាពពាក់ព័ន្ធ និងឧបសគ្គ ដល់នាយកសាលាបឋមសិក្សាចំនួន ១១៨ នាក់ ក្នុងស្រុកគោលដៅ គឺស្រុកតំបែរ និងស្រុកពញាក្រែក
  - បានបើកវគ្គស្តីពីការកសាងផែនការអភិវឌ្ឍសាលាបឋមសិក្សា ដោយមានកិច្ចសហការបច្ចេកទេសពីជំនាញការិយាល័យផែនការ និងគ្រប់គ្រងជំនួយ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដល់នាយកសាលាចំនួន ០៤ ស្រុក គឺ ស្រុកតំបែរ ស្រុកមេមត់ ស្រុកពញាក្រែក និងស្រុកក្រូចឆ្មារ ។

## ខ.វឌ្ឍនភាពនៃសូចនាករផលសម្រេចតាមអនុវិស័យ

### ១. វឌ្ឍនភាពសូចនាករស្នូល

**ការវិភាគវឌ្ឍនភាពនៃសូចនាករផលសម្រេច ៖**

| | ការអប់រំបឋមសិក្សា | ជាក់ស្តែងឆ្នាំ 2015-2016 | ចំណុចដៅឆ្នាំ 2016-2017 | ជាក់ស្តែងឆ្នាំ 2016-2017 | ស្ថានភាព |
|---|---|---|---|---|---|
| ១ | អត្រាពិតចូលរៀនថ្មី | 96.17% | 99% | 97.30% | → |
| | អត្រាពិតចូលរៀនថ្មី (ស្រី) | 95.27% | 99% | 96.86% | → |
| ២ | អត្រាពិតនៃការសិក្សា | 95.14% | 98.98% | 95.16% | → |
| | អត្រាពិតនៃការសិក្សា (ស្រី) | 95,14% | 98.98% | 96.61% | → |
| ៣ | អត្រាបោះបង់ការសិក្សា | 2.79% | 1.50% | 2.38% | → |
| | អត្រាបោះបង់ការសិក្សា (ស្រី) | 2.55% | 1.50% | 2.09% | → |
| ៤ | អត្រាបញ្ចប់ការសិក្សា | 91.64% | 95% | 92.11% | → |
| | អត្រាបញ្ចប់ការសិក្សា (ស្រី) | 92.83% | 95% | 93.19% | → |
| ៥ | អត្រាត្រួតថ្នាក់ | 8.68% | 1.50% | 7.58% | → |
| | អត្រាត្រួតថ្នាក់ (ស្រី) | 7.54% | 1.50% | 6.59% | → |
| ៦ | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | 91.44% | 95% | 91.15% | ↓ |
| | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ(ស្រី) | 92.72% | 95% | 90.26% | ↓ |
| ៧ | ចំនួនស្រុក/ក្រុង ដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០ភាគរយ | 7 | 7 | 7 | ↑ |
| ៨ | ភាគរយសិស្សថ្មីថ្នាក់ទី១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សា | 53% | 64% | 57% | → |
| ៩ | ភាគរយសាលាកុមារមេត្រី កម្រិតមធ្យម និងកម្រិតអភិវឌ្ឍ | 76% | 80% | 79% | → |
| ១០ | ភាគរយសាលាបឋមសិក្សាមាន | | | | |
| | បង្គន់អនាម័យ និងទឹកស្អាត | 72.91% | 75% | 74% | → |
| | កន្លែងសម្អាតដៃ | 74.68% | 80% | 76% | → |
| | ប្រអប់សង្គ្រោះបឋម | 55.18% | 65% | 56% | → |
| ១០ | ចំនួនសិស្សទទួលអាហារូបករណ៍ | 8,290 | 8,290 | 8, 223 | ↓ |
| ១១ | ចំនួនគ្រឹះស្ថានសិក្សា ដែលបានចុះពិនិត្យក្នុងមួយឆ្នាំ | 78 | 100 | 150 | ↑ |

<u>**សម្គាល់:**</u> ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

**គ.បញ្ហាប្រឈម:**

ទន្ទឹមនឹងលទ្ធផលដែលបានសម្រេចខាងលើការអប់រំបឋមសិក្សាក្នុងខេត្តត្បូងឃ្មុំ បានជួបនូវបញ្ហាប្រឈម មួយចំនួនដូចជា៖

- ការប្រមូលកុមារចូលរៀនមិនទាន់បានតាមអាយុកុមារដែលត្រូវចូលរៀន
- ការចូលរួមរបស់មាតាបិតា និងសហគមន៍មិនទាន់បានពេញលេញ
- ខ្វះគ្រូបង្រៀននៅតាមសាលាឆ្ងាយៗពីទីប្រជុំជន
- សិស្សអវត្តមានច្រើនក្នុងរដូវប្រមូលផល ជាពិសេសចល័តទីលំនៅតាមឪពុកម្តាយ
- សមត្ថភាពគ្រប់គ្រងដឹកនាំរបស់នាយកសាលាមួយចំនួនតូចមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀន
- ការចុះពិនិត្យតាមដានរបស់ DTMT មិនបានគ្រប់សាលា
- ការចុះពិនិត្យតាមដានរបស់មន្ត្រីថ្នាក់ខេត្តមិនបានគ្រប់សាលា

## ២.២.៣-អនុវិស័យការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស ៖

### ក-លទ្ធផលសម្រេចបាន៖

#### ក.១.ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាការពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ឆ្នាំសិក្សា ២០១៧-២០១៨ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈមាន ៧៨សាលា បើធៀបនឹងឆ្នាំ២០១៦-២០១៧ គ្រឹះស្ថានមធ្យមសិក្សាកើនមួយកន្លែង ។ អនុវិទ្យាល័យប្តូរភូមិសិក្សាទៅជាវិទ្យាល័យ ចំនួន ០១កន្លែង ។ វិទ្យាល័យធនធានមួយកន្លែងមាននៅវិទ្យាល័យសម្តេចតេជោ ហ៊ុនសែន សួង។ គ្រប់ឃុំសង្កាត់សុទ្ធតែមានអនុវិទ្យាល័យចំនួនមួយឡើងទៅ ទោះនៅតំបន់ជួបការលំបាកក៏ដោយ។ អនុវិទ្យាល័យ ១០ភាគរយ មិនទាន់មានបង្គន់អនាម័យ និង១០ភាគរយ មិនទាន់មានទឹកស្អាតប្រើប្រាស់ ។ ផ្នែកមធ្យមសិក្សាបឋមភូមិមាន បុគ្គលិកអប់រំសរុប ១,១៦០នាក់ ស្រី៤៥៨នាក់ ស្មើនឹង ៧៩.២៨ភាគរយ ថយ ០៩នាក់ ស្រី ០៥នាក់ ក្នុងនោះបុគ្គលិកបង្រៀន ៩៥៨នាក់ ស្រី៤១៨នាក់ ស្មើនឹង ៦៥.៤៨ភាគរយ ថយ ០៤នាក់ ស្រី០៣នាក់ ចំពោះសិស្សមធ្យមសិក្សាបឋមភូមិសាធារណៈមានចំនួន ២៩,៩១៦នាក់ ស្រី១៥,៩៩៩នាក់ ស្មើនឹង ៧១.៦៦ភាគរយ កើន១,១៤០ នាក់ ស្រី៦៣៣នាក់។ ផ្នែកមធ្យមសិក្សាទុតិយភូមិ មានបុគ្គលិកអប់រំសរុប ៣០៣នាក់ ,ស្រី ៨៧នាក់ ស្មើនឹង ២០.៧១ភាគរយ ថយ ០៦នាក់ ស្រី០២នាក់ ក្នុងនោះបុគ្គលិកបង្រៀន ២១៩នាក់ ស្រី ៧៨នាក់ ស្មើនឹង១៤.៩៦ភាគរយ ថយ ១៩នាក់ ស្រី ០៥នាក់ ចំពោះសិស្សមធ្យមសិក្សាទុតិយភូមិសាធារណៈមានចំនួន ១១,៨២៦នាក់ ស្រី ៦,៥៤៥ នាក់ ស្មើនឹង ២៨.៣៣ភាគរយ កើន ១,៦៨៧នាក់ ស្រី១,០៩៥នាក់។ ទោះបីគ្រូបង្រៀនកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក៏នៅតែមានការខ្វះខាត គ្រូនៅមធ្យមសិក្សាទុតិយភូមិ និងគ្រូតាមឯកទេស មុខវិជ្ជាវិទ្យាសាស្ត្រដូចជា មុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងគ្រូភាសាបរទេស ។

សិស្សមធ្យមសិក្សាឯកជនមាន៨៩៥ នាក់ ស្រី៧១៩ នាក់ ស្មើនឹង១១៨.៧០ភាគរយ កើន ១៤១នាក់ ស្រី ១១៣នាក់ ។

ក.១.១-ស្ថានភាពនៃការអប់រំនៅមធ្យមសិក្សាចំណេះទូទៅ ៖

- យុទ្ធនាការប្រមូលកុមារចូលរៀន តាមគ្រឹះស្ថានមធ្យមសិក្សា តាមរយៈការបំផុសស្មារតីមាតាបិតា ឬអាណាព្យាបាលសិស្ស សហគមន៍ ឱ្យយល់ពីសារសំខាន់នៃការរៀនសូត្រពេញមួយជីវិត
- ផ្សព្វផ្សាយពីការលើកកម្ពស់សមភាពយេនឌ័រ និងកុមារបាត់បង់កាយសម្បទា ជាពិសេសសិស្សស្រី កុមារពិការ កុមារក្រីក្រ ឱ្យមានឱកាសបានចូលរៀនដូចកុមារដទៃដែរ

- ជំរុញការលើកទឹកចិត្តសិស្ស តាមរយៈសកម្មភាពផ្តល់ការលើកទឹកចិត្ត ដូចជា រង្វាន់ ប័ណ្ណសរសើរ និងថវិកា
- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងរៀនពូកែ ផ្អែកតាមគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួងក្នុងន័យកាត់បន្ថយការចំណាយរបស់សិស្សអនុលោមតាម ថវិកាកម្មវិធី(PB) និងថវិកាជំនួយកែលម្អ សាលា(SIG) ដោយតម្លាភាព និងមានប្រសិទ្ធភាព
- បង្កើតទំនាក់ទំនងយ៉ាងជិតស្និតជាមួយភាគីពាក់ព័ន្ធ ដូចជាអាជ្ញាធរដែនដី សហគមន៍ ដៃគូអភិវឌ្ឍនានា ដើម្បីឱ្យការអប់រំផ្នែកមធ្យមសិក្សាទូទាំងខេត្តទទួលបានលទ្ធផលល្អ ។
- **អ្នកស្ម័គ្រចិត្តនៅខេត្តត្បូងឃ្មុំ**

ខេត្តត្បូងឃ្មុំទទួលបានអ្នកស្ម័គ្រចិត្តចំនួន ៥នាក់ ដែលមានឈ្មោះ ៖

១.ឈ្មោះ Rachael Carrasco ២.ឈ្មោះ Lyndsey Garrett

៣.ឈ្មោះ Ian Grace ៤.ឈ្មោះ Hye Min Nam

៥.ឈ្មោះ Midian Yohannes

សកម្មភាពបានអនុវត្តគឺ បង្រៀនភាសាអង់គ្លេសប្រចាំថ្ងៃរួមជាមួយគ្រូដៃគូសម្របសម្រួលចំនួន ៣នាក់ បង្រៀនសិស្សអោយមានទំនាក់ទំនង និងអាចសរសេរលិខិតឆ្លើយឆ្លង ជាមួយសិស្សនៅសហរដ្ឋអាមេរិក បង្កើតម៉ោងសម្រាប់កូនសិស្សពីថ្នាក់ទី៧ ដល់ ថ្នាក់ទី១២ ចូលជួបគាត់ដើម្បីរៀនការសន្ទនាជាភាសាអង់គ្លេស នៅក្នុងបណ្ណាល័យចំនួន ២ថ្ងៃ ក្នុងមួយសប្តាហ៍ និង រៀបចំគម្រោងបណ្ណាល័យដែលមានការចូលរួម ជ្រុមជ្រែងពីលោកនាយកសាលា គ្រូ និងសិស្សានុសិស្សផងដែរ នៅវិទ្យាល័យ ហ៊ុន សែន អូររាំងឪ វិទ្យាល័យ ក្រូចឆ្មារ វិទ្យាល័យ ហ៊ុន សែន ប៉ើស II វិទ្យាល័យ ហ៊ុន សែន តំបែរ និងវិទ្យាល័យ ហ៊ុន សែន ខ្នារ ។

- **ផ្នែកផែនការនិងគ្រប់គ្រងជំនួយ មន្ទីរអប់រំ យុវជន និងកីឡា**
  - **ផ្នែកសំណង់** ៖ គិតក្នុងឆ្នាំសិក្សា ២០១៦-២០១៧ មន្ទីរអប់រំយុវជន និងកីឡាខេត្ត បានទទួលនូវសមិទ្ធផលសំណង់តាមគ្រឹះស្ថានសិក្សាក្រោមអំណោយឧបត្ថមដែលមាន ៖
    - សំណង់អគារ ជាអំណោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជាដែលបានសាងសង់មាន ៖
      - ស្រុកមេមត់ ដែលមានសមិទ្ធិផលអគារសិក្សាចំនួន ២ខ្នង ស្មើនឹង ៣៤បន្ទប់ ទីចាត់ការ ១ ខ្នង ស្មើនឹង ០៣ បន្ទប់ និងផ្ទះស្នាក់នៅសម្រាប់គ្រូចំនួន ៣ ខ្នង ស្មើនឹង ៧៨ បន្ទប់ ។ ប្រគល់ដល់ វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន កុលផ្សារ នូវអគារសិក្សាចំនួន ១ខ្នង ស្មើនឹង ១៨បន្ទប់ ទីចាត់ការ ១ ខ្នង ស្មើនឹង ៣បន្ទប់ និងផ្ទះស្នាក់នៅសម្រាប់គ្រូចំនួន ១ខ្នង ស្មើនឹង ៣០បន្ទប់ និងវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន មេមត់នូវអគារសិក្សាចំនួន ១ខ្នង ស្មើនឹង ១៦បន្ទប់ និងផ្ទះស្នាក់នៅសម្រាប់គ្រូចំនួន ២ខ្នង ស្មើនឹង ៤៨បន្ទប់ ។
      - ស្រុកក្រូចឆ្មារ ដែលមានសមិទ្ធិផលជាអគារសិក្សា ចំនួន ១ ខ្នង ស្មើនឹង ២១ បន្ទប់ និងទីចាត់ការ ១ ខ្នង ស្មើនឹង ៣ បន្ទប់ ប្រគល់ដល់អនុវិទ្យាល័យប៊ុន រ៉ានី ហ៊ុនសែន កំពង់ទ្រាស ។
      - ស្រុក ត្បូងឃ្មុំ ដែលមានសមិទ្ធិផលអគារសិក្សា ចំនួន ២ ខ្នង ស្មើនឹង ៤៨ បន្ទប់ទីចាត់ការ ១ ខ្នង ស្មើនឹង ០៣ បន្ទប់ និងផ្ទះស្នាក់នៅសម្រាប់គ្រូចំនួន ៣ ខ្នង ស្មើនឹង ៤០ បន្ទប់ ដែលក្នុងនោះ

ប្រគល់ដល់វិទ្យាល័យ ហ៊ុន សែនពាមជីលាំង នូវអគារសិក្សា ១ខ្នង ស្មើនឹង ៣០បន្ទប់ និងផ្ទះស្នាក់នៅសម្រាប់គ្រូចំនួន ១ ខ្នង ស្មើនឹង ២០ បន្ទប់ ។ អនុវិទ្យាល័យចំណុះរដ្ឋបាលខេត្តត្បូងឃ្មុំ ទទួលបានអគារសិក្សា ១ខ្នង ស្មើនឹង ១៨ បន្ទប់ និងទីចាត់ការ ១ខ្នង ស្មើនឹង ០៣បន្ទប់ និងផ្ទះស្នាក់នៅសម្រាប់គ្រូចំនួន ២ ខ្នង ស្មើនឹង ២០ បន្ទប់ ។

### ក.១.១.១ អនុវិទ្យាល័យ(៧-៩) ៖

| បរិយាយ | ឆ្នាំសិក្សា 2016-2017 | ឆ្នាំសិក្សា 2017-2018 | កើន (+) | ថយ (-) |
|---|---|---|---|---|
| សាលារៀន | 54 សាលា | 54 សាលា | 00 កន្លែង | |
| អគារ | 86 ខ្នង | 87 ខ្នង | 01 ខ្នង | |
| បន្ទប់រៀន | 394 បន្ទប់ | 397 បន្ទប់ | 03 បន្ទប់ | |
| បុគ្គលិកអប់រំនៅអនុវិទ្យាល័យសរុប | 466 នាក់ | 448 នាក់ | 18 នាក់ | |
| បុគ្គលិកអប់រំនៅអនុវិទ្យាល័យស្រី | 182 នាក់ | 174 នាក់ | | 08នាក់ |
| ថ្នាក់រៀនមធ្យមសិក្សាបឋមភូមិ | 568 ថ្នាក់ | 587 ថ្នាក់ | 19 ថ្នាក់ | |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិសរុប | 1,169 នាក់ | 1160 នាក់ | | 09 នាក់ |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិស្រី | 463 នាក់ | 458 នាក់ | | 05នាក់ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាបឋមភូមិសរុប | 962 នាក់ | 958 នាក់ | | 04 នាក់ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាបឋមភូមិស្រី | 421 នាក់ | 418 នាក់ | | 03នាក់ |
| សិស្សមធ្យមសិក្សាបឋមភូមិសាធារណៈសរុប | 28,776 នាក់ | 29,916 នាក់ | 1,140 នាក់ | |
| សិស្សមធ្យមសិក្សាបឋមភូមិសាធារណៈស្រី | 15,366 នាក់ | 15,999 នាក់ | 633 នាក់ | |

### ក.១.១.២ វិទ្យាល័យ (ថ្នាក់ទី៧-១២) ៖

| បរិយាយ | ឆ្នាំសិក្សា 2016-2017 | ឆ្នាំសិក្សា 2017-2018 | កើន (+) | ថយ (-) |
|---|---|---|---|---|
| សាលារៀន | 23 សាលា | 24 សាលា | 01 កន្លែង | |
| អគារ | 115 ខ្នង | 117 ខ្នង | 02 ខ្នង | |
| បន្ទប់រៀន | 654 បន្ទប់ | 669 បន្ទប់ | 15 បន្ទប់ | |
| បុគ្គលិកអប់រំនៅវិទ្យាល័យសរុប | 1,012 នាក់ | 1,010 នាក់ | | 02 នាក់ |
| បុគ្គលិកអប់រំនៅវិទ្យាល័យស្រី | 370 នាក់ | 375 នាក់ | 05 នាក់ | |
| ថ្នាក់រៀនមធ្យមសិក្សាទុតិយភូមិ | 222 ថ្នាក់ | 261 ថ្នាក់ | 39 ថ្នាក់ | |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិសរុប | 309 នាក់ | 303 នាក់ | | 06 នាក់ |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិស្រី | 89 នាក់ | 87 នាក់ | | 02 នាក់ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាទុតិយភូមិសរុប | 238 នាក់ | 219 នាក់ | | 19 នាក់ |
| បុគ្គលិកបង្រៀនមធ្យមសិក្សាទុតិយភូមិស្រី | 83 នាក់ | 78 នាក់ | | 05 នាក់ |
| សិស្សមធ្យមសិក្សាទុតិយភូមិសាធារណៈសរុប | 10,139 នាក់ | 11,826 នាក់ | 1,687 នាក់ | |
| សិស្សមធ្យមសិក្សាទុតិយភូមិសាធារណៈស្រី | 5,450 នាក់ | 6,545 នាក់ | 1,095 នាក់ | |

## តារាងសិស្សជាប់មធ្យមភាគតាមកម្រិតថ្នាក់ធៀបទៅនឹងចំណុចដៅឆ្នាំសិក្សា ២០១៦-២០១៧

| ថ្នាក់ទី | សិស្សដើមឆ្នាំសិក្សា 2016-2017 | | សិស្សជាប់មធ្យមភាគ(%) | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ (%) | | ជាក់ស្តែង (%) | | គម្លាត(%) | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 7 | 12,459 | 6,500 | 82 | 82 | 70.44 | 75.36 | -11.56 | -6.64 |
| 8 | 9,140 | 4,955 | 82 | 82 | 79.16 | 81.65 | -2.84 | -0.35 |
| 9 | 7,177 | 3,911 | 82 | 82 | 80.77 | 83.02 | -1.23 | 1.02 |
| 10 | 4,216 | 2,288 | 82 | 82 | 84.65 | 87.76 | 2.64 | 5.76 |
| 11 | 3,241 | 1,753 | 82 | 82 | 88.02 | 90.92 | 6.02 | 8.92 |
| 12 | 2,682 | 1,409 | 82 | 82 | 92.65 | 93.68 | 10.65 | 11.68 |
| សរុប | 38,915 | 20,816 | 82 | 82 | 78.93 | 82.21 | -3.07 | 0.21 |

## តារាងសិស្សធ្លាក់មធ្យមភាគតាមកម្រិតថ្នាក់ធៀបទៅនឹងចំណុចដៅឆ្នាំសិក្សា ២០១៦-២០១៧

| ថ្នាក់ទី | សិស្សដើមឆ្នាំសិក្សា 2016-2017 | | សិស្សធ្លាក់មធ្យមភាគ(%) | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ (%) | | ជាក់ស្តែង (%) | | គម្លាត(%) | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 7 | 12,459 | 6,500 | 8.00 | 8.00 | 15.04 | 12.01 | -7.04 | -4.01 |
| 8 | 9,140 | 4,955 | 8.00 | 8.00 | 10.12 | 8.21 | -2.12 | -0.21 |
| 9 | 7,177 | 3,911 | 8.00 | 8.00 | 5.16 | 3.70 | 2.84 | 4.30 |
| 10 | 4,216 | 2,288 | 8.00 | 8.00 | 6.68 | 4.76 | 1.32 | 3.24 |
| 11 | 3,241 | 1,753 | 8.00 | 8.00 | 6.23 | 3.08 | 1.77 | 4.92 |
| 12 | 2,682 | 1,409 | 8.00 | 8.00 | 1.93 | 1.20 | 6.07 | 6.80 |
| សរុប | 38,915 | 20,816 | 8.00 | 8.00 | 9.52 | 7.26 | -1.52 | -0.74 |

## តារាងសិស្សបោះបង់ការសិក្សាតាមកម្រិតថ្នាក់ធៀបទៅនឹងចំណុចដៅឆ្នាំសិក្សា ២០១៦-២០១៧

| ថ្នាក់ទី | សិស្សដើមឆ្នាំសិក្សា 2016-2017 | | សិស្សបោះបង់ការសិក្សា(%) | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ចំណុចដៅ (%) | | ជាក់ស្តែង (%) | | គម្លាត(%) | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 7 | 12,459 | 6,500 | 10.00 | 10.00 | 14.50 | 12.61 | -4.50 | -2.61 |
| 8 | 9,140 | 4,955 | 10.00 | 10.00 | 10.71 | 10.13 | -0.71 | -0.13 |
| 9 | 7,177 | 3,911 | 10.00 | 10.00 | 14.05 | 13.27 | -4.05 | -3.27 |
| 10 | 4,216 | 2,288 | 10.00 | 10.00 | 8.65 | 7.47 | 1.35 | 2.53 |
| 11 | 3,241 | 1,753 | 10.00 | 10.00 | 5.73 | 5.98 | 4.27 | 4.02 |
| 12 | 2,682 | 1,409 | 10.00 | 10.00 | 5.40 | 5.11 | 4.60 | 4.89 |
| សរុប | 38,915 | 20,816 | 10.00 | 10.00 | 11.54 | 10.51 | -1.54 | -0.51 |

## តារាងសិស្សជាប់មធ្យមភាគតាមកម្រិតថ្នាក់ឆ្នាំសិក្សា២០១៦-២០១៧ ធៀបទៅនឹងឆ្នាំសិក្សា ២០១៥-២០១៦

| ថ្នាក់ទី | សិស្សឆ្នាំសិក្សា 2015-2016 | | សិស្សឆ្នាំសិក្សា 2016-2017 | | គម្លាត | | សិស្សជាប់មធ្យមភាគ (%) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ឆ្នាំសិក្សា 2015-16 | | ឆ្នាំសិក្សា 2016-17 | | គម្លាត | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 7 | 11,828 | 6,263 | 12,459 | 6,500 | 631 | 237 | 71.07 | 75.69 | 70.44 | 75.36 | 0.63 | -0.33 |
| 8 | 8,609 | 4,680 | 9,140 | 4,955 | 531 | 275 | 76.75 | 80.51 | 79.16 | 81.65 | -2.41 | 1.14 |
| 9 | 6,421 | 3,335 | 7,177 | 3,911 | 756 | 576 | 74.77 | 78.35 | 80.77 | 83.02 | 6.00 | 4.67 |
| 10 | 3,920 | 2,093 | 4,216 | 2,288 | 296 | 195 | 78.95 | 82.36 | 84.65 | 87.76 | 5.70 | 5.40 |
| 11 | 2,951 | 1,535 | 3,241 | 1,753 | 290 | 218 | 84.71 | 87.62 | 88.02 | 90.92 | 3.31 | 3.30 |
| 12 | 2,407 | 1,227 | 2,682 | 1,409 | 275 | 182 | 87.24 | 89.97 | 92.65 | 93.68 | 5.41 | 3.71 |
| សរុប | 36,136 | 19,133 | 38,915 | 20,816 | 2,779 | 1,683 | 76.13 | 79.94 | 78.93 | 82.21 | 2.80 | 1.01 |

## តារាងសិស្សធ្លាក់មធ្យមភាគតាមកម្រិតថ្នាក់ឆ្នាំសិក្សា២០១៦-២០១៧ ធៀបទៅនឹងឆ្នាំសិក្សា ២០១៥-២០១៦

| ថ្នាក់ទី | សិស្សឆ្នាំសិក្សា 2015-2016 | | សិស្សឆ្នាំសិក្សា 2016-2017 | | គម្លាត | | សិស្សធ្លាក់មធ្យមភាគ (%) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ឆ្នាំសិក្សា 2015-16 | | ឆ្នាំសិក្សា 2016-17 | | គម្លាត | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 7 | 11,828 | 6,263 | 12,459 | 6,500 | 631 | 237 | 7.38 | 5.75 | 13.91 | 9.64 | 6.53 | 3.89 |
| 8 | 8,609 | 4,680 | 9,140 | 4,955 | 531 | 275 | 7.16 | 5.20 | 9.19 | 6.94 | 2.03 | 1.74 |
| 9 | 6,421 | 3,335 | 7,177 | 3,911 | 756 | 576 | 4.55 | 2.64 | 7.74 | 5.66 | 3.19 | 3.02 |
| 10 | 3,920 | 2,093 | 4,216 | 2,288 | 296 | 195 | 4.47 | 3.24 | 10.05 | 7.40 | 5.58 | 4.16 |
| 11 | 2,951 | 1,535 | 3,241 | 1,753 | 290 | 218 | 4.68 | 2.97 | 7.15 | 4.29 | 2.47 | 1.32 |
| 12 | 2,407 | 1,227 | 2,682 | 1,409 | 275 | 182 | 11.39 | 10.82 | 4.11 | 3.50 | -7.28 | -7.32 |
| សរុប | 36,136 | 19,133 | 38,915 | 20,816 | 2,779 | 1,683 | 6.71 | 5.06 | 10.07 | 7.22 | 3.36 | 2.16 |

## តារាងសិស្សបោះបង់ការសិក្សាតាមកម្រិតថ្នាក់ឆ្នាំសិក្សា២០១៦-២០១៧ធៀបទៅនឹងឆ្នាំសិក្សា២០១៥-២០១៦

| ថ្នាក់ទី | សិស្សឆ្នាំសិក្សា 2015-2016 | | សិស្សឆ្នាំសិក្សា 2016-2017 | | គម្លាត | | សិស្សបោះបង់ការសិក្សា (%) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ឆ្នាំសិក្សា 2015-16 (%) | | ឆ្នាំសិក្សា 2016-17 (%) | | គម្លាត(%) | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 7 | 11,828 | 6,263 | 12,459 | 6,500 | 631 | 237 | 15.63 | 14.99 | 14.50 | 12.61 | -1.13 | -2.38 |
| 8 | 8,609 | 4,680 | 9,140 | 4,955 | 531 | 275 | 13.56 | 13.11 | 10.71 | 10.13 | -2.85 | -2.98 |
| 9 | 6,421 | 3,335 | 7,177 | 3,911 | 756 | 576 | 17.20 | 15.14 | 14.05 | 13.27 | -3.15 | -0.78 |
| 10 | 3,920 | 2,093 | 4,216 | 2,288 | 296 | 195 | 10.89 | 9.46 | 8.65 | 2.24 | -0.81 | -7.22 |
| 11 | 2,951 | 1,535 | 3,241 | 1,753 | 290 | 218 | 8.84 | 7.42 | 5.73 | 5.98 | -3.11 | -1.44 |
| 12 | 2,407 | 1,227 | 2,682 | 1,409 | 275 | 182 | 7.47 | 7.00 | 5.40 | 5.11 | -2.07 | -1.89 |
| **សរុប** | **36,136** | **19,133** | **38,915** | **20,816** | **2,779** | **1,683** | **13.80** | **12.83** | **11.54** | **10.51** | **-2.26** | **-2.32** |

## លទ្ធផលប្រឡងសញ្ញាបត្រឆ្នាំសិក្សា ២០១៦-២០១៧ ធៀបទៅនឹងឆ្នាំសិក្សា ២០១៥-២០១៦ ៖

| ល.រ | បរិយាយ | ឆ្នាំសិក្សា 2015-2016 | | | | ឆ្នាំសិក្សា 2016-2017 | | | |
|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប % | ស្រី % | សរុប | ស្រី | សរុប % | ស្រី % |
| ១- | មធ្យមសិក្សាបឋមភូមិ | | | | | | | | |
| | -សិស្សដើមឆ្នាំសិក្សា | 5,648 | 2,911 | | | 7,056 | 3,877 | | |
| | -បេក្ខជនមកប្រឡង | 5,145 | 2,741 | 91.09 | 94.16 | 6,092 | 3,428 | 86.33 | 88.41 |
| | -បេក្ខជនប្រឡងជាប់ | 4,630 | 2,553 | 89.99 | 93.14 | 5,620 | 3,260 | 92.25 | 95.09 |
| ២- | មធ្យមសិក្សាទុតិយភូមិ | | | | | | | | |
| | -សិស្សដើមឆ្នាំសិក្សា | 2,586 | 1,357 | | | 3,151 | 1,660 | | |
| | -បេក្ខជនមកប្រឡង | 2,568 | 1,350 | 99.30 | 99.48 | 3,124 | 1,646 | 99.14 | 99.15 |
| | -បេក្ខជនប្រឡងជាប់ | 1,690 | 947 | 65.80 | 70.14 | 2,033 | 1,100 | 65.07 | 66.82 |

- លទ្ធផលការប្រឡងមធ្យមសិក្សាទុតិយភូមិសម័យប្រឡង៖ ២១ សីហា ២០១៧
- និទ្ទេសA : ០៧ នាក់ ស្រី ០៤ នាក់ , និទ្ទេស B : ៧១ នាក់ ស្រី ៤៣ នាក់, និទ្ទេស C : ១៥៥ នាក់ ស្រី ៩០ នាក់, និទ្ទេស D : ២៤៥ នាក់ ស្រី ១២០ នាក់ និងនិទ្ទេស E : ១,៥៥៥ នាក់ ស្រី ៨៤៣នាក់

## លទ្ធផលប្រឡងសិស្សពូកែឆ្នាំសិក្សា ២០១៥-២០១៦ ធៀបទៅនឹងឆ្នាំសិក្សា ២០១៦-២០១៧ ៖

| មុខវិជ្ជា | ថ្នាក់ទី៩ | | | | | | ថ្នាក់ទី ១២ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2015-2016 | | 2016-2017 | | គម្លាត(កើន-ថយ) | | 2015-2016 | | 2016-2017 | | គម្លាត(កើន-ថយ) | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| -អក្សរសាស្ត្រខ្មែរ | 00 | 00 | 00 | 00 | 00 | 00 | 00 | 00 | 01 | 01 | 01 | 01 |
| -គណិតវិទ្យា | 01 | 00 | 00 | 00 | -01 | 00 | 01 | 00 | 01 | 01 | 00 | 01 |
| -រូបវិទ្យា | 00 | 00 | 00 | 00 | 00 | 00 | 00 | 00 | 00 | 00 | 00 | 00 |
| សរុបរួម | **01** | **00** | **00** | **00** | **-01** | **00** | **01** | **00** | **02** | **02** | **01** | **02** |

- សិស្សពូកែប្រឡងជាប់ទូទាំងប្រទេសថ្នាក់ទី៩ បានចំនួន ០១ នាក់ ស្រី 00 នាក់ ក្នុងនោះចំណាត់ថ្នាក់ជ័យលាភីលេខ ១០ ផ្នែករូបវិទ្យាថ្នាក់ទី៩ ចំនួន ០១ នាក់ ស្រី 00 នាក់ ។

## តារាងផលធៀបផ្នែកមធ្យមសិក្សា ២០១៦-២០១៧ និង២០១៧-២០១៨

| បរិយាយ | | ឆ្នាំសិក្សា 2016-2017 | ឆ្នាំសិក្សា 2017-2018 | កើន -ថយ |
|---|---|---|---|---|
| **ផ្នែកមធ្យមសិក្សាបឋមភូមិ** | | | | |
| 1 | ផលធៀបសិស្ស-ថ្នាក់ | 50.66 | 50.96 | 0.30 |
| 2 | ផលធៀបសិស្ស-គ្រូ | 24.61 | 25.78 | 1.17 |
| 3 | ផលធៀបសិស្ស-បន្ទប់រៀន | 41.25 | 41.73 | 0.48 |
| **ផ្នែកមធ្យមសិក្សាទុតិយភូមិ** | | | | |
| 1 | ផលធៀបសិស្ស-ថ្នាក់ | 45.67 | 45.31 | -0.36 |
| 2 | ផលធៀបសិស្ស-គ្រូ | 32.81 | 39.02 | 6.21 |
| 3 | ផលធៀបសិស្ស-បន្ទប់រៀន | 42.22 | 42.51 | 0.29 |

❖ ការផ្គត់ផ្គង់សៀវភៅសិក្សាគោល និងសៀវភៅអំណានបន្ថែម

- សិស្សថ្នាក់ទី៧-៩ ម្នាក់ៗទទួលបានសៀវភៅ ៧ក្បាល តម្រូវការសៀវភៅ ៥ក្បាលសៀវភៅ ទទួលបាន គឺ ៤ក្បាល ( ខ្វះសៀវភៅភាសាអង់គ្លេសកម្មវិធីថ្មី )
- សិស្សថ្នាក់ទី១០ ម្នាក់ៗទទួលបានសៀវភៅ ៨ក្បាល
- សិស្សថ្នាក់ទី១១-១២ ម្នាក់ៗទទួលបានសៀវភៅ ១១ក្បាល

**តារាងកម្មវិធីសិក្សាធៀបនឹងចំណុចដៅឆ្នាំសិក្សា ២០១៥-២០១៦ និងធៀបឆ្នាំសិក្សា ២០១៦-២០១៧ ៖**

| មុខវិជ្ជា | ធៀបនឹងចំណុចដៅឆ្នាំសិក្សា 2016-2017 | | | ធៀបនឹងឆ្នាំសិក្សា2016-2017 | | |
|---|---|---|---|---|---|---|
| | ចំណុចដៅ | ជាក់ស្តែង | កើន/ថយ | 2015-2016 | 2016-2017 | កើន/ថយ |
| -គណិតវិទ្យា | 100% | 98.60% | -1.40% | 98.00% | 98.60% | 0.60% |
| -រូបវិទ្យា | 100% | 98.85% | -1.15% | 98.50% | 98.85% | 0.35% |
| -គីមីវិទ្យា | 100% | 99.05% | -0.95% | 99.00% | 99.05% | 0.05% |
| -ជីវវិទ្យា | 100% | 98.67% | -1.33% | 98.56% | 98.67% | 0.11% |
| -ផែនដីវិទ្យា | 100% | 99.30% | -0.70% | 99.20% | 99.30% | 0.10% |
| -ភូមិវិទ្យា | 100% | 99.28% | -0.72% | 99.15% | 99.28% | 0.24% |
| -ប្រវត្តិវិទ្យា | 100% | 99.46% | -0.54% | 99.22% | 99.46% | 0.24% |
| -សីលធម៌ | 100% | 99.42% | -0.58% | 99.30% | 99.42% | 0.12% |
| -ភាសាខ្មែរ | 100% | 99.17% | -0.83% | 99.10% | 99.17% | 0.07% |
| -គេហកិច្ច | 100% | 97.99% | -2.01% | 97.85% | 97.99% | 0.14% |
| -បារាំង | 100% | 98.28% | -1.72% | 98.14% | 98.28% | 0.14% |
| -អង់គ្លេស | 100% | 98.83% | -1.17% | 98.77% | 98.83% | 0.06% |
| សរុប | 100% | 99.14% | -0.86% | 99.05% | 99.14% | 0.09% |

**តារាងស្ថិតិស្ថានភាពមន្ត្រីអប់រំ ផ្នែកមធ្យមសិក្សាធៀបទៅនឹងឆ្នាំសិក្សា ២០១៧-២០១៨**

| បរិយាយ | ឆ្នាំសិក្សា 2016-2017 | | ឆ្នាំសិក្សា 2017-2018 | | កើន(+) | | ថយ(-) | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| -មន្ត្រីទីចាត់ការ | 127 នាក់ | 42 នាក់ | 123 នាក់ | 40 នាក់ | 00 នាក់ | 00 នាក់ | 04 នាក់ | 02 នាក់ |
| -គ្រូបង្រៀន | 1124 នាក់ | 436 នាក់ | 1,112 នាក់ | 436 នាក់ | 00 នាក់ | 00 នាក់ | 12 នាក់ | 00 នាក់ |
| -នាយក | 76 នាក់ | 02 នាក់ | 76 នាក់ | 02 នាក់ | 00 នាក់ | 00 នាក់ | 00 នាក់ | 00 នាក់ |
| -នាយករង | 85 នាក់ | 12 នាក់ | 87 នាក់ | 11 នាក់ | 02 នាក់ | 01 នាក់ | 00 នាក់ | 00 នាក់ |
| -បណ្ណារក្ស | 65 នាក់ | 60 នាក់ | 65 នាក់ | 60 នាក់ | 00 នាក់ | 00 នាក់ | 00 នាក់ | 00 នាក់ |

### ក.១.១.៥-ស្ថានភាពសិក្សាកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ៖

| ល.រ | ម្ចាស់ឧបត្ថម្ភ | ស្ថានភាពសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | សិស្សដើមឆ្នាំសិក្សា | | សិស្សជាប់មធ្យមភាគ | | សិស្សធ្លាក់មធ្យមភាគ | | សិស្សបោះបង់ការសិក្សា | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | ថវិកាកម្មវិធីបឋមភូមិ(PB) | 1582 | 940 | 1491 | 890 | 14 | 07 | 77 | 43 |
| 2 | ថវិកាកម្មវិធីទុតិយភូមិ(PB) | 120 | 72 | 120 | 72 | 0 | 0 | 0 | 0 |
| **សរុប** | | 1702 | 1012 | 1611 | 962 | 14 | 07 | 77 | 43 |

**ជាលទ្ធផល៖**

- កាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្ស
- សិស្សខិតខំសិក្សារៀនសូត្រ

❖ ការអនុវត្តកម្មវិធីទប់ស្កាត់សិស្សបោះបង់ការសិក្សា

- ពង្រឹងការអនុវត្តថវិកាកែលម្អសាលារៀនឱ្យបានល្អប្រសើរ
- គណៈគ្រប់គ្រងសាលាសហការជិតស្និទ្ធ ជាមួយអាជ្ញាធរដែនដី សហគមន៍ អង្គការដៃគូ ជួយទំនុកបម្រុងកុមារក្រីក្រ កំព្រា និងបំប៉នសិស្សរៀនយឺត
- បង្កើតឱ្យមានក្រុមមិត្តអប់រំមិត្ត
- រៀបចំរង្វាន់សម្រាប់សិស្សចុងឆ្នាំសិក្សា
- តាមដានអវត្តមានសិស្សឱ្យបានច្បាស់លាស់ និងទៀងទាត់
- មាតាបិតាឬអាណាព្យាបាលសិស្ស ជំរុញកូនឱ្យមករៀនទៀងទាត់

❖ ការអប់រំបំណិនជីវិត

- បំផុសស្មារតីដល់គណៈគ្រប់គ្រងសាលា អនុវត្តសកម្មភាពបំណិនជីវិតឱ្យមានសកម្មភាព តាមរយៈការរៀបចំសេវាបង្រៀន ការដឹកនាំសិស្សានុសិស្សអនុវត្តជាក់ស្តែង
- ពិនិត្យតាមដានការអនុវត្តកម្មវិធីអប់រំបំណិនជីវិត នៅតាមគ្រឹះស្ថានមធ្យមសិក្សាទូទាំងខេត្ត

❖ ការងារតម្រង់ទិសវិជ្ជាជីវៈ

- ផ្សព្វផ្សាយប្រឹក្សាអាជីពតាមគ្រឹះស្ថានមធ្យមសិក្សាសាធារណៈក្នុងថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩ បានចំនួន ៣,២១២នាក់ ស្រី១,៨២៤នាក់

### ក.១.១.៣-សាលាចំណេះទូទៅឯកជន (ថ្នាក់ទី៧-១២) ៖

| បរិយាយ | ឆ្នាំសិក្សា 2016-2017 | ឆ្នាំសិក្សា 2017-2018 | កើន (+) | ថយ (-) |
|---|---|---|---|---|
| សាលារៀន | 02 សាលា | 02 សាលា | 00 សាលា | |
| បន្ទប់រៀន | 44 បន្ទប់ | 44 បន្ទប់ | 00 បន្ទប់ | |
| ថ្នាក់រៀន | 22 ថ្នាក់ | 22 ថ្នាក់ | 00 ថ្នាក់ | |
| បុគ្គលិកអប់រំសរុប | 70 នាក់ | 73 នាក់ | 03 នាក់ | |
| បុគ្គលិកអប់រំស្រី | 33 នាក់ | 33 នាក់ | 00 នាក់ | |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិសរុប | 70 នាក់ | 70 នាក់ | 00 នាក់ | |
| បុគ្គលិកអប់រំមធ្យមសិក្សាបឋមភូមិស្រី | 33 នាក់ | 33 នាក់ | 00 នាក់ | |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិសរុប | 00 នាក់ | 00 នាក់ | 00 នាក់ | |
| បុគ្គលិកអប់រំមធ្យមសិក្សាទុតិយភូមិស្រី | 00 នាក់ | 00 នាក់ | 00 នាក់ | |
| សិស្សសរុប | 754 នាក់ | 895 នាក់ | 141 នាក់ | |
| សិស្សស្រី | 606 នាក់ | 719 នាក់ | 113 នាក់ | |
| សិស្សមធ្យមសិក្សាបឋមភូមិសរុប | 494 នាក់ | 560 នាក់ | 66 នាក់ | |
| សិស្សមធ្យមសិក្សាបឋមភូមិស្រី | 397 នាក់ | 461 នាក់ | 64 នាក់ | |
| សិស្សមធ្យមសិក្សាទុតិយភូមិសរុប | 260 នាក់ | 335 នាក់ | 75 នាក់ | |
| សិស្សមធ្យមសិក្សាទុតិយភូមិស្រី | 209 នាក់ | 258 នាក់ | 49 នាក់ | |

## ក.២.ឆាន់នាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### ការបំប៉ន និងសិក្ខាសាលា

- ចូលរួមសិក្ខាសាលា ស្តីពីការកសាងសមត្ថភាពបច្ចេកទេសកុំព្យូទ័រ សម្រាប់ការងារប្រឡង ឆ្នាំសិក្សា ២០១៦-២០១៧ ថ្ងៃទី០២-០៣ ខែកុម្ភៈ ឆ្នាំ២០១៧ នៅខេត្តសៀមរាប ចំនួន០២នាក់
- ចូលរួមសិក្ខាសាលា ស្តីពីកម្មវិធីការងារជ្រើសរើសនិស្សិតអាហារូបករណ៍ឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រ នៅតាមគ្រឹះស្ថានឧត្តមសិក្សា សម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨ ថ្ងៃទី ២៣-២៤ ខែកុម្ភៈ ឆ្នាំ ២០១៧ នៅសណ្ឋាគារមិត្តភាព ខេត្តកំពត ចំនួន២៤នាក់
- ចូលរួមសិក្ខាសាលាស្តីពី ការគ្រប់គ្រងសិស្សអាហារូបករណ៍ក្រីក្រ និងរៀបចំរបាយការណ៍អប់រំនៅមធ្យមសិក្សា ថ្ងៃទី២៩-៣០ ខែមីនា ឆ្នាំ២០១៧ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ ចំនួន ០៣នាក់
- ចូលរួមសិក្ខាសាលាស្តីពី ការពិនិត្យឡើងវិញនូវទិន្នន័យគោល EMIS ឆ្លើយតបនឹងសូចនាករ SDG4 ដល់ថ្នាក់រាជធានីខេត្ត ថ្ងៃទី ០៩-១១ ខែមីនា ឆ្នាំ២០១៧ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត ចំនួន ០១នាក់
- ចូលរួមសិក្ខាសាលា ស្តីពីការរៀបចំបំប៉ននាយកសាលាគោលដៅ ចំនួន១០០ ក្រោមក្របខ័ណ្ឌគម្រោងលើឯកសារណែនាំកម្រងសាលាមធ្យមសិក្សា ថ្ងៃទី ០៨-១២ ខែមេសា ឆ្នាំ២០១៧ នៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម ចំនួន០១នាក់
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើលទ្ធផលស្រាវជ្រាវបឋម ស្តីពីលទ្ធភាពក្នុងការដាក់បញ្ចូលភាសាបរទេស ជាមុខវិជ្ជាកាតព្វកិច្ចប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ថ្ងៃទី ២៤-២៦ ខែ មេសា ឆ្នាំ២០១៧ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ ចំនួន០២នាក់
- បើកវគ្គបំប៉នផ្សព្វផ្សាយ គំរូវិញ្ញាសាស្តង់ដារ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៧ នៅការិយាល័យអប់រំ យុវជន និងកីឡាស្រុកពញាក្រែក សិក្ខាកាមចូលរួមចំនួន ៥៤នាក់
- ចូលរួមសិក្ខាសាលា ការងារអនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃសម្រាប់អនុវិស័យមធ្យមសិក្សាជំហានទី២ ថ្ងៃទី១៥-១៦ ខែមិថុនា ឆ្នាំ២០១៧ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះសីហនុ ចំនួន ០២នាក់
- ចូលរួមវគ្គបំប៉ននាយក នាយករងសាលារៀន ថ្ងៃទី១៦-២៣ ខែមិថុនា ឆ្នាំ២០១៧ នៅសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តកំពង់ចាម ចំនួន ០១នាក់
- ចូលរួមសិក្ខាសាលាស្តីពី ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់គ្រោងផែនការថវិកាប្រចាំឆ្នាំ២០១៨ ថ្ងៃទី៦-៧ ខែកក្កដា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តតាកែវ ចំនួន ០១នាក់
- ចូលរួមសិក្ខាសាលា ស្តីពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង និងបែងចែកធនធានអប់រំ ថ្ងៃទី១៤-១៦ ខែតុលា ឆ្នាំ២០១៧ នៅសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តកំពត ចំនួន ០១នាក់
- ចូលរួមសិក្ខាសាលា ស្តីពីការបំប៉នគ្រូឧទ្ទេសថ្នាក់រាជធានីខេត្តលើខ្លឹមសារសៀវភៅណែនាំស្តីពីការអនុវត្តមូលនិធិកែលម្អសាលារៀន (SIF) ថ្ងៃ ១៥-១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅសាលាគរុកោសល្យ និងវិក្រឹតការ ខេត្តកំពត ចំនួន ០១នាក់

- សិក្ខាសាលាផ្សព្វផ្សាយប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ផ្អែកលើលទ្ធផលសម្រេច សម្រាប់សាលារៀនមធ្យមសិក្សា ថ្ងៃទី១០-១១ ខែកក្កដា ឆ្នាំ២០១៧ នៅស្រុកត្បូងឃ្មុំ សិក្ខាកាម ៧២នាក់
- ចូលរួមសិក្ខាសាលា ស្តីពីការងារបណ្ណាល័យ និងស្តង់ដារបណ្ណាល័យ សាលាមធ្យមសិក្សាថ្ងៃទី១១-១៤ ខែតុលា ឆ្នាំ ២០១៧ នៅអគារធនធាន នៅវិទ្យាល័យព្រះសីហនុ ខេត្តកំពង់ចាម ចំនួន ០៧នាក់
- ចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយសៀវភៅ នីតិវិធី អធិការកិច្ច ថ្ងៃទី២០-២១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅខេត្តកំពង់ចាម ចំនួន ០១នាក់
- ចូលរួមសិក្ខាសាលា ស្តីពីការរៀបចំទម្រង់ផ្សាភ្ជាប់រវាងផែនការប្រតិបត្តិប្រចាំឆ្នាំ ថ្នាក់រាជធានីខេត្ត ក្រុង/ស្រុក/ខណ្ឌ និងសាលារៀន ថ្ងៃទី០៩-១៣ ខែកក្កដា ឆ្នាំ២០១៧ នៅខេត្តកំពត ចំនួន ០១នាក់។
- **ផ្នែកផែនការនិងគ្រប់គ្រងជំនួយ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត**
  - បានបើកវគ្គបណ្តុះបណ្តាលស្តីពី ការកសាងផែនការអភិវឌ្ឍសាលាសម្រាប់មធ្យមសិក្សា ដោយទទួលបានការគាំទ្រកញ្ចប់ថវិកាសម្រាប់ភាពជាដៃគូក្នុងការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំ (CDPF) តាមរយៈអង្គការយូនីសេហ្វ (Unicief ) ដែលមានសមាសភាពចូលរួមជាមន្ត្រីទទួលបន្ទុកផែនការការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ចំនួន ០៧នាក់ និង នាយកវិទ្យាល័យទាំង ២៣ សាលាទូទាំងខេត្ត ដែលទទួលបាននូវការឯកភាពក្នុងការកំណត់ប្រតិទិនសម្រាប់ការកសាងផែនការអភិវឌ្ឍប្រចាំឆ្នាំថ្នាក់សាលា ក្នុងចន្លោះខែមករា និងខែកុម្ភៈ និងបញ្ជូនមកដល់ការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ក្នុងខែឧសភា រៀងរាល់ឆ្នាំ។

## ការប្រជុំបច្ចេកទេស ៖

សាលាសរុប ៧៧ បានប្រជុំបច្ចេកទេសមធ្យមសិក្សាចំនួន ៧ ដង ក្នុង ១ឆ្នាំ ។

## ការផ្សព្វផ្សាយ

- ផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ដំណើរការគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ផ្សព្វផ្សាយពីបទបញ្ញត្តិនិងកម្រិតវិន័យការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅតាមវិទ្យាល័យទូទាំងខេត្ត
- ផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃការប្រឡងនៅតាមគ្រឹះស្ថានមធ្យមសិក្សា
- ផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ការប្រឡងជ្រើសរើសសិស្សពូកែថ្នាក់ខេត្ត
- ផ្សព្វផ្សាយលទ្ធផលអាហារូបករណ៍ជ្រើសរើសនិស្សិតឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រឆ្នាំ២០១៧-២០១៨
- ផ្សព្វផ្សាយលិខិតណែនាំស្តីពី ការជួញដូរមនុស្ស ច្បាប់ចរាចរណ៍ និងគ្រឿងញៀន
- ផ្សព្វផ្សាយសេចក្តីណែនាំស្តីពីចលនាប្រឡងប្រណាំងបីល្អនៅតាមគ្រឹះស្ថានមធ្យមសិក្សា

## ការពិនិត្យតាមដាន និងវាយតម្លៃ

- ពិនិត្យតាមដានការងារគ្រប់គ្រង បង្រៀន និងរៀន ការងារបរិស្ថាន និងបំណិនជីវិត
- ពិនិត្យតាមដានការងារប្រឡងឆមាសលើកទី១ និងលើកទី២ ថ្នាក់ទី៧ ដល់ទី១២
- ពិនិត្យតាមដានការងារប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
- ពិនិត្យតាមដានការងារអាហារូបករណ៍សិស្សក្រីក្រ នៅតាមសាលាគោលដៅ

- ចុះពិនិត្យតាមដានការអនុវត្តថវិកា PB និងSIG
- ចូលរួមជាគណៈកម្មការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- ចូលរួមជាគណៈកម្មការប្រឡងជ្រើសរើសគ្រូបឋមសិក្សា និងមត្តេយ្យសិក្សា

## ខ-វឌ្ឍនភាពនៃសូចនាករផលសម្រេច

**ការវិភាគវឌ្ឍនភាពនៃសូចនាករផលសម្រេច**

| | ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ជាក់ស្តែងឆ្នាំ 2015-2016 | ចំណុចដៅឆ្នាំ 2016-2017 | ជាក់ស្តែងឆ្នាំ 2016-2017 | ស្ថានភាព |
|---|---|---|---|---|---|
| ១ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 48.01% | 49.00% | 51.51% | ↑ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | 52.83% | 53.00% | 56.98% | ↑ |
| ២ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | 15.98% | 17.00% | 17.48% | ↑ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ (ស្រី) | 17.62% | 18.00% | 19.82% | ↑ |
| ៣ | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ | 61.49% | 62.00% | 64.46% | ↑ |
| | អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ (ស្រី) | 64.24% | 65.00% | 67.82% | ↑ |
| ៤ | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 46.63% | 47.00% | 49.82% | ↑ |
| | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | 51.91% | 52.00% | 55.71% | ↑ |
| ៥ | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | 21.36% | 20.00% | 19.50% | ↑ |
| | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | 15.88% | 14.00% | 17.4% | ↓ |
| ៦ | ភាគរយសិស្សមធ្យមសិក្សាបឋមភូមិទទួលអាហារូបករណ៍ | 5.89% | 6.00% | 5.89% | → |
| ៧ | ភាគរយគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រី | 60.00% | 65.00% | 66.00% | ↑ |
| ៨ | ភាគរយសាលាមធ្យមសិក្សាមានបង្គន់អនាម័យ | | | | |
| | មធ្យមសិក្សាបឋមភូមិ | 73.60% | 100.00% | 90.00% | → |
| | មធ្យមសិក្សាទុតិយភូមិ | 100.00% | 100.00% | 100.00% | ↑ |
| ៩ | ភាគរយសាលាមធ្យមសិក្សាមានទឹកស្អាត | | | | |
| | មធ្យមសិក្សាបឋមភូមិ | 88.67% | 100.00% | 90.00% | → |
| | មធ្យមសិក្សាទុតិយភូមិ | 100.00% | 100.00% | 100.00% | ↑ |

<u>សម្គាល់:</u> ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

## គ-បញ្ហាប្រឈម៖

- សិស្សបោះបង់ការសិក្សា មកពីបញ្ហាជីវភាព ចំណាកស្រុក រៀបការ និងការយល់ដឹងពីតម្លៃនៃការសិក្សារៀនសូត្ររបស់មាតាបិតា ឬអាណាព្យាបាលនៅមានកម្រិត
- ខ្វះអគារសិក្សា និងបន្ទប់រៀន នៅតំបន់មួយចំនួនមិនទាន់គ្រប់គ្រាន់តាមស្តង់ដារនៅឡើយ
- ខ្វះកន្លែងស្នាក់នៅរបស់គ្រូ

- ខ្វះបណ្ណាល័យ បន្ទប់ពិសោធន៍ ធនធានសម្ភារ និងធនធានមនុស្ស បម្រើឱ្យដំណើរការបង្រៀនទ្រឹស្តី និងការអនុវត្តជាក់ស្តែង
- នាយកសាលា បង្រៀនផង និងគ្រប់គ្រងផង
- ខ្វះគ្រូ នៅតំបន់ជួបការលំបាក
- ផ្នែកអប់រំវិជ្ជាជីវៈជម្រើស និងបំណិនជីវិតតាមមូលដ្ឋានពុំមានដំណើរការល្អ ដោយខ្វះគ្រូជំនាញ
- សិស្សទទួលបានអាហារូបករណ៍នៅតែប្រឈមនឹងការបោះបង់ការសិក្សា

## ២.២.៤. អនុវិស័យការអប់រំក្រៅប្រព័ន្ធ

### ក.លទ្ធផលសម្រេចបាន

### ក.១.ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ស្រុកដែលបានអនុវត្តកម្មវិធីអក្ខរកម្មមាន ៦ស្រុក កម្មវិធីបង្កើនប្រាក់ចំណូលនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍មាន ៦ស្រុក កម្មវិធីក្រោយអក្ខរកម្មមាន ២ស្រុក កម្មវិធីចូលរៀនឡើងវិញមាន ៦ស្រុក កម្មវិធីបំពេញវិជ្ជាមាន ៤ ក្រុង/ស្រុក និងកម្មវិធីសមមូលបឋមសិក្សាមាន ៤ស្រុក។

បើធៀបនឹងឆ្នាំសិក្សា២០១៥-២០១៦ កម្មវិធីសមមូលបឋមសិក្សាកើនចំនួន ១ស្រុក គឺនៅស្រុកមេមត់ និងថ្នាក់រៀនកើនបានចំនួន១០ថ្នាក់ ។

**ក.១.១-កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ៖**

អនក្ខរជនអាយុ ១៥ ដល់ ៤៥ ឆ្នាំ មានចំនួន ៣៦,៤៣៦ នាក់ ស្រី ២៦,១៤៩ នាក់ ចំពោះអត្រាអក្ខរកម្មជនពេញវ័យ១៥ឆ្នាំឡើង នៅឆ្នាំ២០១៦ មាន៩០.៤៧ភាគរយ និងនៅឆ្នាំ២០១៧នេះមាន ៩០.៧១ភាគរយ។ មន្ទីរអប់រំ យុវជន និងកីឡាខេត្តបានប្រារព្ធទិវាអក្ខរកម្មជាតិ ៨ កញ្ញានៅស្រុកតំបែរ ក្រោមប្រធានបទ " អក្ខរកម្មផ្សារភ្ជាប់នឹងសហគមន៍ " ដែលមានអ្នកចូលរួម៥០០នាក់ ស្រី ៦០ភាគរយ ។

ថ្នាក់អក្ខរកម្ម បានអនុវត្តមានចំនួន ២៧ភូមិ ២០ឃុំ ៦ស្រុក ក្នុងចំណោមក្រុង/ស្រុកទាំង៧ ដែលមានគ្រូអក្ខរកម្មចំនួន ៣០នាក់ ស្រី ១៤នាក់ គ្រប់គ្រងដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្តមានដូចខាងក្រោម៖

- ដំណើរការរយៈពេល ៨ ខែ ចាប់ពីខែ មីនា ដល់ខែ តុលា
- ម៉ោងសិក្សាចាប់ពីម៉ោង ១៨:០០ នាទី ដល់ម៉ោង ២០:០០ នាទីយប់
- បង្រៀនតាមសៀវភៅថ្នាក់ជាតិ ពីភាគ ១ ដល់ភាគ ៣
- ថ្នាក់រៀនដំណើរការនៅក្រោមផ្ទះប្រជាពលរដ្ឋ
- គ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលរយៈពេល ១០ ថ្ងៃ
- សិស្សអក្ខរកម្មមានចំនួន ៦៥១នាក់ ស្រី៤១៧នាក់ លទ្ធផលរំដោះសរុប ៥៥០នាក់ ស្រី ៣៥៦នាក់ ស្មើនឹង ៨៤.៤៨ភាគរយ។

**តារាងស្ថិតិថ្នាក់ គ្រូ សិស្ស កម្មវិធីអក្ខរកម្ម**

| បរិយាយ | 2015-2016 | | 2016-2017 | | កើន(+)/ថយ(-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូសរុប | 30 | 12 | 30 | 14 | 0 | +2 |
| សិស្សសរុប | 626 | 385 | 651 | 417 | +25 | +32 |

**ក.១.២.កម្មវិធីចូលរៀនឡើងវិញ ៖**

ការអនុវត្តកម្មវិធីចូលរៀនឡើងវិញបានរួមចំណែកបង្កឱកាស ឱ្យសិស្សបោះបង់អាចបន្តការសិក្សាតាមសាលារៀននៅក្នុងប្រព័ន្ធឡើងវិញ។ សិស្សបោះបង់ការសិក្សានៅកម្រិតបឋមសិក្សាក្នុងឆ្នាំសិក្សា ២០១៥-២០១៦ មាន ៣,២៨៧នាក់ ស្រី១,៤៥៦នាក់ ដែលទាមទារឱ្យពង្រីកការអនុវត្តកម្មវិធីចូលរៀនឡើងវិញមានដូចខាងក្រោម៖

- កម្មវិធីចូលរៀនឡើងវិញ ដំណើរការសិក្សានៅតាមសាលាក្នុងប្រព័ន្ធពីថ្នាក់ទី៣ ដល់ទី៦
- ម៉ោង និងកម្មវិធីសិក្សាអនុវត្តនៅមហាវិស្សមកាលចាប់ពីថ្ងៃ ០១ ខែកញ្ញាដល់ ៣១ ខែតុលា ឆ្នាំ ២០១៧ មួយសប្តាហ៍បង្រៀន ០៦ ថ្ងៃ ក្នុង១ ថ្ងៃ ៤ម៉ោង ក្នុង១ ម៉ោងស្មើ ៤៥ នាទី លើមុខវិជ្ជា គណិតវិទ្យា និងភាសាខ្មែរ បង្រៀនតាមសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានជ្រើសរើសគ្រូក្នុងប្រព័ន្ធ ដោយទទួលបានការបណ្តុះបណ្តាលរយៈពេល ៣ ថ្ងៃ
- ថ្នាក់រៀនមានចំនួន ៤៥ ថ្នាក់
- គ្រូសរុប ៤៥ នាក់ ស្រី១៨ នាក់
- សិស្សចូលរៀនចំនួន ៩២៥នាក់ ស្រី ៤១៣ នាក់ លទ្ធផលបានបញ្ជូនសិស្សចូលសាលា ក្នុងប្រព័ន្ធវិញចំនួន ៨៣៧នាក់ ស្រី ៣៨៨ នាក់ ស្មើនឹង ៩០.៤៨ភាគរយ

**តារាងស្ថិតិថ្នាក់ គ្រូ សិស្ស កម្មវិធីចូលរៀនឡើងវិញ**

| បរិយាយ | 2015-2016 | | 2016-2017 | | កើន(+)/ថយ(-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូសរុប | 45 | 24 | 45 | 18 | 0 | -6 |
| សិស្សសរុប | 916 | 380 | 925 | 413 | +9 | +33 |

**ក-១.៣.កម្មវិធីសមមូល-បំពេញវិជ្ជា ៖**

**ក-១.៣.១.កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ៖**

ថ្នាក់កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ បានជួយដល់មុខសញ្ញាដែលគ្មានឱកាសចូលរៀនតាមសាលាអប់រំក្នុងប្រព័ន្ធ ឱ្យបានរៀនចប់កម្រិតបឋមសិក្សាមានដំណើរការដូចខាងក្រោម៖

- កម្មវិធីសមមូលបឋមសិក្សាត្រូវបានបង្រៀន ២ម៉ោង ក្នុង១ថ្ងៃ (បង្រៀនពី ថ្ងៃចន្ទ ដល់ថ្ងៃសៅរ៍)
- ម៉ោង និងកម្មវិធីសិក្សា អនុវត្តតាមកម្មវិធីសមមូលបឋមសិក្សាក្រៅប្រព័ន្ធ
- គ្រូបង្រៀន សរុប ២១ នាក់ ស្រី០៤ នាក់ កើន៤៧.៦២% ស្រី កើន៥០%
- ថ្នាក់កម្មវិធីសមមូលបឋមសិក្សាចំនួន ២១ ថ្នាក់ មានសិស្សសរុបចំនួន ៤៣២ នាក់ ស្រី ២៤៤ នាក់ ឆ្នាំទី១មានចំនួន១៣ថ្នាក់ មានសិស្សសរុប ២៧៤នាក់ ស្រី១៦៣នាក់ បានបញ្ចប់ថ្នាក់ឆ្នាំទី១សរុប ២២០នាក់ ស្រី ១៣៧ នាក់ ស្មើនឹង ៨០.២៩ភាគរយ និងឆ្នាំទី២មានចំនួន ៨ថ្នាក់ មានសិស្សសរុប ១៥៨នាក់ ស្រី៨១នាក់ បានបញ្ចប់ថ្នាក់ឆ្នាំទី២សរុប ១២៦នាក់ ស្រី ៦៥ នាក់ ស្មើនឹង ៧៩.៧៥ភាគរយ សរុបចំនួនសិស្សដែលបានបញ្ចប់ថ្នាក់ឆ្នាំទី១ និងទី២ មានចំនួន ៣៤៦ នាក់ ស្រី២០២នាក់ ស្មើនឹង ៨០.០៩ភាគរយ ។

**តារាងស្ថិតិថ្នាក់ គ្រូ សិស្ស/អ្នករៀន កម្មវិធីសមមូលបឋមសិក្សា**

| បរិយាយ | 2015-2016 | | 2016-2017 | | កើន(+)/ថយ(-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូសរុប | 11 | 2 | 21 | 4 | +11 | +2 |
| សិស្សសរុប | 215 | 127 | 432 | 244 | +217 | +117 |

### ក១.៣.២.ថ្នាក់បំពេញវិជ្ជា៖

កម្មវិធីនេះ ផ្តល់ការអប់រំនៅកម្រិតមធ្យមសិក្សាដល់អ្នកសិក្សាដែលពុំមានឱកាសគ្រប់គ្រាន់ ដើម្បីឱ្យពួកគេបានរៀន និងប្រឡងបញ្ចប់កម្រិតសិក្សានីមួយៗ ហើយទទួលបានវិញ្ញាបនបត្រ សញ្ញាបត្រដែលមានតម្លៃស្មើកម្រិតមធ្យមសិក្សាចំណេះទូទៅ។

- បំពេញវិជ្ជាបឋមភូមិ
  - សិស្សបំពេញវិជ្ជាថ្នាក់ទី៩ ចំនួន៤៩នាក់ ស្រី១១នាក់ ក្នុងនោះបានដាក់ពាក្យប្រឡងចំនួន ៣៦នាក់ ស្រី៦នាក់ ប្រឡងជាប់មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជាចំនួន ៣៦នាក់ ស្រី ៦នាក់ ស្មើនឹង ១០០ភាគរយ។
- បំពេញវិជ្ជាទុតិយភូមិ
  - សិស្សមធ្យមសិក្សាទុតិយភូមិចំនួន ១៤៤ នាក់ ស្រី៦៨នាក់ មកប្រឡង១៣២នាក់ ស្រី៦២នាក់ បានប្រឡងជាប់៨៩នាក់ ស្រី ៤៥នាក់ ស្មើនឹង ៦៧.៤២ភាគរយ ស្រី ៧២.៥៨ភាគរយ ។
  - សិស្សស្វ័យរិនសរុបចំនួន ៩៧នាក់ស្រី ៥០នាក់ មកប្រឡង ៨៧នាក់ ស្រី៤៤នាក់ បានប្រឡងជាប់ ៦៦នាក់ ស្រី ៣២នាក់ ស្មើនឹង ៧៥.៥៨ភាគរយ ស្រី៧២.៧២ភាគរយ ។

**តារាងស្ថិតិថ្នាក់ គ្រូ និងសិស្ស មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិបំពេញវិជ្ជា**

| បរិយាយ | មធ្យមសិក្សាបឋមភូមិបំពេញវិជ្ជា | | | | | | មធ្យមសិក្សាទុតិយភូមិបំពេញវិជ្ជា | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2015-2016 | | 2016-2017 | | កើន(+)/ថយ(-) | | 2015-2016 | | 2016-2017 | | កើន(+)/ថយ(-) | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូ | ប្រើប្រាស់គ្រូអប់រំក្នុងប្រព័ន្ធ | | | | | | | | | | | |
| សិស្ស | 45 | 21 | 49 | 11 | +4 | -10 | 304 | 157 | 241 | 117 | -63 | -40 |

### ក-១.៤.កម្មវិធីបង្កើនប្រាក់ចំណូលតាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍ ៖

- មជ្ឈមណ្ឌលសិក្សាសហគន៍មានចំនួន ៦ កន្លែង នៅស្រុកត្បូងឃ្មុំ ពញាក្រែក តំបែរ មេមត់ ក្រូចឆ្មារ និង អូររាំងឪ ។ ដំណើរការថ្នាក់ជំនាញចំនួន១២ថ្នាក់ មានជំនាញកាត់ដេរ៤ថ្នាក់ កែសម្ផស្ស៤ថ្នាក់ ភ្លេងពិណពាទ្យ១ថ្នាក់ ភ្លេងប្រពៃណី១ថ្នាក់ និងថ្នាក់កុំព្យូទ័រ១ថ្នាក់ ។ សិក្សារយៈពេល៦ខែ ចាប់ពីថ្ងៃទី ០១ ខែមេសា ដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៧ ។
- សិស្សចូលរៀនសរុប២០២ នាក់ស្រី ១៥៣ នាក់ លទ្ធផលសម្រេចបាន១៤៦ នាក់ស្រី ១១៥ នាក់ស្មើនឹង ៧២.២៧ភាគរយ ។

**តារាងស្ថិតិថ្នាក់ គ្រូជំនាញ អ្នករៀនជំនាញមុខរបរ និងមជ្ឈមណ្ឌលសិក្សាសហគមន៍**

| បរិយាយ | 2015-2016 | | 2016-2017 | | កើន(+)/ថយ(-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| គ្រូជំនាញសរុប | 12 | 8 | 12 | 9 | 0 | +1 |
| អ្នករៀនជំនាញសរុប | 220 | 151 | 202 | 153 | -18 | +2 |

**ក.១-៥.កម្មវិធីក្រោយអក្ខរកម្ម-មណ្ឌលអាន និងបណ្ណាល័យ ៖**

- មណ្ឌលអានមាន ០១ កន្លែង នៅស្រុកក្រូចឆ្មារ ដែលមានអ្នកចូលអានចំនួន ២៤៥នាក់ ស្រី ១១២ នាក់។
- បណ្ណាល័យមានចំនួន ០១ កន្លែង សម្រាប់សហគមន៍ចូលអាន និងស្រាវជ្រាវ នៅស្រុកត្បូងឃ្មុំ ដែលមានអ្នកចូលអាន ២៦៣ នាក់ ស្រី ១២៤ នាក់។
- ជ្រុងអានមាន ២កន្លែង (ក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍ទួលកណ្តោល និងវាលម្លូ) មានអ្នកចូលអានសរុប ២៣៥នាក់ ស្រី១០៦នាក់ ។

**តារាងស្ថិតិបណ្ណាល័យ មណ្ឌលអាន ជ្រុងអាន និងអ្នកចូលអាន**

| បរិយាយ | 2015-2016 | | 2016-2017 | | កើន(+)/ថយ(-) | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អ្នកចូលអានបណ្ណាល័យ | 620 | 248 | 263 | 124 | -357 | -124 |
| អ្នកចូលអានមណ្ឌលអាន | 1093 | 378 | 245 | 112 | -848 | -266 |
| អ្នកចូលអានក្នុងជ្រុងអាន(មជ្ឈមណ្ឌលសិក្សាសហគមន៍) | 0 | 0 | 235 | 106 | +235 | +106 |
| អ្នកចូលអានសរុប | 1713 | 626 | 743 | 342 | -970 | -284 |

## ក.២ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

ដោយអនុវត្តតាមផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ (ការិយាល័យអប់រំក្រៅប្រព័ន្ធ)បានអនុវត្តនូវផែនការសកម្មភាពរបស់ខ្លួនដោយបានបើកវគ្គបណ្តុះបណ្តាលវគ្គបំប៉នសិក្ខាសាលានិងការប្រជុំផ្សេងៗទៀតជូនមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់តាមមុខសញ្ញាដូចខាងក្រោម៖

- បណ្តុះបណ្តាលគ្រូអក្ខរកម្មជាប់កិច្ចសន្យាចំនួន១៨នាក់ ស្រី០៩នាក់ ស្តីពីបច្ចេកទេសនៃការបង្រៀននិងរៀនកម្មវិធីអក្ខរកម្ម
- សិក្ខាសាលាបំប៉នសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធឃុំ/សង្កាត់ ដោយមានសិក្ខាកាមសរុប ៧៧នាក់ ស្រី០៥នាក់ ស្តីពីការប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន និងការងារគ្រប់គ្រង និងដឹកនាំនៃការងារអប់រំក្រៅប្រព័ន្ធ
- សិក្ខាសាលាវិធីសាស្ត្រការកសាងទិន្នន័យព័ត៌មាន ដែលមានសិក្ខាកាមសរុប ៧៤នាក់ ស្រី០៥នាក់ ស្តីពីការកសាងទិន្នន័យ និងរបាយការណ៍អប់រំក្រៅប្រព័ន្ធ
- សិក្ខាសាលាពង្រឹងសមត្ថភាពគ្រូជំនាញមុខរបរ និងគណៈកម្មការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមានសិក្ខាកាមចូលរួមសរុប ៣០នាក់ ស្រី១១នាក់ ស្តីពីដំណើរការនៃការបង្រៀន និងរៀនជំនាញនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍
- សិក្ខាសាលាបំប៉នគ្រូកម្មវិធីចូលរៀនឡើងវិញចំនួន ៥៦ នាក់ ស្រី២១នាក់ ស្តីពីការរៀបចំមុនដំណើរការថ្នាក់ ពេលដំណើរការថ្នាក់ និងក្រោយបញ្ចប់ថ្នាក់កម្មវិធីចូលរៀនឡើងវិញ

- សិក្ខាសាលាបំប៉នគ្រូកម្មវិធីសមមូលបឋមសិក្សាចំនួន២១នាក់ ស្រី០៤នាក់ ស្តីពីការបង្រៀន និងរៀនថ្នាក់សមមូលបឋមសិក្សា និងការប្រើប្រាស់សៀវភៅ។

## ខ. វឌ្ឍនភាពនៃសូចនាករផលសម្រេច

សូចនាករផលសម្រេចរបស់អនុវិស័យអប់រំក្រៅប្រព័ន្ធ ធៀបនឹងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ សម្រេចបានដូចខាងក្រោម៖

**ការវិភាគវឌ្ឍនភាពនៃសូចនាករផលសម្រេច**

| | ការអប់រំក្រៅប្រព័ន្ធ | ជាក់ស្តែងឆ្នាំ ២០១៥-២០១៦ | ចំណុចដៅឆ្នាំ ២០១៦-២០១៧ | ជាក់ស្តែងឆ្នាំ ២០១៦-២០១៧ | ស្ថានភាព |
|---|---|---|---|---|---|
| **គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត** | | | | | |
| ១ | ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | 532 | 570 | 550 | ⇨ |
| ២ | ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | 215 | 430 | 432 | ⬆ |
| ៣ | ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍ | 6 | 6 | 6 | ⬆ |
| ៤ | ចំនួនកុមារដែលបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | 856 | 830 | 837 | ⬆ |
| ៥ | ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ | 180 | 200 | 146 | ⬇ |
| **គោលនយោបាយទី២៖ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់** | | | | | |
| ៦ | ក្រុង/ស្រុករៀបចំបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | 3 | 4 | 4 | ⬆ |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

## គ.បញ្ហាប្រឈម

- សិស្សអវត្តមាននៅរដូវធ្វើចម្ការ និងមករៀនយឺតយ៉ាវព្រោះរវល់នៅចម្ការ
- សិស្សធ្វើចំណាកស្រុកដើម្បីទៅប្រកបមុខរបរផ្សេងៗ
- ការចូលរួមពីអាជ្ញាធរមូលដ្ឋានមិនទាន់បានទូលំទូលាយលើការងារអប់រំក្រៅប្រព័ន្ធ
- ការយល់ដឹងអំពីកម្មវិធីអប់រំក្រៅប្រព័ន្ធរបស់ស្រទាប់មហាជននៅមានកម្រិតជាពិសេសកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ
- ការចុះពិនិត្យតាមដានជួបការលំបាកព្រោះត្រូវចុះទៅនៅពេលយប់ពីម៉ោង៥ ទៅម៉ោង៨យប់
- ការទុកដាក់សម្ភារ នៅមជ្ឈមណ្ឌលសិក្សាសហគមន៍ មិនទាន់បានត្រឹមត្រូវ
- សិស្សរៀនចប់ជំនាញមុខរបរមិនមានសម្ភារៈ និងធនធានក្នុងការបើកមុខរបរផ្ទាល់ខ្លួន
- នាយកដ្ឋានចេញសញ្ញាបត្របណ្តោះអាសន្នជូនបេក្ខជនមានភាពយឺតយ៉ាវ

## ២.២.៥-អនុវិស័យ ការអភិវឌ្ឍយុវជន ៖

### ក-លទ្ធផលសម្រេចបាន

### ក.១ ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ផ្អែកតាមគោលការណ៍ណែនាំ និងទិសដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ប្រចាំឆ្នាំសិក្សា ២០១៦-២០១៧ រយៈពេលមួយឆ្នាំសិក្សាកន្លងមកនេះ ការិយាល័យ យុវជន ខិតខំយកចិត្តទុកដាក់អនុវត្តភារកិច្ចទទួលបានលទ្ធផលដូចខាងក្រោម ៖

### ១-ការពង្រឹងសមត្ថភាពយុវជន

ក្នុងឆ្នាំសិក្សា ២០១៦-២០១៧ នេះ បានរៀបចំបង្កើតក្រុមប្រឹក្សាកុមារ-យុវជន គ្រប់ ក្រុង/ស្រុក ក្នុងនោះ បឋមសិក្សាចំនួន ២៩៤ សាលា អនុវិទ្យាល័យចំនួន ៥៤ សាលា វិទ្យាល័យចំនួន ២៣ សាលា និងបានរៀបចំបង្កើតក្រុមប្រឹក្សាយុវជន-កុមារ មានដូចខាងក្រោម ៖

- ក្រុមប្រឹក្សាយុវជន

ក្រុមប្រឹក្សាយុវជន បានបង្កើតចំនួន ២៣/២៣ វិទ្យាល័យទូទាំងខេត្តដែលមានសមាជិកគណកម្មាការប្រតិបត្តិចំនួន ២៥៣នាក់ ស្រី១៣៦នាក់ និងក្រុមប្រឹក្សាភិបាល ២៣ក្រុម មានសមាជិក ១២៦នាក់ ស្រី៩៣នាក់ ចែកចេញជា៖

- សាខាមានចំនួន ២០៨សាខាមានសមាជិកគណកម្មាធិការប្រត្តិបត្តិសាខាចំនួន១,៨៧២នាក់ ស្រី១,១២៣នាក់
- មានអនុសាខាមានចំនួន ១,២៤៨នាក់ មានសមាជិកចំនួន ៧,២៥៣នាក់ ស្រី៣,៦៩៩នាក់
- ទីប្រឹក្សាសរុបចំនួន ២៥៨នាក់ ស្រី៩៦នាក់

- ក្រុមប្រឹក្សាកុមារ

  - **វិទ្យាល័យ** ៖មានចំនួន ២៥៨សាខា មានសមាជិគណកម្មាធិការសាខាចំនួន ២,៣៥៨នាក់ ស្រី ១,២០២នាក់ និងអនុសាខាចំនួន ១,៥៤៨ មានសមាជិកចំនួន ១១,៤៥១នាក់ ស្រី៥,៨៣៤នាក់
  - **អនុវិទ្យាល័យ** ៖ អនុសាខាចំនួន ១,៥៦០ មានសមាជិកចំនួន ១២,០៥៣ នាក់ ស្រី ៦,១៤៧ នាក់

- សមាជិកក្រុមប្រឹក្សាកុមារសរុបចំនួន ១៣,៧៥៧ នាក់ ស្រី ៧,២០៨ នាក់
- ក្រុមប្រឹក្សាភិបាលចំនួន៥៤ មានសមាជិកសរុបចំនួន ៣២៤ នាក់ ស្រី ៧១ នាក់
- ទីប្រឹក្សាសរុបចំនួន ២៦០ នាក់ ស្រី ៩៣ នាក់។

  - **សាលាបឋមសិក្សា** ៖ បានបង្កើតក្រុមប្រឹក្សាកុមារពីថ្នាក់ទី៤-៦ ចំនួន ៣១៥ សាលាដែលមានសមាជិកគណៈកម្មាធិការប្រតិបត្តិចំនួន ២,៣៣៤ នាក់ ស្រី១,៦៤៩ នាក់ ចែកចេញជា ៖

- សាខាចំនួន ១,៤២៤ មានសមាជិកគណៈកម្មាធិការសាខាចំនួន ១២,៨១៦ នាក់ ស្រី ៦,៥៣៦ នាក់
- អនុសាខាចំនួន ៨,៥៤៤ មានសមាជិកចំនួន ៤២,១៩៤ នាក់ ស្រី២១,៥១៨ នាក់
- សមាជិកក្រុមប្រឹក្សាកុមារសរុបចំនួន ៥០,៧៣៨ នាក់ ស្រី ២៤,៧៣០ នាក់
- ក្រុមប្រឹក្សាភិបាលចំនួន ៣១៥ មានសមាជិកសរុបចំនួន ១,៨៩០នាក់ ស្រី ៣៥៩ នាក់
- ទីប្រឹក្សាសរុបចំនួន ១,៤២៤ នាក់ ស្រី ៤៨៣ នាក់។

- អំពីស្នាដៃក្នុងចលនាប្រឡងប្រណាំង ៣ ល្អ របស់កុមារ និងយុវជន

  - **កុមារ**មានស្នាដៃចលនា ៣ ល្អ

- កុមារដែលមានស្នាដៃសិស្សល្អ និងកូនល្អមានចំនួន ១២,៥៦០ នាក់ ស្រី៧,៧៦០នាក់។
- កុមារដែលមានស្នាដៃសិស្សល្អ និងមិត្តល្អមានចំនួន ២៦,១០៥ នាក់ ស្រី៣,៩៧៦ នាក់។
- កុមារដែលមានស្នាដៃមិត្តល្អ និងកូនល្អមានចំនួន ៦៤,៣០៣នាក់ ស្រី ៣៦,០៣៦ នាក់។
- កុមារដែលមានស្នាដៃចលនា ៣ ល្អ មានចំនួន ៥៧,០៧៦ នាក់ ស្រី ២៦,៩៧៦ នាក់។

  - **យុវជនមានស្នាដៃចលនា ៣ ល្អ**

- យុវជនដែលមានស្នាដៃសិស្សល្អ និងកូនល្អមានចំនួន ២៧,៧០៨នាក់ ស្រី១១,០១៣ នាក់
- យុវជនដែលមានស្នាដៃសិស្សល្អ និងមិត្តល្អមានចំនួន ៧៦,៧០៦នាក់ ស្រី ៤៧,០៦០ នាក់
- យុវជនដែលមានស្នាដៃមិត្តល្អ និងកូនល្អមានចំនួន ៥៩,៧០៦ នាក់ ស្រី ៤៤,០១០ នាក់
- ស្នាដៃ៣ល្អរបស់យុវជនមានចំនួន ៧៩,៧០១ នាក់ ស្រី ៣៧,៩៧៩ នាក់

**តារាងស្ថិតិក្រុមប្រឹក្សាយុវជន និងកុមារ សាលាបឋមសិក្សា និងមធ្យមសិក្សាប្រចាំឆ្នាំ សិក្សា ២០១៥-២០១៦ធៀប នឹងឆ្នាំសិក្សា ២០១៦-២០១៧ ៖**

| ល.រ | ឈ្មោះក្រុង/ស្រុក | បឋមសិក្សា | | កើន ឬ ថយ | អនុវិទ្យាល័យ | | កើន ឬ ថយ | វិទ្យាល័យ | | កើន ឬ ថយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំសិក្សា ២០១៥-២០១៦ | ឆ្នាំសិក្សា ២០១៦-២០១៧ | | ឆ្នាំសិក្សា ២០១៥-២០១៦ | ឆ្នាំសិក្សា ២០១៦-២០១៧ | | ឆ្នាំសិក្សា ២០១៥-២០១៦ | ឆ្នាំសិក្សា ២០១៦-២០១៧ | | |
| 1 | ក្រុងសួង | ០៨ | ១២ | ↑ | ០២ | ០២ | → | ០១ | ០១ | → | |
| 2 | ស្រុកត្បូងឃ្មុំ | ៧១ | ៨៣ | ↑ | ១០ | ១០ | → | ០៦ | ០៦ | → | |
| 3 | ស្រុកពញាក្រែក | ៦២ | ៦៧ | ↑ | ០៨ | ០៨ | → | ០៤ | ០៤ | → | |
| 4 | ស្រុកក្រូចឆ្មារ | ៤១ | ៤៥ | ↑ | ០៩ | ០៩ | → | ០៤ | ០៤ | → | |
| 5 | ស្រុកមេមត់ | ៧២ | ១០០ | ↑ | ១៣ | ១៣ | → | ០៣ | ០៣ | → | |
| 6 | ស្រុកតំបែរ | ៥២ | ៥៣ | ↑ | ០៨ | ០៨ | → | ០២ | ០២ | → | |
| 7 | ស្រុកអូររាំងឪ | ៣២ | ៣៥ | ↑ | ០៤ | ០៤ | → | ០៣ | ០៣ | → | |
| សរុប | | **៣៣៨** | **៣៩៥** | | ៥៤ | ៥៤ | | ២៣ | **២៣** | | |

<u>សម្គាល់:</u> ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

## ២.ការបណ្តុះបណ្តាលជំនាញដល់យុវជន

- បានបើកវគ្គផ្សព្វផ្សាយដល់យុវជនចំនួន ២,០០០នាក់ ស្រី ១,០៧៥ នាក់ ក្នុងវិទ្យាល័យ ២១ នៅត្រីមាសទី ១ និងទី២ ឆ្នាំ២០១៧ ស្តីពី "ការតម្រង់ទិសការសិក្សា និងទីផ្សារការងារ"
- យុវជន កុមារសហគមន៍មន្ត្រីរាជការថ្នាក់ដឹកនាំខេត្តប្រមាណ ១,៤៤០នាក់ ត្រូវបានចូលរួមទិវា១មិថុនា កុមារអន្តរជាតិ ២០១៧ នៅវិទ្យាល័យ សម្តេចម៉ែ ស្រុកត្បូងឃ្មុំ។
- យុវជននៅវិទ្យាល័យសម្តេចតេជោហ៊ុន សែនសួង ចំនួន ៣០០នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលការបញ្ញាបសហគ្រិនភាព ។
- ក្រុមប្រឹក្សាយុវជនចំនួន ១៥០នាក់ បានចូលរួមបូកសរុបសន្និបាតបីល្អថ្នាក់ខេត្ត
- យុវជនក្រៅសាលាចំនួន ២២ នាក់ទទួលបានការបណ្តុះបណ្តាលជំនាញភ្លេងពិណពាទ្យ និងភ្លេងខ្មែរ នៅឃុំវាលមូរ ស្រុកពញាក្រែក
- យុវជនចំនួន ២២ នាក់ បានទទួលការបណ្តុះបណ្តាលជំនាញកាត់ដេរ នៅឃុំកោងកាង ស្រុកពញាក្រែក
- យុវជនចំនួន ៣០ នាក់ទទួលបានការបណ្តុះបណ្តាលជំនាញរដ្ឋបាល កុំព្យូទ័រ នៅវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សួង ក្រុងសួង។

## ៣.កម្មវិធីទស្សនកិច្ច និងបោះជំរំ

- បានដឹកនាំក្រុមប្រឹក្សាយុវជនចំនួន ១៥០នាក់ ស្រី ៨៧នាក់ មកពី ៥ វិទ្យាល័យក្នុងស្រុក ត្បូងឃ្មុំ និង មេមត់ ចូលរួមទស្សនកិច្ចសិក្សារៀនសូត្រ អំពីដំណើរនៃការរៀបចំក្រុមប្រឹក្សាយុវជននៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន អម្ពវ័ននំជីក ស្រុកក្រូចឆ្មារ
- បានដឹកនាំក្រុមប្រឹក្សាយុវជនចំនួនន ១៥០នាក់ ស្រី ៨០នាក់ ចូលរួមទស្សនកិច្ចសិក្សារៀនសូត្រនៅសាលាបឋមសិក្សាវត្តបូព៌ខេត្តសៀមរាប

- បានដឹកនាំក្រុមប្រឹក្សាកុមារចំនួន ០៨ នាក់ ស្រី ០៤ នាក់ ចូលរួមទស្សនកិច្ចសិក្សារៀនសូត្រចាប់ពីថ្ងៃទី ០៤ ដល់ ០៨ ខែកញ្ញា ឆ្នាំ ២០១៧ ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡានៅខេត្តសៀមរាប
- បានដឹកនាំក្រុមប្រឹក្សាយុវជនចំនួន ០៨ នាក់ ស្រី ០៤ ចូលរួមដំណើរទស្សនកិច្ចសិក្សា រៀនសូត្រចាប់ពីថ្ងៃទី ២៤ ដល់ ២៨ ខែតុលា ឆ្នាំ២០១៧ ដែលរៀបចំឡើងដោយ ក្រសួង អប់រំ យុវជន និងកីឡា នៅខេត្តកោះកុង
- បានរៀបចំការបោះជំរំក្រុមប្រឹក្សាយុវជនចំនួន ៤៥០នាក់ ស្រី២២១ នាក់មកពីវិទ្យាល័យ ទាំង២៣ ទូទាំងខេត្ត ក្រោមប្រធានបទ "យុវជន និងសហគមន៍" ចាប់ពីថ្ងៃទី ១៣ ដល់ ១៨ ខែតុលា ឆ្នាំ២០១៧ នៅបរិវេណតារាងបាល់ទាត់វិទ្យាល័យ ហ៊ុនសែន ពញាក្រែក ស្រុកពញាក្រែក
- បានដឹកនាំសមាជិកក្រុមប្រឹក្សាយុវជនចំនួន ១២ នាក់ ស្រី ០៦នាក់ ចូលរួមបោះជំរំ ក្រុម ប្រឹក្សាយុវជនថ្នាក់ជាតិក្រោមប្រធានបទ " យុវជន និងការអភិវឌ្ឍជាតិ" ដែលរៀបចំឡើង ដោយក្រសួងអប់រំ យុវជន និងកីឡា ចាប់ ពីថ្ងៃទី ១៣ដល់ទី ១៩ ខែធ្នូ ឆ្នាំ២០១៧ នៅខេត្តកំពង់ធំ
- បានដឹកនាំសិស្សានុសិស្សដែលមានស្នាដៃល្អចំនួន ១២ នាក់ស្រី ០៦ នាក់(កូនល្អសិស្ស ល្អ មិត្តល្អ) ចូលរួមបូកសរុបការប្រឡងប្រណាំង ចលនាបីល្អដែលរៀបចំដោយក្រសួង អប់រំ យុវជន និងកីឡាចាប់ពីថ្ងៃទី ១៣ ដល់ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧នៅខេត្តសៀមរាប
- យុវជនស្ម័គ្រចិត្តក្រៅសាលាចំនួន ១៦នាក់ ស្រី៨ នាក់ បានចូលរួមទស្សនកិច្ចសិក្សានៅខេត្តរតនគិរី និងខេត្តសៀមរាប
- បានសហការជាមួយសាខាកាកបាទក្រហមខេត្តរៀបចំពិធីបំពាក់កន្សែងយុវជនកាកបាទក្រហម ០២ លើក ចំនួន ២០០ នៅវិទ្យាល័យ ហ៊ុន សែន ព្រែកអាជី និងវិទ្យាល័យ ហ៊ុន សែន ខ្នារ
- បានរៀបចំពិធីបំពាក់កន្សែងកាយរឹទ្ធិប្អូន ចំនួន ០៤ ស្រុក/ក្រុងចំនួន ២,០០០នាក់ស្រី ១,១២១នាក់
- យុវជនកាយរឹទ្ធិ និងកាកបាទក្រហមចំនួន ៦០០ នាក់ បានចូលរួមបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំចំនួន ០៣ លើក និង១០០ នាក់ចូលរួមទិវាកាកបាទក្រហមចំនួន ០១លើក នៅសាលាខេត្តត្បូងឃ្មុំ។

**ក.២ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់**

**១. ការកសាងលិខិតបទដ្ឋានស្តីពីការងារយុវជន និងកុមារ**

- បានរៀបចំសេចក្តីណែនាំ ពីការរៀបចំរចនាសម្ព័ន្ធក្រុមប្រឹក្សាយុវជន និងកុមារ និងគំរូរបាយការណ៍ប្រចាំឆ្នាំដល់គ្រឹស្ថានសិក្សាទូទាំងខេត្ត
- ចេញសេចក្តីណែនាំ ស្តីពីការពង្រីកចលនាកាយរឹទ្ធិជាតិកម្ពុជា និងធ្វើសេចក្តីណែនាំ ស្តីពីការរៀបចំសមាសភាព ក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិកាយរឹទ្ធិជាតិកម្ពុជា នៅថ្នាក់ក្រុង-ស្រុក
- បានរៀបចំកែសម្រួលសមាសភាពថ្នាក់ដឹកនាំកាយរឹទ្ធិជាតិកម្ពុជាខេត្តត្បូងឃ្មុំ ជូនទៅក្រសួងអប់រំ យុវជន និងកីឡា។

**២.ការអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកការងារយុវជន**

- បានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុការងារយុវជនថ្នាក់ខេត្ត ថ្នាក់ស្រុក និងសាលាចំនួន ៤៤ នាក់ ស្រី ០៣ នាក់ ស្តីពីការគ្រប់គ្រងការងារក្រុមប្រឹក្សាយុវជន និងកុមារ
- បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកការងារកាយរឹទ្ធិថ្នាក់ខេត្ត ថ្នាក់ស្រុក និងសាលាចំនួន ៥៧ នាក់ ស្រី ០៤ នាក់ ស្តីពីជំនាញកាយរឹទ្ធិកម្ម
- បានបញ្ជូនមន្ត្រីចំនួន ០៧ រូបចូលរួមសិក្សារៀនសូត្រពីរបៀបការរៀបចំ បោះជំរំចំនួន ០២ លើក នៅរមណីយដ្ឋានបឹងសំរិទ្ធិ ខេត្តកំពង់ធំ និងស្រុកកងមាសខេត្តកំពង់ចាម
- បានបញ្ជូនមន្ត្រី ០៣ រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពី មូលដ្ឋានគ្រឹះ កាយរឹទ្ធិកម្មនៅរាជធានីភ្នំពេញ
- បានបញ្ជូនមន្ត្រីចំនួន ០២ រូបចូលរួមកម្មវិធីបណ្តុះបណ្តាលស្តីពី កម្មវិធី យុវជននៅរាជធានីភ្នំពេញ។

### ៣.ការប្រជុំ

- បានប្រជុំមន្ត្រីការិយាល័យយុវជន ដើម្បីពង្រឹងអំពីរបៀបរបបធ្វើការងារនិងភារកិច្ចទទួលខុសត្រូវរបស់មន្ត្រីម្នាក់ៗ រៀងរាល់ខែ
- បានចូលរួម ប្រជុំការងារប្រចាំខែរបស់មន្ទីរ និងប្រជុំអាណត្តិថ្នាក់ដឹកនាំអប់រំទូទាំងខេត្ត ជារៀងរាល់ខែ
- បានចូលរួមរាល់កិច្ចប្រជុំវិសាមញ្ញនានាតាមការចាំបាច់របស់មន្ទីរ ។

### ៤.ការផ្សព្វផ្សាយ

- បានផ្សព្វផ្សាយលក្ខន្តិកៈក្រុមប្រឹក្សាកុមារកម្ពុជាគ្រប់ក្រុង/ស្រុក
- បានផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍យុវជន គ្រប់ក្រុង/ស្រុក
- បានផ្សព្វផ្សាយលក្ខន្តិកៈរបស់កាយរឹទ្ធិជាតិកម្ពុជា ។

### ៥.ការពិនិត្យតាមដាន និងវាយតម្លៃ

ឆ្នាំសិក្សា ២០១៦-២០១៧នេះ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ការិយាល័យយុវជន ក្រុង-ស្រុក បានចុះ ពិនិត្យតាមដានការពង្រឹងក្រុមប្រឹក្សា យុវជន-កុមារ ដោយប្រើប្រាស់ថវិកាកម្មវិធីឆ្នាំ ២០១៧ របស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តត្បូងឃ្មុំ ។

### ខ-វឌ្ឍនភាពនៃសូចនាករផលសម្រេច

**ការវិភាគវឌ្ឍនភាពនៃសូចនាករផលសម្រេច**

| | ការអភិវឌ្ឍយុវជន | ជាក់ស្តែងឆ្នាំ ២០១៥-២០១៦ | ចំណុចដៅឆ្នាំ ២០១៥-២០១៦ | ជាក់ស្តែងឆ្នាំ ២០១៥-២០១៦ | ស្ថានភាព |
|---|---|---|---|---|---|
| ១ | ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាលជំនាញខ្លីៗ | ២២ | ៣០ | ៧៧ | ↑ |
| ២ | ចំនួនយុវជនដែលទទួលការបណ្តុះបណ្តាលពីការងារស្ម័គ្រចិត្ត | ១,៥០០ | ១,៥០០ | ១,៣៧៣ | ↓ |
| ៣ | ចំនួនមជ្ឈមណ្ឌលយុវជន | | | | |
| ៤ | ចំនួនយុវជន និងកុមារបានចូលរួមដំណើរទស្សនកិច្ចសិក្សា | ១៥០ | ១០០ | ១៥០ | ↑ |
| ៥ | ភាគរយសិស្សថ្នាក់ទី៤-៩ចូលរួមក្នុងក្រុមប្រឹក្សា | ១០០% | ១០០% | ១០០% | ↑ |
| ៦ | ភាគរយសិស្សថ្នាក់ទី១០-១២ចូលរួមក្នុងក្រុមប្រឹក្សាយុវជន | ១០០% | ១០០% | ១០០% | ↑ |
| ៧ | ចំនួនយុវជនទទួលបានការអប់រំស្តីពី"ការតម្រង់ទិសការសិក្សា និងទីផ្សារការងារ | ២០០០ | ២៥០០ | ២២៥៤ | → |
| ៨ | ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលសហគ្រិនភាព | ២៥០ | ៣០០ | ៣០០ | ↑ |
| ៩ | ចំនួនយុវជនបានចូលរួមកម្មវិធីបោះជំរំ | ៣៥០ | ៤៥០ | ៤៥០ | ↑ |

*សម្គាល់:* ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

### គ.បញ្ហាប្រឈម

- ការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំគ្រប់គ្រង នៅតាមសាលាមួយចំនួនពុំទាន់យកចិត្តទុកដាក់ក្នុងការសហការអនុវត្តឱ្យបានស៊ីជម្រៅនៅឡើយ
- ខ្វះការចូលរួមគាំទ្រពីគណៈគ្រប់គ្រងសាលា គ្រូទទួលបន្ទុក និងអ្នកពាក់ព័ន្ធ
- ខ្វះមន្ត្រីទទួលបន្ទុកការងារយុវជនតាមសាលា
- គណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាយុវជន និងកុមារមួយចំនួនពុំទាន់យល់ច្បាស់នូវ តួនាទី ភារកិច្ចរបស់ខ្លួន
- ព័ត៌មានពាក់ព័ន្ធលើវឌ្ឍនភាពអនុវិស័យយុវជនពុំទាន់បានគ្រប់ជ្រុងជ្រោយ
- មន្ត្រីជំនាញទទួលបន្ទុកយុវជនពុំទាន់ទទួលបានការបណ្តុះបណ្តាលនៅឡើយ។

## ២.២.៦-អនុវិស័យ ការអប់រំកាយ និងកីឡា

### ក-លទ្ធផលសម្រេចបាន

### ក.១ ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

ផ្អែកតាមគោលការណ៍ណែនាំ និងទិសដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជននិងកីឡាខេត្ត ប្រចាំឆ្នាំសិក្សា ២០១៦-២០១៧រយៈពេលមួយឆ្នាំសិក្សាកន្លងមកនេះ ការិយាល័យអប់រំកាយ និង កីឡាខិតខំយកចិត្តទុកដាក់អនុវត្តភារកិច្ចទទួលបានលទ្ធផលដូចខាងក្រោម ៖

### ១ កីឡាសិស្ស និងមហាជន

- **ការប្រកួតកីឡាសិស្ស និងមហាជនថ្នាក់ខេត្ត**

រៀបចំការប្រកួតកីឡាសិស្ស បឋមសិក្សា មធ្យមសិក្សា និង មហាជនជម្រើសជើងឯកទូទាំងខេត្ត ប្រចាំឆ្នាំសិក្សា ២០១៦-២០១៧ លទ្ធផលទទួលបាន ៖

- **កីឡាសិស្សបឋមសិក្សា**

បានទទួលក្រុមកីឡាករ-ការិនី ចូលរួមធ្វើការប្រកួតកីឡាសិស្សបឋមសិក្សា ជម្រើសជើងឯកថ្នាក់ខេត្តចំនួន ១៣ ក្រុម មានកីឡាករ-ការិនីចំនួន ១៨៦ នាក់ ស្រី ៣០ នាក់ លើប្រភេទកីឡាចំនួន ០៤ ៖បាល់ទាត់ (កុមារា) បាល់ទះ (កុមារា) បាល់បោះ(កុមារា-កុមារី) និងអត្តពលកម្ម (កុមារា-កុមារី)លទ្ធផលៈ ទទួលបានក្រុម កីឡាករ-ការិនី ដែលមានចំណាត់ថ្នាក់ល្អ១,២,៣ បាល់ទាត់កុមារាចំនួន ០៣ ក្រុម បាល់ទះកុមារាចំនួន ០៣ ក្រុម បាល់បោះកុមារាចំនួន ០១ ក្រុម បាល់បោះកុមារីចំនួន ០១ ក្រុម និងអត្តពលកម្ម(កុមារា-កុមារី)ចំនួន ០៣ ក្រុម។

- **កីឡាសិស្សមធ្យមសិក្សា**

បានទទួលក្រុមកីឡាករ កីឡាការិនី ចូលរួមធ្វើការប្រកួតកីឡាសិស្សមធ្យមសិក្សាជម្រើសជើងឯក ថ្នាក់ខេត្ត ប្រចាំឆ្នាំសិក្សា២០១៦-២០១៧ មានចំនួន ៣៣ ក្រុម មានកីឡាករ-ការិនីចំនួន ៤៣០ នាក់ស្រី ១៩២ នាក់ លើប្រភេទកីឡាចំនួន ០៥ ៖បាល់ទាត់(បុរស-នារី) បាល់ទះ(បុរស-នារី) បាល់បោះ(បុរស-នារី) ប៊ូល(បុរស) និង អត្តពលកម្ម(បុរស-នារី)លទ្ធផលៈ ទទួលបានក្រុមកីឡាករ-ការិនី ដែលមានចំណាត់ថ្នាក់ល្អពីលេខ ១,២,៣ មាន៖ បាល់ទាត់(បុរស-នារី) ចំនួន ០៦ ក្រុម បាល់ទះ(បុរស-នារី) ចំនួន ០៦ ក្រុម បាល់បោះ (បុរស-នារី) ចំនួន ០៥ ក្រុម អត្តពលកម្ម(បុរស-នារី) ចំនួន ០៣ ក្រុម និង ប៉េតង់ ប៊ូល(បុរស) ចំនួន ០៣ ក្រុម។

- **កីឡាមហាជន**

បានទទួលក្រុមកីឡាករ កីឡាការិនី ចូលរួមធ្វើការប្រកួតកីឡាមហាជនជម្រើសជើងឯកថ្នាក់ខេត្ត ប្រចាំឆ្នាំ ២០១៧ មានចំនួន ៦៥ ក្រុម មានកីឡាករ កីឡាការិនីចំនួន ៨៨៨ នាក់ ស្រី ១៨៤ នាក់ លើប្រភេទ ចំនួន ០៥ ៖បាល់ទាត់(បុរស-នារី) បាល់ទះ(បុរស-នារី) បាល់បោះ(បុរស-នារី) អត្តពលកម្ម(បុរស-នារី) និង ប៉េតង់(បុរស-នារី) លទ្ធផលចំណាត់ថ្នាក់ល្អពីលេខ ១,២,៣ មាន៖ បាល់ទាត់(បុរស-នារី)ចំនួន ០៦ ក្រុម បាល់ទះ(បុរស-នារី)ចំនួន ០៦ ក្រុម បាល់បោះ(បុរស-នារី)ចំនួន ០៦ ក្រុម អត្តពលកម្ម(បុរស-នារី)ចំនួន ០៣ ក្រុមប៉េតង់(បុរស)ចំនួន ០៣ ក្រុម និង ប៉េតង់(នារី) ០២ ក្រុម។

បានទទួលក្រុមកីឡាករ ចូលរួមធ្វើការប្រកួតកីឡាបាល់ទាត់យុវជនអាយុ ២០ ឆ្នាំ ពានរង្វាន់អភិបាល នៃគណៈអភិបាលខេត្ត ជម្រើសជើងឯកថ្នាក់ខេត្តប្រចាំឆ្នាំ២០១៧ មានចំនួន ០៨ ក្រុម មានកីឡាករចំនួន ១៤ ៤ នាក់ ស្រី ០ នាក់ លើប្រភេទចំនួន ០១ ៖បាល់ទាត់(បុរស)លទ្ធផលៈ ទទួលបានក្រុមកីឡាករ ដែលមាន ចំណាត់ថ្នាក់ល្អពីលេខ ១,២,៣ មាន៖ បាល់ទាត់ចំនួន ០៣ ក្រុម។

## ២. ការប្រកួតកីឡាសិស្សបឋមសិក្សា សិស្សមធ្យមសិក្សា និងមហាជនទូទាំងប្រទេស និងការប្រកួតផ្សេងៗ

- **កីឡាសិស្សបឋមសិក្សា**

បានដឹកនាំក្រុមកីឡា ចំនួន ០៧ ក្រុម មានកីឡាករ កីឡាការិនីចំនួន ៩៦ នាក់ ស្រី ៤៨ នាក់ ចូលរួមប្រកួតកីឡាសិស្សបឋមសិក្សាជ្រើសរើសជើងឯកថ្នាក់ជាតិប្រចាំឆ្នាំសិក្សា២០១៦ -២០១៧ នៅមណ្ឌលរាជ ភ្នំពេញចាប់ពីថ្ងៃទី ០៥ ដល់ ១១ ខែ វិច្ឆិកា ឆ្នាំ២០១៧ លើប្រភេទកីឡា បាល់ទាត់(កុមារា-កុមារី) បាល់ទះ (កុមារា-កុមារី) បាល់បោះ (កុមារា-កុមារី) និងអត្តពលកម្ម (កុមារា-កុមារី) ជាលទ្ធផល ពុំទទួលបានចំណាត់ថ្នាក់។

- **កីឡាសិស្សមធ្យមសិក្សា**

បានដឹកនាំក្រុមកីឡាចំនួន ១១ ក្រុម មានកីឡាករ កីឡាការិនីចំនួន ១១៤ នាក់ ស្រី ៥៧ នាក់ ចូលរួម ប្រកួតកីឡាសិស្សមធ្យមសិក្សា ជ្រើសរើសជើងឯកថ្នាក់ជាតិប្រចាំឆ្នាំសិក្សា២០១៦-២០១៧ នៅមណ្ឌល ខេត្តកំពង់ចាម ចាប់ពីថ្ងៃទី ២៦ ខែ កញ្ញា ដល់ ០៥ ខែ តុលា ឆ្នាំ២០១៧ លើវិញ្ញាសា បាល់ទាត់(បុរស-នារី) បាល់ទះ(បុរស-នារី) បាល់បោះ(បុរស-នារី) អត្តពលកម្ម(បុរស-នារី)ប៉េតង់ ប៊ូល(បុរស-នារី)និងវាយកូនឃ្លីលើតុ (បុរស-នារី)។ លទ្ធផលៈ ចំណាត់ថ្នាក់លេខ១ មេដាយមាស ០២ គ្រឿង លើប្រភេទកីឡាបាល់បោះនារី និងលើប្រភេទកីឡាអត្តពលកម្ម ចោលដុំដែកនារី និងចំណាត់ថ្នាក់លេខ ៣ មេដាយសំរិទ្ធ ០៤ គ្រឿង លើប្រភេទកីឡាអត្តពលកម្ម ចោលថាសនារី លើប្រភេទកីឡាប៉េតង់ប៊ូលក្រុមបុរស និងលើប្រភេទកីឡា វាយកូនឃ្លីលើតុបុរស។

- **កីឡាមហាជន**

- បានដឹកនាំក្រុមកីឡាបាល់ទាត់ចំនួន ០១ ក្រុម មានកីឡាករចំនួន ៣០ នាក់ ស្រី ០ នាក់ ចូលរួមការប្រកួតកីឡាបាល់ទាត់ ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន លើកទី១១ ប្រចាំឆ្នាំ២០១៧ នៅមណ្ឌល ខេត្តព្រៃវែង ខេត្តកណ្តាល វគ្គទី ១ និងមណ្ឌលខេត្តកំពត វគ្គទី ២ ចាប់ពីថ្ងៃទី **២៤** ខែ **មករា** ដល់ **២៦** ខែ **មេសា** ឆ្នាំ ២០១៧ ជាលទ្ធផលពុំទទួលបានចំណាត់។
- បានដឹកនាំក្រុមកីឡាបាល់ទាត់ចំនួន ០២ ក្រុម មានកីឡាករចំនួន ៥០ នាក់ ស្រី ០ នាក់ ចូលរួមការប្រកួតកីឡាបាល់ទាត់យុវជនអាយុក្រោម ១៤ ឆ្នាំ និងយុវជនអាយុ ១៦ ឆ្នាំ ជម្រើសជើងឯកថ្នាក់ជាតិប្រចាំឆ្នាំ ២០១៧ នៅមណ្ឌលខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម វគ្គទី១ ចាប់ពីថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៧ ដល់ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៨ ជាលទ្ធផលបានឡើងទៅវគ្គទី២ ។
- បានដឹកនាំក្រុមកីឡាទ្រាញព្រ័ត្រចំនួន ០២ ក្រុម មានកីឡាករ កីឡាការិនីចំនួន ២០ នាក់ ស្រី ១០ នាក់ ចូលរួមសហការជាមួយសហព័ន្ធកីឡាទាញព្រ័ត្រកម្ពុជា ជម្រើសជើងឯកថ្នាក់ភូមិភាគប្រចាំឆ្នាំ២០១៧ នៅមណ្ឌលខេត្តត្បូងឃ្មុំ ចាប់ពីថ្ងៃទី ២៨-២៩ ខែ វិច្ឆិកា ឆ្នាំ២០១៧ ជាលទ្ធផល ចំណាត់ថ្នាក់លេខ១ មេដាយមាស ០១ គ្រឿង លើប្រភេទកីឡាទាញព្រ័ត្របុរស ចំណាត់ថ្នាក់ លេខ ៣ មេដាយសំរិទ្ធ ០១ គ្រឿង លើប្រភេទទាញព្រ័ត្រនារី។

## ក.២-ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

### ១.ការកសាង និងផ្សព្វផ្សាយលិខិតបទដ្ឋានស្តីពីការអប់រំកាយ និងកីឡា

- រៀបចំរចនាសម្ព័ន្ធផ្សេងៗ និងបំណែងចែកភារកិច្ចដល់មន្ត្រីការិយាល័យកីឡា
- រៀបចំផែនការអនុវត្តការងារ និងធ្វើប្រតិទិនការងារប្រចាំខែនីមួយៗ និងប្រចាំឆ្នាំ

- ពង្រឹងការងារអប់រំកាយ និងកីឡា ដើម្បីត្រៀមរៀបចំកីឡាស៊ីហ្គេមនៅឆ្នាំ ២០២៣
- រៀបចំផ្សព្វផ្សាយបទបញ្ជារួមសម្រាប់ការប្រកួតកីឡាសិស្ស និងមហាជន
- រៀបចំលិខិតបទដ្ឋានផ្សេងៗ ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និង សាលារៀន
- ផ្សព្វផ្សាយលិខិតបទដ្ឋានផ្សេងៗដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងគ្រឹះស្ថានសិក្សា
- រៀបចំលិខិតបទដ្ឋានផ្សេងៗ ពាក់ព័ន្ធការងារអប់រំកាយ និងកីឡា ជូនមន្ទីរ និងក្រសួង។

**២-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារៈកីឡា**

- ជួសជុលទីលានបាល់ទាត់ ០១ កន្លែងនៅវិទ្យាល័យ ហ៊ុន សែន ចារថ្មី ស្រុកតំបែរ។
- បានបែងចែកសម្ភារៈកីឡាទៅតាមក្រុង/ស្រុកទាំង៧ ក្នុងនោះវិទ្យាល័យចំនួន ១៧ និងអនុវិទ្យាល័យចំនួន ០២ ដែលសម្ភារៈទាំងនោះរួមមាន ខោអាវកីឡា ស្បែកជើងត្រាប៉ុង និងប៉ាតា បាល់ទាត់ បាល់ទះ បាល់បោះ សំណាញ់បាល់ទះ សំណាញ់បាល់ទាត់ សំណាញ់សី ក្រូណូម៉ែត្រ ប៉េតង់ប៊ូល ដុំដែក ៣ kg ដុំដែក ៤kg និងខ្សែព្រួរ។

**៣-ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំកាយ និងកីឡា និងកីឡាករ-កីឡាការិនី**

- បានចូលរួមសិក្ខាសាលាវគ្គអ្នកវាយតម្លៃអាជ្ញាកណ្តាលបាល់ទាត់នៅមជ្ឈមណ្ឌល និងសាលាបាល់ទាត់ជាតិបាទី
- បានចូលរួមវគ្គសិក្ខាសាលាស្តីពី លេខាគុ និងស្នងការប្រកួតកីឡាបាល់បោះ នៅរាជធានីភ្នំពេញ
- បានចូលរួមវគ្គសិក្ខាសាលា គ្រូបង្វឹកកីឡាទាញព្រ័ត្រកម្រិតមូលដ្ឋាន នៅរាជធានីភ្នំពេញ
- បានចូលរួមសហការជាមួយសហព័ន្ធកីឡាបាល់ទាត់កម្ពុជា បើកវគ្គសិក្ខាសាលា អាជ្ញាកណ្តាល បាល់ទាត់កម្រិតមូលដ្ឋាន នៅមណ្ឌលខេត្តត្បូងឃ្មុំ
- បានចូលរួមវគ្គបំប៉ន នាយក-នាយករងសាលាបឋមសិក្សានិងមធ្យមសិក្សា នៅខេត្តកំពង់ចាម
- បានចូលរួមវគ្គសិក្ខាសាលាអាជ្ញាកណ្តាលបាល់ទះកម្រិតមូលដ្ឋាន នៅខេត្តពោធិ៍សាត់
- បានចូលរួមសិក្ខាសាលាស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា សម្រាប់ការគ្រោងផែនការថវិកា ប្រចាំឆ្នាំ ២០១៨ នៅខេត្តតាកែវ
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយប្រដាល់គុនខ្មែរ នៅរាជធានីភ្នំពេញ
- បានបើកវគ្គសិក្ខាសាលាស្តីពីការប្រើប្រាស់សៀវភៅសិក្សាគោលមុខវិជ្ជាអប់រំកាយ និងកីឡា នៅស្រុកពញាក្រែក
- បានចូលរួមវគ្គសិក្ខាសាលាគ្រូបង្ហាត់កីឡាហែលទឹកកម្រិតមូលដ្ឋាន នៅខេត្តកំពង់ចាម។

**៤-ការប្រជុំ**

- បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែ និងលើកទិសដៅបន្តក្នុងការិយាល័យ ដើម្បីចូលរួមប្រជុំជាមួយការិយាល័យក្រោមឱវាទទាំង ១១ និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកទាំង០៧ ជារៀងរាល់ខែនៅមន្ទីរអប់រំ យុវជន និងកីឡា
- បានចូលរួមប្រជុំធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មដំណាច់ឆ្នាំ
- បានប្រជុំចាប់ឆ្នោតការប្រកួតកីឡាសិស្សបឋម មធ្យមសិក្សា និងមហាជនជម្រើសជើងឯកថ្នាក់ខេត្តប្រចាំឆ្នាំ ២០១៧

- បានចូលរួមមហាសន្និបាតបូកសរុបការងារ សហព័ន្ធបាល់ទះកម្ពុជានៅរាជធានីភ្នំពេញ
- បានចូលរួមមហាសន្និបាតលើកទី១១ ឆ្នាំ២០១៧ របស់សហព័ន្ធបាល់ទាត់កម្ពុជារាជធានីភ្នំពេញ
- បានចូលរួមប្រជុំការងារបច្ចេកទេសចម្រុះវិស័យអប់រំ
- បានចូលរួមប្រជុំស្តីពីការណែនាំការប្រកួតកីឡាសិស្សបឋមសិក្សា និងសិស្សមធ្យមសិក្សាជម្រើសជើងឯកថ្នាក់ជាតិប្រចាំឆ្នាំសិក្សា២០១៦-២០១៧
- បានចូលរួមប្រជុំស្តីពីការប្រកួតកីឡាបាល់ទាត់ជម្រើសជើងឯកយុវជនអាយុក្រោម១៤-១៦ ឆ្នាំ
- បានប្រជុំបច្ចេកទេសកីឡាបាល់ទាត់ បាល់ទះ បាល់បោះ អត្តពលកម្ម និងប៉េតង់ប៊ូល
- បានចូលរួមប្រជុំសន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំ២០១៥-២០១៦ និងលើកទិសដៅឆ្នាំសិក្សា២០១៦-២០១៧។

### ៥-ការពិនិត្យតាមដាន និងវាយតម្លៃ

- បានពិនិត្យតាមដាននិងវាយតម្លៃលើការងារអប់រំកាយ និងកីឡានៅគ្រឹះស្ថានសិក្សាចំនួន ១៣ ដង
- បានពិនិត្យតាមដាន និងវាយតម្លៃលើការងារហ្វឹកហាត់អប់រំកាយ និងកីឡានៅក្រៅសាលាចំនួន ១៥ ដង។

## ខ-វឌ្ឍនភាពនៃសូចនាករផលសម្រេច

**ការវិភាគវឌ្ឍនភាពនៃសូចនាករផលសម្រេច**

| | ការអប់រំកាយ និងកីឡា | ជាក់ស្តែងឆ្នាំ ២០១៥-២០១៦ | ចំណុចដៅឆ្នាំ ២០១៦-២០១៧ | ជាក់ស្តែងឆ្នាំ ២០១៦-២០១៧ | ស្ថានភាព |
|---|---|---|---|---|---|
| ១ | ចំនួនគ្រូអប់រំកាយ និងកីឡា | ៤៦នាក់ | ៦០នាក់ | ៥១នាក់ | → |
| ២ | ទីលានកីឡដ្ឋានខេត្ត | ០ កន្លែង | ១ កន្លែង | ០ កន្លែង | ↓ |
| ៣ | គ្រឹះស្ថានបឋម និងមធ្យមមាន៖<br>- ទីលានបាល់ទាត់<br>- ទីលានបាល់ទះ<br>- ទីលានបាល់បោះ | <br>០ កន្លែង<br>០៣ កន្លែង<br>០១ កន្លែង | <br>០៧កន្លែង<br>០៧កន្លែង<br>០៧កន្លែង | <br>០១ កន្លែង<br>០ កន្លែង<br>០ កន្លែង | → |
| ៤ | ចំនួនមេដាយក្នុងការប្រកួតកីឡានានា<br>- មាស<br>- ប្រាក់<br>- សំរិទ្ធ | <br>០ គ្រឿង<br>០ គ្រឿង<br>០ គ្រឿង | <br>០៥ គ្រឿង<br>០៥គ្រឿង<br>០៦ គ្រឿង | <br>០៣ គ្រឿង<br>០ គ្រឿង<br>០៦ គ្រឿង | → |

សម្គាល់: ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

## គ-បញ្ហាប្រឈម

- គ្មានកីឡដ្ឋានខេត្ត
- ការផ្តល់គ្រូអប់រំកាយ និងកីឡា មិនទាន់គ្រប់គ្រាន់ទៅតាមតម្រូវការ
- ខ្វះការចូលរួមគាំទ្រពីសប្បុរសជន និងអ្នកពាក់ព័ន្ធ
- សម្ភារៈ និង ទីលានកីឡាមិនទាន់គ្រប់គ្រាន់តាមតម្រូវការនៅតាមគ្រឹះស្ថានសិក្សា
- សមត្ថភាពមន្ត្រីទទួលបន្ទុកការងារបច្ចេកទេសអប់រំកាយ និងកីឡា មិនទាន់សមស្របតាមរីកចម្រើនរបស់វិស័យអប់រំកាយ និងកីឡា។

## ២.៣-សកម្មភាពនិងលទ្ធផលការងាររបស់សមាគមបុគ្គលិកសិក្សាខ្មែរ

### ១-ស្ថានភាពនៃសមាគមបុគ្គលិកសិក្សាខ្មែរ

សមាគមបុគ្គលិកសិក្សាខ្មែរ (ស.ប.ស.ខ) ខេត្តត្បូងឃ្មុំ មាន ០៨ អង្គភាពគឺ ៖ ការិយាល័យក្រោមឱវាទមន្ទីរ អប់រំ យុវជន និងកីឡាខេត្ត ការិយាល័យ អប់រំ យុវជន និងកីឡាក្រុងសួង ការិយាល័យ អប់រំ យុវជន និងកីឡាស្រុកត្បូងឃ្មុំ ការិយាល័យ អប់រំ យុវជន និងកីឡាស្រុកអូររាំងឪ ការិយាល័យ អប់រំ យុវជន និងកីឡាស្រុកពញាក្រែក ការិយាល័យ អប់រំ យុវជន និងកីឡាស្រុកមេមត់ ការិយាល័យ អប់រំ យុវជន និងកីឡាស្រុកតំបែរ និងការិយាល័យ អប់រំ យុវជន និងកីឡាស្រុកក្រូចឆ្មារមាន៖

- សមាជិក ស.ប.ស.ខ សរុបចំនួន ៤,៥៤៦នាក់ និវត្តជនមាន ៩៣៤នាក់
- ផ្ទេរចូល ៧នាក់ ស្រី៥នាក់
- ផ្ទេរចេញ ២៤នាក់ ស្រី១២នាក់
- សមាជិកសុំចូលថ្មីមាន ៦៥នាក់ ស្រី៣៥នាក់
- សមាជិកស្លាប់ ៣៣នាក់ ស្រី៨នាក់
- សពគូស្រករ ៩នាក់ ស្រី៥នាក់
- បានបើកប្រាក់ជូនសមាជិកសពចំនួន ១៦នាក់ ស្រី៣នាក់
- បានបើកប្រាក់ជូនសពគូស្រករចំនួន ៥នាក់ ស្រី១នាក់

ស.ប.ស.ខ ខេត្តត្បូងឃ្មុំ មានទីតាំងបណ្តោះអាសន្ននៅក្នុងបរិវេណសាលាបឋមសិក្សា ស ខេង ខ្នារ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។

### ២-ការលំបាក ៖

- បានបើកប្រាក់គរុមរណូបត្ថម្ភជូនដល់គ្រួសារសពមានការយឺតយ៉ាវដោយ មូលហេតុយើងកំពុងរៀបចំបើកប្រាក់តាមប្រព័ន្ធធនាគារ
- ការិយាល័យអប់រំយុវជននិងកីឡាស្រុក/ក្រុងខ្លះ ពុំសូវយកចិត្តទុកដាក់ចលនាគ្រូចេញថ្មីឲ្យចូលជាសមាជិកសមាគម
- ការិយាល័យអប់រំយុវជននិងកីឡាស្រុក/ក្រុងខ្លះយឺតយ៉ាវក្នុងការបញ្ជូលឯកសារមរណភាពដល់ ស.ប.ស.ខ ខេត្ត

### ៣-សន្និដ្ឋាន

ទោះបីមានការលំបាកយ៉ាងនេះក៏ដោយ គណៈកម្មាធិការ ស.ប.ស.ខ ខេត្តនៅតែខិតខំអនុវត្តការងារ ស.ប.ស.ខ ដោយឈរលើមនសិការទទួលខុសត្រូវឱ្យមានដំណើរការទាំងនៅមូលដ្ឋាន ក៏ដូចជានៅគណៈកម្មាធិការកណ្តាលឲ្យមានភាពរលូន និងឈានទៅរកភាពល្អប្រសើរនៅថ្ងៃអនាគត។

### ៤-សំណូមពរ ៖

- សូមឲ្យលោកប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក ជួយជំរុញលោកគ្រូអ្នកគ្រូដែលទើបចេញថ្មីចូលជាសមាជិក ស.ប.ស.ខ ខេត្តឲ្យបានទាំងអស់នៅតាមអង្គភាពនិមួយៗ
- សូមបញ្ជូនឯកសារបុគ្គលិក ឬគូរស្រករដែលទទួលមរណភាពឲ្យបានមុន ថ្ងៃ២២ នៃខែនិមួយៗ
- សូមឲ្យលោកប្រធានការិយាល័យអប់រំយុវជននិងកីឡាស្រុក/ក្រុងជួយផ្សព្វផ្សាយការងារ ស.ប.ស.ខ ឲ្យបានទូលំទូលាយទាំងការបង់ប្រាក់ភាគទានប្រចាំខែ និងការទទួលបាននូវប្រាក់គរុមរណូបត្ថម្ភដល់គ្រួសារសព ដោយសមាជិកទទួលបាន ៥,៦០០,០០០៛ និងគូស្រករទទួលបាន ២,៨០០,០០០៛ ចៀសវាងការឆ្លើយមិនដឹង និងលើសពីការកំណត់
- សូមឲ្យលោកប្រធានការិយាល័យអប់រំយុវជននិងកីឡាក្រុង/ស្រុក ត្រួតពិនិត្យឈ្មោះសមាជិកក្នុងស្រុករបស់ខ្លួនឲ្យបានត្រឹមត្រូវចៀសវាងកាត់ប្រាក់ភាគទានខុស។

# ទិសដៅ

# តាមអនុវិស័យ

# ឆ្នាំសិក្សា ២០១៧-២០១៨

# ៣-ទិសដៅឆ្នាំសិក្សា ២០១៧ - ២០១៨

ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ទាំងបញ្ហាប្រឈមតាមអនុវិស័យ និងបញ្ហាប្រឈមជាលក្ខណៈ អន្តរអនុវិស័យ និងផ្អែកលើបទពិសោធកន្លងមក មន្ទីរអប់រំ យុវជន និងកីឡាខេត្ត នឹងជម្រុញល្បឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនតាមទិសដៅដូចខាងក្រោម ៖

## ៣.១.ទិសដៅតាមអនុវិស័យ

### ៣.១.១.អនុវិស័យ ការអប់រំកុមារតូច

- បង្កើនការចូលរៀនរបស់កុមារអាយុ ៣ ឆ្នាំតាមគ្រប់រូបភាពកើនឡើងពី ១៧.១២ ភាគរយ ទៅដល់ ៣០ ភាគរយ នៅឆ្នាំសិក្សា២០១៧-២០១៨
- បង្កើនការចូលរៀនរបស់កុមារអាយុ ៤ឆ្នាំ តាមគ្រប់រូបភាពកើនឡើង ៤០.៩៦ភាគរយ ទៅដល់ ៤៣ភាគរយ នៅឆ្នាំសិក្សា២០១៧-២០១៨
- បង្កើនការចូលរៀនរបស់កុមារអាយុពី ៥ ឆ្នាំតាមគ្រប់រូបភាពកើនឡើងពី ៥៩ ភាគរយ ទៅដល់ ៦៥ ភាគរយ នៅឆ្នាំសិក្សា២០១៧-២០១៨
- ភាគរយកុមារតូចដែលគោរពតាមស្តង់ដាគុណភាពកើនពី ៣១ភាគរយ ដល់ ៣២ភាគរយ នៅឆ្នាំសិក្សា ២០១៧ -២០១៨
- ភាគរយកុមារតូចដែលអនុវត្តបានតេស្តទៀងទាត់ដើម្បីវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំកើនឡើងពី៤៦.៤៥ ភាគរយ ទៅដល់ ៧០ភាគរយ នៅឆ្នាំ២០១៧-២០១៨
- ភាគរយកុមារតូចក្នុងសេវាគាំពារនិងអភិវឌ្ឍកុមារតូច ដែលមានស្ថានភាពអាហារូបត្ថម្ភកើនឡើងពី១០.១២ ភាគរយ ទៅដល់១២ភាគរយ នៅឆ្នាំ ២០១៧-២០១៨
- ភាគរយកុមារតូចនៅតាមសាលាមត្តេយ្យសិក្សាសាធារណៈទទួលបានថ្នាំទម្លាក់ព្រូនកើនឡើងពី ៤៩.៩៦ ភាគរយ ទៅដល់ ៩៦ភាគរយ នៅឆ្នាំ២០១៧-២០១៨

### ៣.១.២.អនុវិស័យ ការអប់រំបឋមសិក្សា

- បង្កើនអត្រាពិតចូលរៀនថ្មី ៩៧.៣០ភាគរយ ដល់ ៩៩ភាគរយ នៅឆ្នាំ២០១៧-២០១៨
- បង្កើនអត្រាពិតនៃការសិក្សាពី ៩៥.១៦ភាគរយ ដល់ ៩៧ភាគរយ នៅឆ្នាំ២០១៧-២០១៨
- កាត់បន្ថយអត្រាបោះបង់ការសិក្សា ២.៣៨ភាគរយ មកត្រឹម ១.៥០ភាគរយ នៅឆ្នាំ២០១៧-២០១៨
- បង្កើនអត្រាបញ្ចប់ការសិក្សា ពី ៩២.១១ភាគរយ ដល់ ៩៥ភាគរយ នៅឆ្នាំ២០១៧-២០១៨
- កាត់បន្ថយអត្រាត្រួតថ្នាក់ ពី ៧.៥៨ភាគរយ មកត្រឹម ៣ភាគរយ នៅឆ្នាំ២០១៧-២០១៨
- បង្កើនអត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិពី ៩១.១៥ភាគរយ ដល់ ៩៥ភាគរយ នៅឆ្នាំ២០១៧-២០១៨
- ចំនួនស្រុកដែលសម្រេចអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាយ៉ាងតិច ៨០ភាគរយ ៧ ក្រុង/ស្រុក នៅឆ្នាំ ២០១៧-២០១៨
- បង្កើនភាគរយសិស្សថ្មីថ្នាក់ទី១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សាពី ៥៧ភាគរយ ដល់ ៧២ភាគរយ នៅឆ្នាំ ២០១៧-២០១៨

- បង្កើនភាគរយសាលាកុមារមេត្រីកម្រិតមធ្យមនិងអភិវឌ្ឍពី ៧៩ភាគរយ ដល់ ៨២ភាគរយ នៅឆ្នាំ២០១៧-២០១៨
- បង្កើនចំនួនសិស្សទទួលអាហារូបករណ៍នៅបឋមសិក្សាពី ៨២៩០នាក់ ដល់ ៨៤៤០នាក់ នៅឆ្នាំ២០១៧-២០១៨
- ផ្តល់សៀវភៅសិក្សាគោលនៅថ្នាក់ទី១ ដល់ទី៣ នៅតំបន់ជនបទ និងតំបន់ប្រជុំជនតាមផលធៀប ១:១ នៅឆ្នាំ ២០១៧-២០១៨
- ផ្តល់សៀវភៅសិក្សាគោលនៅថ្នាក់ទី៤ ដល់ ទី៦ នៅតំបន់ជនបទនិងតំបន់ប្រជុំជនតាមផលធៀប ១:១ នៅឆ្នាំ ២០១៧-២០១៨
- បង្កើនកន្លែងលាងសម្អាតដៃតាមសាលារៀនពី ៧៦ភាគរយ ដល់ ៨០ភាគរយ នៅឆ្នាំ២០១៧-២០១៨
- បង្កើនប្រអប់សង្គ្រោះបឋមតាមសាលារៀនពី ៥៦ភាគរយ ដល់ ៦៥ភាគរយ នៅឆ្នាំ២០១៧-២០១៨
- បង្កើនកម្មវិធីអប់រំបរិយាប័ន្នចំនួន ៣០ សាលា នៅឆ្នាំ២០១៧-២០១៨
- បំប៉នគ្រូបង្រៀនក្នុងកម្មវិធីអប់រំបញ្ចូលគ្នាចំនួន ១០០នាក់ នៅឆ្នាំ២០១៧-២០១៨
- ផ្សព្វផ្សាយពីកម្មវិធីអប់រំបញ្ចូលគ្នាឱ្យបាន ៤៥ សាលា នៅឆ្នាំ២០១៧-២០១៨

### ៣.១.៣.អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

- អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ១៩.៥០ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងថយចុះមកត្រឹម ១៩ ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៥១.៥១ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងកើនឡើងដល់ ៥៣ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ១៨.៤៨ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ និងកើនឡើងដល់ ១៨ ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ ២៤.៥៣ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងកើនឡើងដល់ ២៥ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ៨.១៩ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងកើនឡើងដល់ ៩ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- អត្រាឆ្លងភូមិសិក្សាពីម.បឋមភូមិទៅម.ទុតិយភូមិ ៦៤.៤៦ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងកើនឡើងដល់ ៦៥ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៤៩.៨២ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងកើនឡើងដល់ ៥០ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- ភាគរយសិស្សមធ្យមសិក្សាបឋមភូមិទទួលអាហារូបករណ៍ ៥.៨៩ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងកើនឡើងដល់ ៦ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- ចំនួនគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រី ៦៦ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងកើនឡើងដល់ ៦៧ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- ភាគរយសាលាមធ្យមសិក្សាមានបង្គន់អនាម័យនៅមធ្យមសិក្សាបឋមភូមិ ៩០ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងកើនឡើងដល់ ១០០ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨
- ភាគរយសាលាមធ្យមសិក្សាមានបង្គន់អនាម័យនៅមធ្យមសិក្សាទុតិយភូមិ ១០០ភាគរយ ឆ្នាំសិក្សា២០១៦-២០១៧ នឹងកើនឡើងដល់ ១០០ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨

- សាលាមធ្យមសិក្សា ៤០ភាគរយ បានអនុវត្តកម្មវិធីសិក្សាអប់រំបំណិនជីវិតនៅឆ្នាំ ២០១៦-២០១៧ បើប្រៀបនឹងឆ្នាំ ២០១៧-២០១៨ បាន ៧០ភាគរយ
- សាលាមធ្យមសិក្សា ៤២ភាគរយ ទទួលវគ្គបំប៉នផ្សព្វផ្សាយការងារតម្រង់ទិសវិជ្ជាជីវៈក្នុងឆ្នាំ ២០១៦-២០១៧ បើប្រៀបនឹងឆ្នាំ ២០១៧-២០១៨ បាន ៦៧.៥៣ភាគរយ

### ៣.១.៤.អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

- ពង្រីកថ្នាក់អក្ខរកម្មចំនួន ៣០ថ្នាក់ ដែលមានប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម ចំនួន ៦០០ នាក់ នៅឆ្នាំ ២០១៨
- ពង្រីកថ្នាក់សមមូលបឋមសិក្សាចំនួន ២១ថ្នាក់ និងសមមូលមធ្យមសិក្សាចំនួន ១ថ្នាក់ ដែលមានសិស្សចូលរៀនសរុប ៤៥០នាក់ នៅឆ្នាំសិក្សា ២០១៧-២០១៨
- ពង្រីកមជ្ឈមណ្ឌលសិក្សាសហគមន៍ពី ០៦កន្លែង ដល់ ៧កន្លែង នៅឆ្នាំ ២០១៨
- បង្កើនថ្នាក់កម្មវិធីចូលរៀនឡើងវិញចំនួន ៤១ថ្នាក់ ដែលមានសិស្សបញ្ជូនចូលក្នុងប្រព័ន្ធវិញចំនួន ៨២០នាក់ នៅឆ្នាំសិក្សា ២០១៧-២០១៨
- បង្កើនថ្នាក់កម្មវិធីបង្កើនប្រាក់ចំណូលចំនួន ១៨ថ្នាក់ ដែលមានអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញចំនួន ២២០នាក់
- ពង្រីកការកសាងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ ចំនួន ០៥ ស្រុកនៅឆ្នាំ ២០១៨ ។

### ៣.១.៥.អនុវិស័យ ការអភិវឌ្ឍយុវជន

- មន្ត្រីទទួលបន្ទុកកាយរឹទ្ធិចំនួន ៦០ នាក់ នឹងទទួលបានការបណ្តុះបណ្តាលវគ្គមូលដ្ឋានកាយរឹទ្ធិថ្នាក់ខេត្ត
- ចំនួនកាយរឹទ្ធិប្អូន និងកាយរឹទ្ធិក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សាចំនួន ១០០០ នាក់នឹងទទួលបានការ បណ្តុះបណ្តាល និងបំពាក់កន្សែង
- កុមារចំនួន ១៥០០ នាក់នឹងបានចូលរួមក្នុងពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី ៦៩ ទិវាកុមារអន្តរជាតិ ០១ មិថុនា ឆ្នាំ២០១៨
- យុវជនចំនួន ៥០០ នាក់នឹងបានចូលរួមក្នុងពីធីប្រារព្ធទិវាយុវជនអន្តរជាតិ ១២ សីហា ឆ្នាំ២១០៨
- យុវជនដែលមានស្នាដៃបីល្អ ចំនួន ២៥០ នាក់នឹងបានចូលរួមក្នុងពិធីសន្និបាតចលនាបីល្អថ្នាក់ខេត្ត
- យុវជនចំនួន ៥០០ នាក់នឹងទទួលបានការអប់រំ ផ្សព្វផ្សាយស្តីពី " ការប្រឹក្សាអាជីព"
- យុវជនក្នុងសាលាចំនួន ២០០ នាក់នឹងទទួលបានការអប់រំស្តីពីសហគ្រិនភាព
- យុវជនក្រៅសាលាចំនួន ១៥០ នាក់នឹងទទួលបានការអប់រំស្តីពីសហគ្រិនភាព
- ក្រុមប្រឹក្សាកុមារ និងយុវជនចំនួន ៣៥០ នាក់នឹងបានចូលរួមដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវ និងរៀនសូត្រ
- យុវជនដែលមានស្នាដៃបីល្អ ចំនួន ១៥ នាក់ នឹងបានចូលក្នុងសន្និបាតចលនាបីល្អ
- យុវជនចំនួន ៥០០ នាក់នឹងបានចូលរួមក្នុងកម្មវិធីបោះជំរំថ្នាក់ខេត្ត និងថ្នាក់ជាតិ
- សាលាបឋមចំនួន ៣០ និងមធ្យមសិក្សាចំនួន ២០ នឹងត្រូវបានត្រួតពិនិត្យតាមដានវាយតម្លៃ
- យុវជនស្ម័គ្រចិត្តក្រៅសាលាចំនួន ២០ នាក់នឹងបាចូលរួមដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវ និងរៀនសូត្រ
- យុវជនចំនួន ២៥ នាក់នឹងទទួលបានការបណ្តុះបណ្តាលជំនាញកាត់ដេរ
- យុវជនចំនួន ៦០ នាក់នឹងទទួលបានការបណ្តុះបណ្តាលជំនាញសិល្បៈ និងរបាំ
- យុវជនចំនួន ៦០ នាក់នឹងទទួលបានការបណ្តុះបណ្តាលវគ្គរដ្ឋបាលកុំព្យូទ័រ

### ៣.១.៦.អនុវិស័យ ការអប់រំកាយ និងកីឡា

- បង្កើតសមាគមកីឡាបាល់ទាត់ នៅតាមសហគមន៍អោយបានចំនួន ០១ ក្លឹប ក្រុងសួង នៅឆ្នាំ២០១៨

- ចូលរួមការប្រកួតកីឡាបាល់ទាត់ ពានរង្វាន់សម្តេច ហ៊ុន សែន លើកទី១២ មានក្រុមចូលរួម ០១ ប្រភេទកីឡា មានកីឡាករបាល់ទាត់បុរសចំនួន ១៨ នាក់
- ចូលរួមការប្រកួតកីឡាបាល់ទាត់យុវជនអាយុ ១៤-១៦ ឆ្នាំ មានក្រុមចូលរួម ០១ ប្រភេទកីឡា មានកីឡាករបាល់ទាត់បុរស-នារី ចំនួន ៥០ នាក់
- ចូលរួមការប្រកួតកីឡាទាញព្រ័ត្រ មានក្រុមចូលរួម ០២ ប្រភេទកីឡា មានកីឡាករទាញព្រ័ត្រ បុរស-នារី ចំនួន ២០ នាក់
- ចូលរួមការប្រកួតកីឡាអត្តពលកម្ម មានក្រុមចូលរួម ០១ ប្រភេទកីឡា មានកីឡាករអត្តពលកម្ម បុរស-នារី ចំនួន ១២ នាក់
- ចូលរួមការប្រកួតកីឡាជាតិលើកទី២ មានក្រុមចូលរួមឱ្យបាន០៧ ប្រភេទកីឡា មានកីឡាករបាល់ទាត់បុរស-នារី ចំនួន៣៦ នាក់ បាល់ទះបុរស-នារី២៤ បាល់បោះបុរស-នារី២៤ នាក់ ប៊ូលបុរស-នារី០៦ នាក់ អត្តពលកម្ម ១២ នាក់ ហែលទឹកបុរស-នារី២៥ នាក់ និងប្រដាល់សេរី ១០ នាក់
- លទ្ធផលការប្រកួតដណ្តើមមេដាយ ទូទាំងប្រទេសទទួលបាន
    - ការប្រកួតកីឡាបាល់ទាត់ ពានរង្វាន់សម្តេចហ៊ុន សែន លើកទី១២ មេដាយសំរិទ្ធ ០១ គ្រឿង
    - ការប្រកួតកីឡាទាញព្រ័ត្រថ្នាក់ភូមិភាគ មេដាយសំរិទ្ធ ០១ គ្រឿង
    - ការប្រកួតកីឡាបាល់ទាត់អាយុ ១៤-១៦ ឆ្នាំ មេដាយ សំរិទ្ធ ០១ គ្រឿង
    - ការប្រកួតកីឡាជាតិលើកទី ០២ មេដាយមាស ០២ គ្រឿង និងប្រាក់ ០២ គ្រឿង និងសំរិទ្ធ ០៤ គ្រឿង
    - ការប្រកួតកីឡាអត្តពលកម្ម មេដាយសំរិទ្ធ ០១ គ្រឿង
- ត្រៀមរៀបចំការប្រកួតកីឡាដើម្បីទាំងអស់គ្នា
- បង្កើតសមាគមកីឡា នៅតាមអង្គភាពសាលារៀនមធ្យមសិក្សាបានចំនួន០២ សមាគម ស្រុកត្បូងឃ្មុំ និងស្រុកមេមត់ នៅឆ្នាំ២០១៨
- រៀបចំក្រុមកីឡាកុមារា-កុមារី សិស្សបឋមសិក្សាដែលមានសមត្ថភាពចំនួន០៨ក្រុម មាន០៤ប្រភេទកីឡា មានកីឡាករ-ការិនីបាល់ទាត់ចំនួន៣៦ នាក់,បាល់ទះចំនួន ២៤ នាក់,បាល់បោះចំនួន ២៤ នាក់,និងអត្តពលកម្ម ចំនួន ១២ នាក់ នៅឆ្នាំ២០១៨
- រៀបចំក្រុមកីឡាករ-កីឡាការិនី សិស្សមធ្យមសិក្សាចំនួន១០ ក្រុម មាន០៦ ប្រភេទ មានកីឡាករ-កីឡាការិនី បាល់ទាត់ចំនួន ៣៦ នាក់ បាល់ទះចំនួន ២៤ នាក់ បាល់បោះចំនួន ២៤ នាក់ អត្តពលកម្មចំនួន ១២ នាក់ ប៉េតង់ចំនួន ០៦នាក់ និងវាយកូនឃ្លីលើតុចំនួន ០៣ នាក់ នៅឆ្នាំ២០១៨
- លទ្ធផលការប្រកួតដណ្តើមមេដាយ ទូទាំងប្រទេសទទួលបាន
    - ផ្នែកបឋមសិក្សាទទួលបានមេដាយប្រាក់ ០១ គ្រឿង និងមេដាយសំរិទ្ធ ០២ គ្រឿង
    - ផ្នែកមធ្យមសិក្សាទទួលបានមេដាយមាស ០២ គ្រឿង មេដាយប្រាក់ ០១ គ្រឿង និងមេដាយសំរិទ្ធ ០៤ គ្រឿង
- ចុះមើលការបង្រៀនរបស់គ្រូអប់រំកាយ និងកីឡា នៅតាមគ្រឹះស្ថានមធ្យមសិក្សាអោយបានចំនួន ២០ សាលា ក្នុងឆ្នាំសិក្សា២០១៨
- ចុះមើលការបង្រៀនបង្គោលគ្រូអប់រំកាយ និងកីឡា នៅតាមគ្រឹះស្ថានបឋមសិក្សាអោយបានចំនួន ១៥ សាលា ក្នុងឆ្នាំសិក្សា២០១៨ ។

# ទិសដៅ

# និងបញ្ហាប្រឈម

# ឆ្លងអនុវិស័យ

# ឆ្នាំសិក្សា ២០១៧-២០១៨

## ៣.២.បញ្ហាប្រឈម និងទិសដៅឆ្លងអនុវិស័យ

### ៣.២.១.ការពង្រឹកប្រព័ន្ធផែនការ

បញ្ហាប្រឈម

- មន្ត្រីផែនការថ្នាក់ក្រុង ស្រុកទទួលបន្ទុកការងារច្រើន និងផ្លាស់ប្តូរជាបន្តបន្ទាប់
- សមត្ថភាពមន្ត្រីជំនាញនៃមន្ទីរ ស្តីពីការទាញ និងវិភាគទិន្នន័យអប់រំនៅមានកម្រិត
- ការប្រមូលស្ថិតិអប់រំពីគ្រប់គ្រឹះស្ថានសិក្សានៅមានការយឺតយ៉ាវ នាយកសាលាទទួលបន្ទុកឧបសម្ព័ន្ធសាលាច្រើន និងប្រើប្រាស់គ្រូកិច្ចសន្យាទទួលបន្ទុក
- សមត្ថភាពមន្ត្រីទទួលបន្ទុកផែនការនៅថ្នាក់ការិយាល័យអប់រំ យុវជន ក្រុង/ស្រុក នៅមានកម្រិត
- ការផ្តល់ព័ត៌មានត្រឡប់ស្តីពីការសម្រេចផ្តល់ជូនតាមសំណើស្តីពីការសាងសង់ឡើងវិញ និងជួសជុល អគារទ្រុឌទ្រោម មានភាពយឺតយ៉ាវ និងនិតិវិធីស្មុគស្មាញ
- បណ្តាញខ្សែ ណេតវឺក វីភីអិន ( VPN Network ) នៅឆ្ងាយពីទីតាំងខេត្ត ២៤ គីឡូម៉ែត្រ

ទិសដៅ

- ប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ៤ដង នៅឆ្នាំ ២០១៨
- ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក ទាំង ៧ ផលិតបានផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧
- នាយកវិទ្យាល័យ អនុវិទ្យាល័យ និងបឋមសិក្សា ចំនួន ៣០ នាក់ ទទួលបានការបណ្តុះ បណ្តាលស្តីពីការបំពេញតារាងជំរឿនស្ថិតិអប់រំ
- សៀវភៅផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៨ របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តចំនួន ៣០០ ក្បាលបាន បោះពុម្ព និងផ្សព្វផ្សាយ ដល់ថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្រុងទាំង៧ ។
- បំប៉នសមត្ថភាពមន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡាក្រុង/ស្រុក ទាំង ៧ និងនាយកសាលាចំនួន ៤៥ សាលាស្តីពីការបំពេញតារាងជំរឿនស្ថិតិអប់រំ និងតារាងសម្រង់ពិន្ទុសិស្ស ឆ្នាំ២០១៨
- បំប៉នសមត្ថភាពមន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡា ក្រុង/ស្រុក ទាំង៧ ស្តីពីការកសាងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៨ និងការកសាងរបាយការណ៍សមិទ្ធកម្មចំនួន ២៨នាក់ នៅឆ្នាំ២០១៨
- ប្រជុំវាយតម្លៃការអនុវត្តផែនការប្រតិបត្តិឆ្នាំ ២០១៨របស់ខេត្ត បាន ២ដង នៅឆ្នាំ ២០១៨

### ៣.២.២.ការគ្រប់គ្រងបុគ្គលិក និងនីតិកម្ម

បញ្ហាប្រឈម

- ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងអង្គភាពមួយចំនួន មិនសូវយកចិត្តទុកដាក់ពីការងារជាមូលដ្ឋាន នាំឱ្យធ្វើការងារយឺតយ៉ាវ និងផ្តល់របាយការណ៍ផ្សេងៗពុំទាន់ពេលវេលា
- អង្គភាពមួយចំនួនមានមន្ត្រីជំនាញត្រូវចូលនិវត្តន៍ ហើយមន្ត្រីថ្មីកំពុងទទួលការងារបុគ្គលិកបន្ត ពុំទាន់យល់ដឹងច្បាស់អំពីកិច្ចការទាំងនោះ ធ្វើឱ្យរាំងស្ទះការងារដោយអន្លើៗ
- មន្ត្រីទទួលបន្ទុកការងារបុគ្គលិក របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក មួយចំនួន មិនទាន់ចេះប្រើប្រាស់កុំព្យូទ័រ គ្មានលទ្ធភាពបញ្ជូនទិន្នន័យតាមសំណូមពរ
- ការបញ្ជូនលិខិតបទដ្ឋានផ្សេងៗមួយចំនួន ពីក្រសួង មកមន្ទីរ មានភាពយឺតយ៉ាវ
- ការបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតនៅពុំទាន់មានតុល្យភាពជាមួយកង្វះគ្រូជាក់ស្តែងនៅ តាមមូលដ្ឋាន

- ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានរយៈពេលខ្លី ៣ ខែ ( ១ ខែកន្លះ ២ ដង) តាមលក្ខខណ្ឌ អតីតភាពការងារ ភេទ អាយុ តាមឯកទេសដែលសាមីខ្លួនបានជ្រើសរើស មិនទាន់បានសមស្រប
- តាមតម្រូវការជាក់ស្តែងសម្រាប់ឱ្យបង្រៀននៅវិទ្យាល័យ និងអនុវិទ្យាល័យ
- ការបែងចែកគ្រូបង្រៀនកម្រិតឧត្តម គ្រូមូលដ្ឋាន គ្រូបឋម និងគ្រូមត្តេយ្យសិក្សាមិនទាន់គ្រប់តាម តម្រូវការ និងគ្រប់ឯកទេស ។

ទិសដៅ

- អនុវត្តការងារពង្រាយគ្រូ ៖
  - + ឆ្លងស្រុកឱ្យបានចំនួន ៥ នាក់ ឆ្នាំ២០១៨
  - + ឆ្លងខេត្តឱ្យបានចំនួន ៣ នាក់ ឆ្នាំ២០១៨
  - + ឆ្លងឃុំឱ្យបានចំនួន ៥ នាក់ ឆ្នាំ២០១៨
- អនុវត្តការងារបណ្តុះបណ្តាលវគ្គគ្រប់គ្រង ជូនគណៈគ្រងគ្រងនៅតាមអង្គភាព ៤០ នាក់ ចំនួន ២ ដង នៅឆ្នាំ ២០១៨
- អនុវត្តការងារបំប៉នសមត្ថភាពបុគ្គលិកអប់រំតាមរយៈវគ្គបណ្តុះបណ្តាលផ្សេងៗឱ្យបាន ៥០ នាក់ ក្នុងឆ្នាំ២០១៨
- ជំរុញការប្រើប្រាស់ក្របខ័ណ្ឌបន្ថែម (ពីរពេល ថ្នាក់គួប កិច្ចសន្យា) ចំនួន ១,៦៣៤ នាក់ ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ដោយគោរពតាមការណែនាំរបស់ក្រសួង
- ជំរុញការចុះពិនិត្យតាមដានការប្រើប្រាស់ក្របខ័ណ្ឌបន្ថែម ម៉ោងបន្ថែម នៅតាមគ្រឹះស្ថានសិក្សា សាធារណៈ ទាំង ០៧ ក្រុង/ស្រុក
- បុគ្គលិកអប់រំទូទាំងខេត្តចំនួន ៤,៨៥៦ នាក់ បើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារនៅឆ្នាំ២០១៨
- បុគ្គលិកអប់រំចំនួន ២,១៦២ នាក់ ទទួលបានប្រាក់ឧបត្ថម្ភតំបន់ជួបការលំបាកចំនួន ៨០,០០០ រ ក្នុងមួយខែៗ

### ៣.២.៣.ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

បញ្ហាប្រឈម

#### ក.ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ការអនុម័តថវិកាប្រចាំឆ្នាំ ពុំទាន់ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ
- ការទូទាត់ថវិកាមានការយឺតយ៉ាវពុំទាន់ឆ្លើយតបទៅនឹងផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយសារមានការនិយ័តភាពផ្ទៃក្នុង និងការស្នើសុំគណទានបន្ថែម
- ពុំទាន់មានឃ្លាំងសម្រាប់ដាក់សម្ភារៈ

#### ខ.ការគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ

- មន្ត្រីជំនាញ ទទួលបន្ទុកការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋថ្នាក់ក្រុង/ស្រុក សមត្ថភាពផ្នែកព័ត៌មានវិទ្យានៅមានកម្រិត
- ការប្រមូលទិន្នន័យអចលទ្រព្យមានភាពយឺតយ៉ាវ
- ខ្វះថវិកាគាំទ្រសកម្មភាព ក្នុងការចុះពិនិត្យតាមដានរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងថវិកាសម្របសម្រួលរបាយការណ៍របស់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក

- ទីតាំងដីមួយចំនួនដែលបានចុះក្នុងបញ្ជីសារពើភ័ណ្ឌ និងទ្រព្យសម្បត្តិរដ្ឋរបស់សាលារៀនជាដីរបស់ក្រុមហ៊ុនចំការកៅស៊ូ និងជាដីរបស់វត្ត ជាហេតុមិនអាចធ្វើប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធដីធ្លីបាន
- វិវាទដីធ្លីចំនួន ០៨កន្លែងមិនទាន់បានដោះស្រាយក្នុងស្រុកអូររាំងឪ ២កន្លែង មេមត់ ២កន្លែង ក្រូចឆ្មារ ១កន្លែង ពញាក្រែក ២ កន្លែង និង ក្រុងសួង ១ កន្លែង
- អគារទ្រុឌទ្រោមមួយចំនួនបានដួលរលំ និងអគារមួយចំនួនទៀតដែលបានវាយកំទិចចោល មិនទាន់បាន ស្នើសុំជម្រះ។

### គ.ការងារគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល

- ការប្រមូលតារាងព័ត៌មាន និងតម្រូវការសៀវភៅសិក្សាគោលឆ្នាំ២០១៩-២០២០មានការយឺតយ៉ាវ
- ការគ្រប់គ្រងសៀវភៅសិក្សាគោល នៅតាមសាលារៀនមួយចំនួនមិនទាន់បានល្អ
- សាលាកើតថ្មីនៅមិនទាន់ទទួលបានសៀវភៅដោយសារតម្រូវការធ្វើមុនពីរឆ្នាំ ។

<u>ទិសដៅ</u>

- ផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ឱ្យដល់សាលារៀន ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ទាំង ៧ និងការិយាល័យក្រោមឱវាទមន្ទីរ បាន ៩៨.២០ភាគរយ ក្នុងឆ្នាំ២០១៨
- ការដកសាច់ប្រាក់ចំណាយថវិកាតាមផែនការប្រចាំឆ្នាំស្មើ ៩៨.២០ភាគរយ
- ផ្គត់ផ្គង់ម៉ូតូចំនួន២គ្រឿងតាមការិយាល័យក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨
- ជួសជុលអគារចាស់ទ្រុឌទ្រោមចំនួន២ កន្លែង (បឋមសិក្សា លោ និងបឋមសិក្សាពោធិ៍រោង)
- ធ្វើប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធដីធ្លីចំនួន ២១៥កន្លែង
- ធានាបាននូវការគ្រប់គ្រងផ្នែកបញ្ជីការសម្ភារៈរបស់ការិយាល័យ តាមរយៈសិក្ខាសាលាឱ្យបានចំនួន ៣ស្រុកបន្ថែម
- ផ្គត់ផ្គង់តុសិស្សអង្គុយពីរនាក់ចំនួន ១៦០០ គ្រឿង
- ធ្វើការជម្រះសម្ភារៈចាស់ៗដែលមិនអាចប្រើបាន
- ពង្រឹងការពិនិត្យតាមដានសម្ភារៈបរិក្ខាបច្ចេកទេស ១ ឆ្នាំ២ដង
- រៀបចំធ្វើតារាងព័ត៌មាន និងតម្រូវការសៀវភៅសិក្សាគោល ២០១៩-២០២០ ត្រឹមខែមិថុនា ២០១៨
- រៀបចំបញ្ជីសារពើភ័ណ្ឌ និងតារាងប្រៀបធៀបកើនឡើង ថយចុះឆ្នាំ២០១៧ ត្រឹមខែមិនា ២០១៨

### ៣.២.៤.ការងាររដ្ឋបាល

<u>បញ្ហាប្រឈម</u>

- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត មិនទាន់មានឃ្លាំងតម្កល់ឯកសារបណ្ណាសារ
- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ពុំទាន់មានសាលប្រជុំផ្ទាល់ខ្លួន

<u>ទិសដៅ</u>

- រៀបចំប្រជុំប្រចាំខែជាមួយថ្នាក់ស្រុក សាលា៤ដង ស្រុកជាមួយមន្ទីរ ១២ដង ឆ្នាំសិក្សា ២០១៧-២០១៨
- រៀបចំសន្និបាតថ្នាក់ខេត្តដែលមានសមាជិកចូលរួម ចំនួន ២៧៥នាក់ ឆ្នាំសិក្សា ២០១៧-២០១៨
- ចុះពិនិត្យតាមដាន ការងាររដ្ឋបាលមួយស្រុក ៥ដង តាមស្រុកគោលដៅឆ្នាំសិក្សា ២០១៧-២០១៨

- ចូលរួមអង្កេតការប្រជុំ តាមស្រុក ១ស្រុក៤ដង ឆ្នាំសិក្សា ២០១៧-២០១៨
- សន្និបាតថ្នាក់ជាតិ ដែលមានសមាជិកចូលរួមចំនួន ២៦នាក់ ឆ្នាំសិក្សា ២០១៧-២០១៨

### ៣.២.៤.ការងារគុណភាពអប់រំ

**បញ្ហាប្រឈម**

- ការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍នៅតាមសាលារៀនពុំទាន់បានល្អប្រសើរ
- សាលារៀនតាមតំបន់ជួបការលំបាក និងឆ្ងាយពីទីប្រជុំជនពុំទាន់មានគ្រូបង្រៀនគ្រប់គ្រាន់
- សិស្សអវត្តមានច្រើនក្នុងរដូវប្រមូលផលពិសេសចល័តទីលំនៅតាមឪពុកម្តាយ
- ការអនុវត្តម៉ោងសិក្សាមិនបានពេញលេញ
- សមត្ថភាពគ្រប់គ្រង របស់នាយកសាលាមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀន
- សាលារៀនមួយចំនួនពុំបានយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ និងថែរក្សាសៀវភៅសិក្សាគោល
- សកម្មភាពចុះជួយសាលារៀនរបស់ក្រុមអធិការកិច្ចផ្ទៃក្នុងមានដំណើរការតិចតួច
- កង្វះសៀវភៅសិក្សាគោលភាគច្រើនថ្នាក់ទី១ និងថ្នាក់ទី២ ផ្នែកភាសាខ្មែរ
- អគារសិក្សានៅតែជាបញ្ហាចោទ (ទ្រុឌទ្រោម, កង្វះអគារ) សម្រាប់ដំណើរការសាលារៀន
- ការផ្តល់សេវាសុខភាព អនាម័យដល់សិស្សនៅតាមសាលារៀនពុំទាន់ល្អប្រសើរ
- បណ្ណាល័យ និងបណ្ណារក្សពុំទាន់ឆ្លើយតប និងតម្រូវការសិស្សនៅឡើយ

**ទិសដៅ**

- ចុះអធិការកិច្ចតាមកាលកំណត់នៅតាមគ្រឹះស្ថានសិក្សាបានចំនួន ២៩សាលារៀន ឆ្នាំ២០១៦-២០១៧ និងកើនដល់ ៩៦សាលារៀន ក្នុងឆ្នាំ២០១៧-២០១៨
- ចុះពិនិត្យតាមដានវឌ្ឍនភាពសាលារៀនដែលបានធ្វើអធិការកិច្ចរួច (ពុំទាន់មានសកម្មភាពឆ្នាំ២០១៦-២០១៧ និងចុះពិនិត្យចំនួន ៥៩សាលារៀន ឆ្នាំ២០១៧-២០១៨)
- របាយការណ៍លទ្ធផលការងារអធិការកិច្ចតាមកាលកំណត់ត្រូវបានផ្សព្វផ្សាយដល់គណៈគ្រប់គ្រង លោកគ្រូ/អ្នកគ្រូចំនួន ៥៧នាក់ ឆ្នាំសិក្សា២០១៦-២០១៧ និងកើនដល់ចំនួន ១០៣នាក់ ឆ្នាំសិក្សា២០១៧-២០១៨
- របាយការណ៍លទ្ធផលអធិការកិច្ចផ្ទៃក្នុងថ្នាក់ ក្រុង ស្រុកបានបូកសរុប និងផ្សព្វផ្សាយចំនួន ២លើក ឆ្នាំសិក្សា ២០១៦-២០១៧ និង២លើកទៀត ឆ្នាំសិក្សា២០១៧-២០១៨
- ផ្សព្វផ្សាយពិគ្រោះយោបល់លទ្ធផលតេស្តវង្វាយតម្លៃសិស្សថ្នាក់ជាតិដល់គណៈគ្រប់គ្រង លោកគ្រូ/អ្នកគ្រូ ៤៥នាក់ ក្នុងឆ្នាំ២០១៦-២០១៧ និងកើនដល់ ៨៤នាក់ នៅឆ្នាំ២០១៧-២០១៨

## ៤-សេចក្តីសន្និដ្ឋាន

មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្ថិតក្នុងដំណាក់កាលប្រែប្រួលសំខាន់មួយ នៃការអនុវត្តសសរស្តម្ភកំណែទម្រង់ធំៗ ចំនួន៥។ ប្រការនេះទាមទាឱ្យមានការគិតគូរអំពីអភិក្រមទូទាំងវិស័យពាក់ព័ន្ធ និងពង្រីកកាលានុវត្តភាពគ្រប់អនុវិស័យ ទាំងប្រាំមួយប្រកបដោយសមត្ថភាព និងមានប្រសិទ្ធភាព ។

អនុវិស័យអប់រំកុមារតូច បានបង្ហាញពីវឌ្ឍនភាព ក្នុងការពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាព ជាពិសេស ការផ្តល់សេវាមត្តេយ្យសិក្សាសម្រាប់កុមារអាយុ ៥ឆ្នាំ អនុវត្តបានការផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយ និងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូច។

អនុវិស័យអប់រំបឋមសិក្សា បានបង្ហាញពីលទ្ធផលដែលទទួលបាននេះ ដោយសារមានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង និងមន្ទីរក្នុងការកំណត់ ទិសដៅផែនការច្បាស់លាស់របស់ការិយាល័យ និងការចូលរួមសហការអនុវត្តប្រកបដោយប្រសិទ្ធភាពពីមន្ត្រីអប់រំ និងអាជ្ញាធរនៅមូលដ្ឋានផ្ទាល់ ព្រមទាំងនឹងអង្គការដៃគូ ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែល បានចូលរួមប្រកបដោយការទទួលខុសត្រូវខ្ពស់ដល់ការប្រមូលកុមារប្រកបដោយសមធម៌ និងបរិយាប័ន្ន និងអន្តរាគមន៍ពិសេសក្នុងការលើក កម្ពស់បំណិនអំណាននៅកម្រិតដំបូងនៃបឋមសិក្សា និងការទប់ស្កាត់ការបោះបង់ការសិក្សា។

អនុវិស័យអប់រំមធ្យមសិក្សាចំណេះទូទៅ បានបង្ហាញពីវឌ្ឍនភាពក្នុងការពង្រឹងគុណភាពការ ទប់ស្កាត់សិស្សបោះបង់ការសិក្សាការពង្រីកការយល់ដឹង និងពង្រឹងយន្តការវាយតម្លៃលទ្ធផល សិក្សា និងការប្រឡង។

អនុវិស័យអប់រំក្រៅប្រព័ន្ធ បានបង្ហាញពីវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធគ្រប់រូបភាព ជាពិសេសយុទ្ធនាការអក្ខរកម្មជាតិ ការបង្កើតឱកាសទី២ សម្រាប់ការទទួលបានការបញ្ចប់ថ្នាក់មធ្យមសិក្សា តាមរយៈប្រព័ន្ធសមមូលសញ្ញាបត្រ។

អនុវិស័យការអភិវឌ្ឍន៍យុវជន បានបង្ហាញពីវឌ្ឍនភាពក្នុងការកែលម្អរចនាសម្ព័ន្ធក្រុមប្រឹក្សាកុមារ និងយុវជន ការបណ្តុះបណ្តាលជំនាញរឹង ជំនាញទន់ និងប្រឹក្សាអាជីព ។

អនុវិស័យការអប់រំកាយ និងកីឡា បានបង្ហាញពីវឌ្ឍនភាពនៃការពង្រឹង ការជំរុញសកម្មភាព អប់រំកាយ និងកីឡានៅតាមសាលារៀន និងកីឡាមហាជន។

សមិទ្ធផលដែលសម្រេចបានខាងលើ ពិតជាបានបង្ហាញយ៉ាងច្បាស់ពីការខិតខំប្រឹងប្រែង របស់យើងទាំងអស់គ្នាដែលមានការទទួលខុសត្រូវខ្ពស់ តាមតួនាទី និងភារៈកិច្ចសំដៅធ្វើឱ្យការអភិវឌ្ឍវិស័យអប់រំមានការរីកចម្រើន ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៥-២០១៧។ ការចូលរួមពីសំណាក់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងប្រាកដនិយមរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ក្តីសង្ឃឹម និងភាពជឿជាក់ខ្ពស់ចំពោះជោគវាសនាអនាគតរបស់ប្រជាជនគ្រប់រូប ព្រមទាំងគ្រួសារនីមួយៗ ។

ថ្ងៃ អង្គារ ១៥រោជ ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ត្បូងឃ្មុំ.ថ្ងៃទី ខែ មករា ឆ្នាំ ២០១៨
**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

**អ៊ិន ពៅសម្បត្តិ**

*<u>ចម្លងជូន៖</u>*

*-ក្រសួងអប់រំ យុវជន និងកីឡា ( នាយកដ្ឋានរដ្ឋបាល )*
*-សាលាខេត្តត្បូងឃ្មុំ*
*"ដើម្បីជូនជ្រាប"*
*-ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក*
*-គ្រប់សាលាមធ្យមសិក្សា និងកម្រងបឋមសិក្សាទូទាំងខេត្ត*
*"ដើម្បីជូនជ្រាប និងអនុវត្ត"*
*-អង្គការដៃគូអភិវឌ្ឍន៍វិស័យអប់រំ*
*"ដើម្បីជូនជ្រាប និងសហការអនុវត្ត"*
*-ឯកសារ-កាលប្បវត្តិ ៖ កា.រ.រដ្ឋបាល*

# ផ្នែកទី២

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១ ៖ វឌ្ឍនភាពនៃការសម្រេចបានសូចនាករស្នូល និងចំនុចដៅសម្រាប់ឆ្នាំ ២០១៦ ដល់ ២០២០**

| សូចនាករស្នូល | ជាក់ស្តែង ២០១៥-១៦ | ចំណុចដៅ ២០១៦-១៧ | ជាក់ស្តែង ២០១៦-១៧ | ស្ថានភាព |
|---|---|---|---|---|
| *គោលនយោបាយទី១ ៖ ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | | | | |
| ១. ភាគរយកុមារអាយុ ៥ឆ្នាំក្នុងការអប់រំកុមារតូចគ្រប់រូបភាព | ៥៨.៨១% | ៦៥% | ៥៩% | → |
| ២. ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់បឋមសិក្សាយ៉ាងតិច ៨០ ភាគរយ | ៧ | ៧ | ៧ | ↑ |
| ៣. ចំនួនស្រុកដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ ភាគរយ | ១ | ១ | ១ | ↑ |
| ៤. អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥ឡើង) | ៩០.៤៧% | ៩០.៧២% | ៩០.៧០% | → |
| ៥. ការវាយតម្លៃថ្នាក់ជាតិលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី ៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | | | | |
| ការអាន | N/A | ៥២១%. | ៥២១%. | ↑ |
| គណិតវិទ្យា | N/A | ៤៨៣%. | ៤៨៣%. | ↑ |
| *គោលនយោបាយទី២ ៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | | | |
| ៦. ចំនួនគ្រូបង្រៀនបានចូលរួមថ្នាក់ពន្លឿន | ២៨ នាក់ | ៤៥ នាក់ | ២៨ នាក់ | → |
| ៧. ចំនួននាយកសាលាបានបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល | ៤០នាក់ | ៥០ នាក់ | ៤៣ នាក់ | → |
| ៨. ភាគរយនៃការទូទាត់ថវិកា | ៨៦១៧%. | ៩៥% | ៩៨១៧%. | ↑ |

**សម្គាល់:** ↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

## ឧបសម្ព័ន្ធទី២៖ វឌ្ឍនភាពនៃការអនុវត្តទិសដៅសន្និបាតឆ្នាំសិក្សា ២០១៦-២០១៧

| អនុវិស័យ/ ឆ្លងអនុវិស័យ | សកម្មភាព | ស្ថានភាព | សេចក្ដីបញ្ជាក់ |
|---|---|---|---|
| **១.អនុវិស័យ** | | | |
| ១.១.ការអប់រំកុមារតូច | ភាគរយកុមារអាយុ ៥ឆ្នាំ ចូលរៀន | ២ | ខ្វះគ្រូ,ខ្វះថ្នាក់, |
| | ភាគរយកុមារអាយុ ៤ឆ្នាំ ចូលរៀន | ២ | ខ្វះគ្រូ,ខ្វះថ្នាក់, |
| | ភាគរយកុមារអាយុ ៣ឆ្នាំ ចូលរៀន | ២ | ខ្វះគ្រូ,ខ្វះថ្នាក់, |
| | ភាគរយសេវាអប់រំកុមារតូចដែលគោរពតាមស្តង់ដាគុណភាព | ២ | គ្មានថវិកាគាំទ្រ |
| | បញ្ចូលកម្មវិធីអប់រំមាតាបិតាផ្សាភ្ជាប់និងមត្តេយ្យសិក្សារដ្ឋ | ២ | គ្មានថវិកា ខ្វះគ្រូថ្នាក់ |
| | ពង្រីកកម្មសេវាមត្តេយ្យសិក្សាសហគមន៍ឱ្យបានបន្ថែម | ១ | |
| | ពង្រីកកម្មសេវាមត្តេយ្យសិក្សាក្នុងបឋមឱ្យបានបន្ថែម | ១ | |
| | មន្ត្រីអប់រំកុមារតូចទាំងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ចូលទិន្នន័យM&E | ១ | |
| | កុមារអាយុ៥ឆ្នាំដែលបានទទួលសេវាអប់រំកុមារតូចទាំងអស់បានធ្វើក្នុង១ឆ្នាំ | ២ | បានធ្វើតេស្តតែក្នុងបឋមសិក្សា ចំណែក ៣សេវាទៀតអត់ធ្វើ |
| | កុមារដែលស្ថិតសេវាអប់រំកុមារតូចទាំងអស់ទទួលបានថ្នាំលាក់ព្រូន | ២ | ស្រុកតំបែរ,ពញាក្រែកទទួលបានតែម្តង រី សាលាខ្លះមិនបានទទួលតែម្តង |
| | កុមារដែលស្ថិតសេវាអប់រំកុមារតូចទាំងអស់ទទួលបានអាហារូបត្ថម្ភ | ២ | គ្មានទិន្នន័យ |
| | កុមារដែលស្ថិតសេវាអប់រំកុមារតូចទាំងអស់ទទួលបានមីក្រូសារជាតុចិញ្ចឹម | ២ | គ្មានទិន្នន័យ |
| ១.២.ការអប់រំបឋមសិក្សា | ភាគរយសាលាកុមារមេត្រីកម្រិតមធ្យមនិងកម្រិតអតិខ្ពស់ | ២ | សាលាខ្វះថវិកា |
| | អត្រាពិតចូលរៀនថ្មី | ២ | |
| | អត្រាពិតនៃការសិក្សា | ២ | |
| | អត្រាបោះបង់ការសិក្សាថយចុះ | ២ | ផ្លាស់ទីលំនៅ |
| | អត្រាត្រួតថ្នាក់ថយចុះ | ២ | រដូវប្រមូលផល |
| | អត្រាបញ្ចប់ការសិក្សាកើន | ២ | សិស្សឈប់ច្រើន |
| | ភាគរយកុមារចូលរៀនថ្នាក់ទី១ថ្មី បានឆ្លងកាត់មត្តេយ្យសិក្សាកើន | ២ | មានមត្តេយ្យសិក្សា នៅក្នុងបឋម |
| | អត្រាឆ្លងកូមិសិក្សាទៅមធ្យមសិក្សាបឋមភូមិកើន | ២ | សិស្សបោះបង់ |
| | ភាគរយសាលាបឋមសិក្សាមាន | | |
| | កន្លែងលាងសម្អាតដៃ | ១ | |
| | ប្រអប់សង្គ្រោះបឋម | ២ | |
| | មានបង្គន់អនាម័យនិងទឹកស្អាត | ២ | |
| | បណ្តុះបណ្តាលដល់គ្រូទទួលបន្ទុកសុខភាពសិក្សា | ១ | |
| | សាងសង់បង្គន់អនាម័យនិងកន្លែងលាងដៃបន្ថែមទៀត | ១ | |
| | បណ្តុះបណ្តាលបណ្ណារក្សដែលថ្មី | ៣ | គ្មានថវិកា |

| | | | |
|---|---|---|---|
| ១.៣.ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ថយចុះ | ១ | |
| | អត្រាពិតនៃការសិក្សាមធ្យមសិក្សាបឋមភូមិ | ២ | |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ កើន | ១ | |
| | អត្រាពិតនៃការសិក្សាមធ្យមសិក្សាទុតិយភូមិភូមិ កើន | ២ | ចំណាកស្រុករកការងារធ្វើ |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើន | ១ | |
| | អត្រាឆ្លងភូមិសិក្សាពីថ្នាក់ទី៦ ទៅ ថ្នាក់ទី៧ កើន | ១ | |
| | អត្រាឆ្លងភូមិសិក្សាពីថ្នាក់ទី៩ ទៅ ថ្នាក់ទី១០ កើន | ១ | |
| | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិកើន | ១ | |
| | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើន | ១ | |
| | សិស្សមធ្យមសិក្សាបឋមភូមិទទួលអាហារូបករណ៍ | ១ | |
| | សិស្សមធ្យមសិក្សាទុតិយភូមិ ទទួលអាហារូបករណ៍ | ១ | |
| | គ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីសាលាកុមារមេត្រីកើន | ១ | |
| | លទ្ធផលប្រឡងសិស្សពូកែថ្នាក់ជាតិ ទទួលបាន | ២ | សមត្ថភាពសិស្សនៅមានកម្រិត |
| | សិស្សពូកែ ទទួលបានរង្វាន់លើកទឹកចិត្ត | ១ | |
| | ចុះពិនិត្យតាមដាន និងផ្តល់បច្ចេកទេស ក្នុងការបង្រៀន និងរៀន | ២ | ខ្វះថវិកា |
| | សាលាមធ្យមសិក្សា អនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមគោលការណ៍ណែនាំ | ១ | |
| | សាលាមធ្យមសិក្សា ទទួលវគ្គបំប៉នផ្សព្វផ្សាយការងារតម្រង់ទិសវិជ្ជាជីវៈ | ២ | ខ្វះថវិកា |
| ១.៤.ការអប់រំក្រៅប្រព័ន្ធ | អត្រាអក្ខរកម្មមនុស្សពេញវ័យអាយុ១៥-៤៥ឆ្នាំកើន | ១ | |
| | ភាគរយប្រជាជនបានបញ្ចប់ថ្នាក់អក្ខរកម្មកើនដល់ | ២ | បោះបង់ការសិក្សាចំណាកស្រុក |
| | ចំនួនអ្នកបានបញ្ចប់ថ្នាក់ជំនាញ នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ | ២ | សិស្សចូលរៀនសរុប២០២នាក់ |
| | សិស្សកម្មវិធីចូលរៀនឡើងវិញបានបញ្ជូនទៅក្នុងប្រព័ន្ធ | ២ | សិស្សចូលរៀនសរុបបានត្រឹមតែ ៩២៥ នាក់ ស្រី៣៨៥នាក់ ព្រោះក្រសួងឱ្យតែ ៤៥ថ្នាក់ |
| | ចំនួនសិស្សចូលរៀនកម្មវិធីសមមូលបឋមសិក្សា | ១ | |
| | មធ្យមសិក្សាបឋមភូមិ | ២ | រើសគ្រូមិនបាន, មិនបានលើកគម្រោងថវិកា |
| | ត្រូវបានបំពាក់សៀវភៅអាន | | |
| | បណ្ណាល័យ | ១ | |
| | មណ្ឌលអាន | ២ | |
| | មជ្ឈមណ្ឌលសិក្សាសហគមន៍ | ២ | |

| | | | |
|---|---|---|---|
| ១.៥.ការអប់រំកាយ និងកីឡា | ចុះពិនិត្យការអនុវត្តសកម្មភាពកីឡាក្រៅសាលាអោយ ចូលរួមហ្វឹកហាត់តាមក្លូនខ្នាត តាមបច្ចេកទេសកីឡា នៅតាមឃុំទាំង ៧ ក្រុង/ស្រុក។ | ២ | ខ្វះថវិកាសម្រាប់ទ្រទ្រង់ |
| | បង្កើតក្លិបកីឡាបាល់ទាត់ នៅតាមសហគមន៍អោយបាន | ១ | |
| | រៀបចំការប្រកួតកីឡាមហាជនថ្នាក់ខេត្ត មានក្រុមចូលរួម | ១ | |
| | លទ្ធផលការប្រកួតដណ្តើមមេដាយ ទូទាំងប្រទេសទទួលបាន | | |
| | ការប្រកួតពានរង្វាន់សម្តេចហ៊ុន សែន លើកទី ១១ មេដាយ | ៣ | មិនថវិកាសម្រាប់ទ្រទ្រង់ការហ្វឹកហាត់ |
| | ការប្រកួតកីឡាសិស្សឧត្តមសិក្សា មេដាយ | ២ | ខ្វះកីឡាករ-ការិនី នៅតាមវិទ្យាល័យ |
| | ការប្រកួតកីឡាបាល់ទាត់នារីអាយុ ១៧ ឆ្នាំ មេដាយ សំរិត | ២ | ខ្វះធនធានកីឡា |
| | បណ្តុះបណ្តាលវគ្គអាជ្ញាកណ្តាលក្រុង/ស្រុកទាំង០៧ នៅឆ្នាំ២០១៧ | ៣ | គ្មានថវិកា |
| | ប្រជុំបច្ចេកទេសកីឡាបាល់ទាត់ បាល់ទះ បាល់បោះ ប៉េតង់ និងអត្តពលកម្ម | ១ | |
| | រៀបចំក្រុមកីឡាកុមារា-កុមារី សិស្សបឋមសិក្សាដែលមានសមត្ថភាព មាន០៤ វិញ្ញាសា | ១ | |
| | រៀបចំក្រុមកីឡាករ-ការិនី សិស្សមធ្យមសិក្សា មាន០៥ វិញ្ញាសា | ១ | |
| | បង្កើតក្លិប សមាគមកីឡា នៅតាមសាលារៀនមធ្យសិក្សា ស្រុកពញាក្រែក និងស្រុកតំបែរ | ១ | |
| | លទ្ធផលការប្រកួតដណ្តើមមេដាយ ទូទាំងប្រទេសទទួលបាន | | |
| | ផ្នែកបឋមសិក្សាទទួលបានមេដាយ មាស | ២ | ការប្រកួតតាមបែបថ្មី សិស្សពិបាកយលពីបច្ចេកទេស |
| | ផ្នែកមធ្យមសិក្សាទទួលបានមេដាយ | ១ | |
| | បណ្តុះបណ្តាលគ្រូបង្គោលនៅបឋមសិក្សាលើមុខវិជ្ជាអប់រំកាយនិងកីឡានៅឆ្នាំ២០១៧ | ១ | |
| | ប្រជុំបច្ចេកទេសកីឡាបាល់ទាត់ បាល់ទះ បាល់បោះ ប៉េតង់ និងអត្តពលកម្ម | ១ | |
| | ចុះមើលការបង្រៀនរបស់គ្រូអប់រំកាយនិងកីឡានៅតាមគ្រឹះស្ថានមធ្យមសិក្សា | ២ | កង្វះថវិកាសម្រាប់ទ្រទ្រង |
| | ចុះមើលការបង្រៀនបង្គោលគ្រូអប់រំកាយនិងកីឡានៅតាមគ្រឹះស្ថានបឋមសិក្សា | ២ | កង្វះថវិកាទ្រទ្រង |
| ១.៦.ការអភិវឌ្ឍយុវជន | ចំនួនយុវជនក្រៅសាលា ទទួលការអប់រំផ្សព្វផ្សាយស្តីពីមេរោគអេដស៍ ជម្ងឺអេសដ៍ និងជម្ងឺឆ្លងផ្សេងៗ | ១ | |
| | កាយរឹទ្ធិប្អូន និងកាយរឹទ្ធិក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាល និងបំពាក់កន្សែង | ១ | |
| | កុមារបានចូលរួមក្នុងពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី ៦៨ ទិវាកុមារអន្តរជាតិ ០១ មិថុនាឆ្នាំ២០១៧ | ១ | |
| | យុវជនបានចូលរួមក្នុងពីធីប្រារព្ធទិវាយុវជនអន្តរជាតិ ១២ សីហា ឆ្នាំ២០១៧ | ៣ | មិនមានថវិកា |
| | យុវជនដែលមានស្នាដៃបីល្អ បានចូលរួមក្នុងពិធីសន្និបាតចលនាបីល្អថ្នាក់ខេត្ត | ១ | |
| | យុវជនទទួលបានការអប់រំ ផ្សព្វផ្សាយស្តីពី " យុវជន និងទីផ្សារការងារ" | ១ | |
| | យុវជនក្នុងសាលាទទួលបានការអប់រំ ស្តីពីសហគ្រិនភាព | ១ | |
| | យុវជនក្រៅសាលាទទួលបានការអប់រំ ស្តីពីសហគ្រិនភាព | ២ | មិនមានថវិកា |
| | ក្រុមប្រឹក្សាកុមារនិងយុវជនបានចូលរួមដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវ និងរៀនសូត្រ | ១ | |
| | យុវជនដែលមានស្នាដៃបីល្អ បានចូលក្នុងសន្និបាតចលនាបីល្អ | ១ | |
| | យុវជនបានចូលរួមក្នុងកម្មវិធីបោះជំរុំថ្នាក់ខេត្ត និងថ្នាក់ជាតិ | ១ | |
| | សាលាត្រូវបានចុះពិនិត្យតាមដានការអនុវត្ត សកម្មភាពកុមារ/យុវជន | | |
| | មធ្យមសិក្សា | ១ | |
| | សាលាបឋម | ១ | |
| | យុវជនស្ម័គ្រចិត្តក្រៅសាលាបាចូលរួមដំណើរទស្សនកិច្ចសិក្សាស្រាវជ្រាវ និងរៀនសូត្រ | ២ | មិនមានយុវជនស្ម័គ្រចិត្ត |
| | យុវជនស្ម័គ្រចិត្តក្រៅសាលាទទួលបានការហ្វឹកហាត់ការងារហាត់ការ និងបំនិនជីវិត | ២ | មិនមានថវិកា |
| | យុវជនទទួលបានការបណ្តុះបណ្តាលជំនាញកាត់ដេរ | ១ | |
| | យុវជនទទួលបានការបណ្តុះបណ្តាលភ្លេងពិណ្ឌពាទ្យ និងភ្លេងខ្មែរ | ១ | |
| | យុវជនទទួលបានការបណ្តុះបណ្តាលភាសាបរទេស | ៣ | មិនមានថវិកា |
| | យុវជនទទួលបានការបណ្តុះបណ្តាលវគ្គជួសជុលកុំព្យូទ័រ | ២ | កង្វះថវិកា |

## ២.ឆ្លងអនុវិស័យ

| | | | |
|---|---|---|---|
| ២.១.ការពង្រឹងប្រព័ន្ធផែនការ | ប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ | ២ | |
| | ការិយាល័យ អយក ក្រុង/ស្រុក ផលិតបានផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ | ១ | |
| | នាយកវិទ្យាល័យ អនុវិទ្យាល័យ និងបឋមសិក្សា ទទួលបានការបណ្តុះបណ្តាលស្តីពីការបំពេញតារាងជំរឿនស្ថិតិអប់រំ | ១ | |
| | ផ្សព្វផ្សាយ | ១ | |
